កាន់តែទុកចិត្ត កាន់តែចំរើន

ហត្ថាកសិករ លីមីតធីត

HATTHA KAKSEKAR LIMITED

# ២០១៩
# របាយការណ៍
# ប្រចាំឆ្នាំ



ហត្ថាកសិករជាបុត្រសម្ព័ន្ធរបស់ធនាគារក្រុងស្រី សមាជិក MUFG សម្ព័ន្ធក្រុមហ៊ុនហិរញ្ញវត្ថុសកល

# មាតិកា


**ក. លទ្ធផលប្រតិបត្តិការសង្ខេប** ........ ០២
**ខ. លទ្ធផលហិរញ្ញវត្ថុសង្ខេប** ........ ០៣
**គ. ធុរកិច្ចសង្គមសង្ខេប** ........ ០៣
**ឃ. ដៃគូអាជីវកម្ម** ........ ០៤
**ង. ការិយាល័យ និងបណ្តាញចែកចាយ** ........ ០៥
**ច. ព័ត៌មានទូទៅរបស់ ហត្ថាកសិករ លីមីតធីត** ........ ០៦
អំពី ហត្ថាកសិករ លីមីតធីត ........ ០៦
ទស្សនវិស័យ បេសកកម្ម និងតម្លៃស្នូល ........ ០៧
ប្រវត្តិ ហត្ថាកសិករ លីមីតធីត ........ ០៨
សារប្រធានក្រុមប្រឹក្សាភិបាល ........ ០៩
សារប្រធានអគ្គនាយក ........ ១០
**ឆ. ទិដ្ឋភាពលើ សកម្មភាពអាជីវកម្ម** ........ ១១
ភាគហ៊ុនិក ........ ១១
ដៃគូហិរញ្ញវត្ថុ ........ ១១
ក្រុមប្រឹក្សាភិបាល ........ ១២
កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ........ ១៥
រចនាសម្ព័ន្ធស្ថាប័ន ........ ១៨
សមាជិកគណៈកម្មាធិការប្រតិបត្តិ ........ ១៩
ជីវប្រវត្តិសមាជិកគណៈកម្មាធិការប្រតិបត្តិ ........ ២០
កិច្ចការទីផ្សារ និងការស្រាវជ្រាវ ........ ២៤
ផលិតផល និង សេវាកម្មហិរញ្ញវត្ថុ ........ ២៥
សកម្មភាពសេវាបម្រើអតិថិជន ........ ២៩
របាយការណ៍គ្រប់គ្រងធនធានមនុស្ស ........ ២៩
ការគ្រប់គ្រងហានិភ័យ ........ ៣១
ការប្រតិបត្តិតាម ........ ៣៣
ក្រមប្រតិបត្តិសីលធម៌ និងគោលការណ៍ ........ ៣៣
**ជ. ការត្រួតពិនិត្យផ្ទៃក្នុង និងសវនកម្មផ្ទៃក្នុង** ........ ៣៤
**ឈ. របាយការណ៍នៃការគ្រប់គ្រងធុរកិច្ចសង្គម** ........ ៣៥
សកម្មភាពទំនួលខុសត្រូវសង្គម ........ ៣៥
សូចនាករសមិទ្ធផលបរិស្ថាន ........ ៣៥
**ញ. របាយការណ៍ក្រុមប្រឹក្សាភិបាល** ........ ៣៦
**ដ. របាយការណ៍របស់សវនករឯករាជ្យ** ........ ៤០
តារាងតុល្យការ ........ ៤០
របាយការណ៍លទ្ធផល ........ ៤១
របាយការណ៍បម្រែបម្រួលមូលធន ........ ៤១
របាយការណ៍លំហូរសាច់ប្រាក់ ........ ៤២

# ក. លទ្ធផលប្រតិបត្តិការសង្ខេប

**ផលបត្រឥណទាន**

| គិតជាដុល្លារអាមេរិក | ២០១៧ | ២០១៨ | ២០១៩ | ប្រែប្រួលជាតួលេខ | ប្រែប្រួលជា (%) |
|---|---|---|---|---|---|
| ផលបត្រឥណទានសរុប | ៥៧៦.៨៨០.១៥៦ | ៧៥៧.៣២៦.៧៤៤ | ១.០៥០.៩២៨.៨៣៨ | ២៩៣.៦០២.០៩៤ | ៣៩,00% |
| ឥណទានជាប្រាក់រៀល | ៣៤.៧៥២.៩៧៧ | ៧២.៣៦៣.១៩៧ | ១៦០.២៩៩.២៤៧ | ៨៧.៩៣៦.០៥០ | ១២២,00% |
| ឥណទានជាប្រាក់ដុល្លារអាមេរិក | ៥១៩.៧០៦.១៤៤ | ៦៥៧.៥១៨.៨៤៧ | ៨៥២.៤៥៣.៥៧៤ | ១៩៤.៩៣៤.៧២៧ | ៣០,00% |
| ឥណទានជាប្រាក់ថៃបាត | ២២.៤២១.០៣៤ | ២៧.៤៤៤.៧០០ | ៣៨.១៧៦.០១៧ | ១០.៧៣១.៣១៧ | ៣៩,00% |

**ចំនួនអតិថិជនឥណទាន**

| ចំនួនអតិថិជន | ២០១៧ | ២០១៨ | ២០១៩ | ប្រែប្រួលជាតួលេខ | ប្រែប្រួលជា (%) |
|---|---|---|---|---|---|
| ចំនួនអតិថិជនសរុប | ១១៨.៣៩៩ | ១៣៤.៤១០ | ១៥០.៥៣១ | ១៦.១២១ | ១២,00% |
| ចំនួនអតិថិជនស្ត្រី | ៧៧.៤១១ | ៨៥.១៨៧ | ៩២.៣៦១ | ៧.១៧៤ | ៨,00% |
| ចំនួនអតិថិជនបុរស | ៤០.៩៨៨ | ៤៩.២២៣ | ៥៨.១៧០ | ៨.៩៤៧ | ១៨,00% |

**ឥណទានបានបញ្ចេញ**

| ចំនួនឥណទានបានបញ្ចេញ | ២០១៧ | ២០១៨ | ២០១៩ | ប្រែប្រួលជាតួលេខ | ប្រែប្រួលជា (%) |
|---|---|---|---|---|---|
| ឥណទានបានបញ្ចេញ (ដុល្លារអាមេរិក) | ៥២៨.៨៤៦.០៦៨ | ៦២៨.២០៤.៨១៣ | ៨៤៧.៨៣១.៥១២ | ២១៩.៦២៦.៦៩៩ | ៣៥,00% |
| ចំនួនអតិថិជនឥណទាន | ៩៣.០៥០ | ៩៨.១៥៩ | ១០៧.៧១៣ | ៩.៥៥៤ | ១០,00% |

**គុណភាពឥណទាន**

| (គិតជាដុល្លារអាមេរិក) | ២០១៧ | ២០១៨ | ២០១៩ | ប្រែប្រួលជាតួលេខ | ប្រែប្រួលជា (%) |
|---|---|---|---|---|---|
| ឥណទានមិនដំណើរការ (៣០ថ្ងៃ) | ៦.៣៥៩.៧១០ | ៥.១៧៤.៧០៤ | ៣.៨៤១.៧១៧ | (១.៣៣២.៩៨៧) | (២៦,00%) |
| ចំនួនប្រាក់ដើមហួសកាលត្រូវសង | ៦.៨៣៧.៥៤១ | ៥.៥០០.១២៩ | ៤.២២៦.៧០១ | (១.២៧៣.៤២៨) | (២៣,00%) |
| អត្រាឥណទានមិនដំណើរការ (៣០ថ្ងៃ) | ១,១0% | 0,៦៨% | 0,៣៧% | (0,៣១%) | (៤៦,00%) |

**បញ្ញើសន្សំ**

| បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ប្រែប្រួលជាតួលេខ | ប្រែប្រួលជា (%) |
|---|---|---|---|---|---|
| សមតុល្យប្រាក់បញ្ញើសន្សំជាដុល្លារអាមេរិក | ៣៦៧.៥៥៣.៦៨១ | ៤៨០.១០៦.១២១ | ៥៩៩.៣០១.៧៧៩ | ១១៩.១៩៥.៦៥៨ | ២៥,00% |
| ចំនួនអតិថិជនបញ្ញើសន្សំ | ២២៥.៩៦០ | ២៣៥.៧៩៦ | ២៥៩.៦៣៤ | ២៣.៨៣៨ | ១០,00% |

**សេវាអេធីអឹម និងធនាគារចល័ត**

| បរិយាយ | ២០១៧ | ២០១៨ | ២០១៩ | ប្រែប្រួលជាតួលេខ | ប្រែប្រួលជា (%) |
|---|---|---|---|---|---|
| ចំនួនប័ណ្ណ អេធីអឹម | ៤០.០២៧ | ៤៦.៦៦៥ | ៥១.១៦២ | ៤.៤៩៧ | ១០,00% |
| អតិថិជនសេវាធនាគារចល័ត | ៦.០១៣ | ៧.២១៥ | ៨.០២៤ | ៨០៩ | ១១,00% |

# ខ. លទ្ធផលហិរញ្ញវត្ថុសង្ខេប

**របាយការណ៍ហិរញ្ញវត្ថុសង្ខេប ( ដុល្លារអាមេរិក )**

| ទ្រព្យសកម្ម | ២០១៧ | ២០១៨ | ២០១៨-CIFRS | ២០១៩-CIFRS |
|---|---|---|---|---|
| ឥណទានផ្តល់ដល់អតិថិជនសរុប | ៥៦៧.៥៣៦.២០២ | ៧៤៧.០០៥.០៦៤ | ៧៤១.៨៣៩.០២៨ | ១.០៣៦.២៧២.៩៣០ |
| ទ្រព្យសកម្មសរុប | ៦៩១.០០៧.៥៧៣ | ៩១៩.៧៥៣.៥០៩ | ៩២៥.០៧៨.៥៨៥ | ១.២២៦.៨៣៣.៤៦៩ |

| បំណុល | | | | |
|---|---|---|---|---|
| ប្រាក់បញ្ញើអតិថិជន | ៣៦៧.៤២១.០៧៩ | ៤៨០.០៩៣.៥៤១ | ៤៩១.៣៥៣.៣៩០ | ៦១០.០៩៩.៣២៧ |
| បំណុលសរុប | ៥៨៥.៦១៦.៨៨៦ | ៧៤៨.៥៩៣.៣៩៤ | ៧៥៨.៨៣៤.២៣២ | ១.០២៨.៤៦៣.៩៧២ |

| មូលធន | | | | |
|---|---|---|---|---|
| មូលធនសរុប | ១០៥.៣៩០.៦៨៧ | ១៧១.១៦០.១១៥ | ១៦៦.២៤៤.៣៥៣ | ១៩៨.៣៦៩.៤៩៧ |

| ចំណូល និងចំណាយ | | | | |
|---|---|---|---|---|
| ចំណូលការប្រាក់ | ៩៤.៩៩៦.៦៥៤ | ១១៤.៩៧០.៥៤៣ | ១១០.៥៩៤.៩៤៧ | ១៤១.៩៦០.៦៣១ |
| ចំណាយការប្រាក់ | (៣៨.៥៥៥.៧៨៤) | (៤៦.៨២១.៣៤៨) | (៤៦.៨៩៧.០៧៧) | (៥៩.៤៩៧.៤៧០) |
| ពន្ធលើប្រាក់ចំណេញ | (៤.១១៤.២៣០) | (៥.២៨៧.២៥៨) | (៤.៨០៧.៧៧៣) | (៣.៣៧៦.៤៨៨) |
| ប្រាក់ចំណេញសុទ្ធប្រចាំឆ្នាំ | ១៥.៣៥៦.១៥៩ | ២០.៧៦៩.៤២៨ | ១៨.៨៥១.៤៨៨ | ៣២.១២៥.១៤៤ |

# គ. ធុរកិច្ចសង្គមសង្ខេប

| ទំនួលខុសត្រូវអតិថិជន | ២០១៧ | ២០១៨ | ២០១៩ |
|---|---|---|---|
| អតិថិជនកម្ចីស្ត្រី | ៦៦,00% | ៦៤,00% | ៦២,00% |
| អតិថិជនសន្សំស្ត្រី | ៦៤,00% | ៦២,00% | ៦0,00% |
| ដែនគ្របដណ្តប់ជនបទសម្រាប់អតិថិជនកម្ចី | ៨២,00% | ៨២,00% | ៨៣,00% |
| អត្រាថែរក្សាអតិថិជន | ៧៩,00% | ៧៩,00% | ៨២,00% |
| ការត្រួតពិនិត្យប្រវត្តិឥណទានតាមរយៈ CBC | ១00,00% | ១00,00% | ១00,00% |
| ចំនួនអ្នកប្រើប្រាស់សេវាធានារ៉ាប់រងខ្នាតតូច | ១៥,២៧0 | ៣៨,0៣៥ | ២៤,៣៥៧ |
| ចំនួនឥណទាន SME | ៧៨៨ | ៩0៣ | ១,១៤៥ |
| អត្រាអតិថិជនមានចំណូល ២,៥ ដុល្លារ ក្នុងមួយថ្ងៃ | ២២,00% | ២១,00% | ២0,00% |

| ទំនួលខុសត្រូវចំពោះបុគ្គលិក | | | |
|---|---|---|---|
| អត្រាបុគ្គលិកស្ត្រី | ២៩,៩៩% | ២៨,៤២% | ២៥,៨១% |
| អត្រាថែរក្សាបុគ្គលិក | ៩១,៥៣% | ៨៨,៨៧% | ៩0,00% |
| រយៈពេលបំពេញការងារជាមធ្យមរបស់បុគ្គលិក (ឆ្នាំ) | ៣,៥១ | ៣,៧១ | ៣,៤៧ |
| ចំនួនវគ្គបណ្តុះបណ្តាលសម្រាប់បុគ្គលិកម្នាក់ | ៦ | ២៤ | ២៩ |

| ទំនួលខុសត្រូវចំពោះរដ្ឋាភិបាល * | | | |
|---|---|---|---|
| ពន្ធលើប្រាក់បៀវត្ស និងអត្ថប្រយោជន៍បន្ថែម | ១.៤២៣.៣៨១ | ១.៣៣៥.១១២ | ១.៤៩២.១៨0 |
| ពន្ធកាត់ទុក | ៣.៧៥៦.៦១១ | ៣.៩៩២.៩៨៣ | ៣.៧៦២.៤៤៧ |
| ពន្ធលើប្រាក់ចំណេញ | ៤.៣៣៦.៩0៩ | ៤.៨៨៣.៦៣៣ | ៤.0៤0.៥0៧ |
| * យោងតាមតួលេខរាយការណ៍ជូនអគ្គនាយកដ្ឋានពន្ធដារ | | | |




# ឃ. ដៃគូអាជីវកម្ម

កាន់តែពិសេសសម្រាប់អតិថិជនរបស់ ហត្ថាកសិករ នោះគឺ រាល់ការទទួលទាន ទិញទំនិញ ឬប្រើប្រាស់សេវាកម្មណាមួយរបស់ដៃគូអាជីវកម្មរបស់យើង អតិថិជនគ្រាន់តែបង្ហាញ ប័ណ្ណអេធីអឹម (ATM Card) របស់ ហត្ថាកសិករ នឹងទទួលបានការបញ្ចុះតម្លៃភ្លាមៗ ដែលការផ្តល់ជូននេះមានរហូតដល់ ៥0% នៃតម្លៃធម្មតា។

សូមបញ្ជាក់បន្ថែមថា គិតត្រឹមដំណាច់ឆ្នាំ ២០១៩ ដោយមានការចាប់អារម្មណ៍ខ្ពស់ក្នុងសហការធ្វើជាដៃគូអាជីវកម្មពីតាមបណ្តាហាងនានាទូទាំងប្រទេស ហត្ថាកសិករ មានដៃគូអាជីវកម្មក្នុងការសហការបញ្ចុះតម្លៃទៅកាន់អតិថិជនរបស់ខ្លួនសរុបចំនួនជាង ៦0 កន្លែង ដែលមកពីវិស័យផ្សេងៗគ្នា ក្នុងនោះរួមមាន ដូចជា យានដ្ឋាន ភោជនីយដ្ឋាន ហាងភេសជ្ជៈ កាហ្វេ ក្លឹបហាត់ប្រាណ គ្លីនិកភ្នែក គ្លីនិកធ្មេញ ហាងលក់ទូរស័ព្ទ សាលារៀនបើកបរ សណ្ឋាគារ ផ្ទះសំណាក់ មជ្ឈមណ្ឌលនាឡិកាដៃ ហាងលក់សំលៀកបំពាក់ ហាងលក់កាបូប ហាងលក់គ្រឿងអលង្ការ និងហាងជាច្រើនផ្សេងទៀត។




## ង. ការិយាល័យ និងបណ្ដាញចែកចាយ

**២៥**
ខេត្ត/ក្រុង

**០១**
ការិយាល័យកណ្ដាល

**១៧៧**
សាខា

**១៣៧**
ម៉ាស៊ីនអេធីអឹម




# ច. ព័ត៌មានទូទៅរបស់ ហត្ថាកសិករ លីមីតធីត

## អំពី ហត្ថាកសិករ លីមីតធីត

ហត្ថាកសិករ គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើសន្សំពីសាធារណជនធំមួយ ដែលបានទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា និងបានធ្វើប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជាជាង ២៦ឆ្នាំ មកហើយ។ ហត្ថាកសិករ បាននឹងកំពុងផ្តល់សេវាកម្មហិរញ្ញវត្ថុយ៉ាងសម្បូរបែបដល់អតិថិជនដូចជា៖ សេវាឥណទាន សេវាប្រាក់បញ្ញើសន្សំ សេវាផ្ទេរប្រាក់ក្នុងស្រុក សេវាអេធីអឹម សេវាធនាគារចល័ត សេវាបើកប្រាក់បៀវត្ស និងជាភ្នាក់លក់សេវាធានារ៉ាប់រងផងដែរ។ តាមរយៈសាខា និងម៉ាស៊ីន អេធីអឹម យ៉ាងទូលំទូលាយនៅទូទាំងប្រទេស។

បច្ចុប្បន្ន ហត្ថាកសិករ លីមីតធីត គឺជាបុត្រសម្ព័ន្ធរបស់ធនាគារក្រុងស្រ៊ី ដែលជាធនាគារពាណិជ្ជធំជាងគេលំដាប់ទី ៥ នៅព្រះរាជាណាចក្រថៃឡង់ដ៍ និងជាសមាជិករបស់សម្ព័ន្ធហិរញ្ញវត្ថុអន្តរជាតិ Mitsubishi UFJ Financial Group (MUFG) ដែលជាសម្ព័ន្ធហិរញ្ញវត្ថុធំជាងគេបំផុតនៅប្រទេសជប៉ុន ព្រមទាំងជាសម្ព័ន្ធសេវាហិរញ្ញវត្ថុដ៏ធំមួយក្នុងចំណោមសម្ព័ន្ធហិរញ្ញវត្ថុធំជាងគេលើសកលលោក។



# ទស្សនវិស័យ បេសកកម្ម និងតម្លៃស្នូល

## ទស្សនវិស័យ

ជាគ្រឹះស្ថានហិរញ្ញវត្ថុដែលទទួលបាន ការកោតសរសើរខ្ពស់និងជាជម្រើសដែលអតិថិជនពេញចិត្ត តាមរយៈបុគ្គលិកប្រកបដោយវិជ្ជាជីវៈ។

## បេសកកម្ម

យើងផ្តល់ជូនអតិថិជននូវដំណោះស្រាយហិរញ្ញវត្ថុ ដែលគួរឱ្យជឿទុកចិត្ត ងាយស្រួលនិងប្រកបដោយ ភាពច្នៃប្រឌិត តាមរយៈបច្ចេកវិទ្យាឌីជីថលដែលនាំមកនូវបទពិសោធន៍ល្អៗដល់អតិថិជន។ យើងប្តេជ្ញាចូលរួមចំណែកដល់ការរីកចម្រើនរបស់អតិថិជន និងសង្គម ប្រកបដោយចេរភាព។

## តម្លៃស្នូល

### ស្មោះត្រង់

យើងប្តេជ្ញាធ្វើអ្វីដែលល្អប្រកបទៅដោយភាពស្មោះត្រង់ ត្រឹមត្រូវ តម្លាភាព ទទួលខុសត្រូវ និងវិជ្ជាជីវៈ។

### ឧត្តមភាព

យើងបានប្តេជ្ញាធ្វើការងារប្រកបដោយឧត្តមភាព ជាមួយកម្រិតបទដ្ឋានកាន់តែខ្ពស់ ហើយយើងចាប់យកការផ្លាស់ប្តូរ និងភាពច្នៃប្រឌិតផ្នែកបច្ចេកវិទ្យាដើម្បីក្លាយជា អ្នកនាំមុខមួយក្នុងទីផ្សារ។

### គាំពារ

យើងជួយ និងយកចិត្តទុកដាក់ចំពោះអតិថិជនតាមរយៈ ការធ្វើការរួមគ្នាដើម្បីការកសាងអនាគតឲ្យកាន់តែប្រសើរ។

### ថាមវន្ត

យើងមានសុទិដ្ឋិនិយម និងសេចក្តីស្វាហាប់ដើម្បីដឹកនាំ និងធ្វើការរួមគ្នាក្នុងបរិយាកាសបើកទូលាយដើម្បីសម្រេចគោលដៅរបស់យើង។

### សាមញ្ញ

យើងធ្វើអ្វីៗឲ្យមានលក្ខណៈសាមញ្ញ ងាយស្រួល និងសមស្របសម្រាប់អតិថិជនដោយផ្អែកលើតម្រូវការរបស់ពួកគាត់ជាអាទិភាព។

# ប្រវត្តិ ហត្ថាកសិករ លីមីតធីត

## ១៩៩៤

គម្រោងសន្តិសុខស្បៀងមួយដែលត្រូវបានបង្កើតឡើងដោយ OCSD/OXFAM-Quebec ដែលជាអង្គការរបស់ ប្រទេស កាណាដា បានផ្តល់ឥណទានខ្នាតតូចដល់ប្រជាពលរដ្ឋនៅតាមតំបន់ជនបទក្នុងឃុំចំនួន ៤ នៃខេត្តពោធិ៍សាត់។

## ១៩៩៦

គម្រោងសន្តិសុខស្បៀងបានចុះបញ្ជី នៅក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជាជាអង្គការក្រៅរដ្ឋាភិបាល ដែលមានឈ្មោះថា "ហត្ថាកសិករ" ដែលជាភាសាខ្មែរមានន័យថា ដៃរបស់កសិករ ឬជាដៃសម្រាប់ជួយកសិករ។ នៅពេលនោះការិយាល័យកណ្តាលរបស់អង្គការ ហត្ថាកសិករ គឺស្ថិតនៅក្នុងខេត្តពោធិ៍សាត់។

## ២០០១

អង្គការហត្ថាកសិករ បានចុះបញ្ជីនៅឯក្រសួងពាណិជ្ជកម្មដោយមានដើមទុនសរុបចំនួន ៧៧.៨៥០ ដុល្លារអាមេរិក ដោយផ្លាស់ប្តូរពីអង្គការក្រៅរដ្ឋាភិបាលទៅជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ដែលមានឈ្មោះថ្មីថា "ហត្ថាកសិករ លីមីតធីត"។ នៅក្នុងពេលជាមួយគ្នានោះដែរ ហត្ថាកសិករ លីមីតធីត បានទទួលអាជ្ញាប័ណ្ណរយៈពេល ៣ឆ្នាំ ពីធនាគារជាតិនៃកម្ពុជា ដើម្បីប្រតិបត្តិការសេវាកម្មមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា។

## ២០០៧

សេវាកម្មប្រាក់បញ្ញើសន្សំនិងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់បម្រើឱ្យសេវាកម្មនេះត្រូវបានដាក់ឱ្យប្រើប្រាស់ដើម្បីត្រួតពិនិត្យ និងគ្រប់គ្រងទៅលើប្រតិបត្តិការ។ ទន្ទឹមនឹងគ្នានោះដែរ ហត្ថាកសិករ បានបង្កើននូវដើមទុនចុះបញ្ជីរបស់ខ្លួនពី ២៥៧.៨៥០ រហូតដល់ ១.៣៣៩.៧០០ ដុល្លារអាមេរិក។ ដោយសារតែ ហត្ថាកសិករ មាននិរន្តរភាព ផ្នែកហិរញ្ញវត្ថុ ប្រតិបត្តិការ និងអភិបាលកិច្ចល្អ ធនាគារជាតិនៃកម្ពុជា ក៏បានផ្តល់អាជ្ញាប័ណ្ណគ្មានកាលកំណត់ សម្រាប់ប្រតិបត្តិការសេវាមីក្រូហិរញ្ញវត្ថុដល់ហត្ថាកសិករ ។

## ២០១០

ធនាគារជាតិនៃកម្ពុជាបានសម្រេចផ្តល់នូវអាជ្ញាប័ណ្ណ ប្រកបអាជីវកម្មដែលទទួលប្រាក់បញ្ញើពីសាធារណជន (MDI-License) ដល់ ហត្ថាកសិករ លីមីតធីត។ ការទទួលអាជ្ញាប័ណ្ណនេះ សបញ្ជាក់ឱ្យឃើញពីភាពជោគជ័យមួយក្នុងចំណោមភាពជោគជ័យជាច្រើនរបស់ ហត្ថាកសិករ លើការផ្តល់សេវាកម្មហិរញ្ញវត្ថុដល់អតិថិជនពិសេសអនុញ្ញាតឱ្យហត្ថាកសិករ កៀនប្រមូលប្រាក់បញ្ញើពីសាធារណជន។ លើសពីនេះផ្នែកព័ត៌មានវិទ្យាបានបំពាក់ប្រព័ន្ធស្នូលធនាគារថ្មី ដើម្បីធ្វើយ៉ាងណាឱ្យការបម្រើសេវាកម្មអតិថិជន និងសកម្មភាពប្រតិបត្តិការ កាន់តែមានប្រសិទ្ធភាពថែមទៀត គាំទ្រយុទ្ធសាស្ត្ររបស់ក្រុមហ៊ុនក្នុងការកម្លាយ ខ្លួនជាធនាគារពាណិជ្ជនាពេលអនាគត។

## ២០១២

ហត្ថាកសិករ លីមីតធីត បានដាក់ឱ្យប្រើប្រាស់ ប្រកបដោយភាពជោគជ័យនូវប្រព័ន្ធស្នូលធនាគារថ្មីនៅគ្រប់ បណ្តាញការិយាល័យប្រតិបត្តិការទាំងអស់។ ប្រព័ន្ធស្នូលធនាគារថ្មីនេះបានបង្កើនប្រសិទ្ធភាព និងផលិតភាពការងារអាជីវកម្ម កាន់តែប្រសើរឡើង។ បន្ថែមពីនេះហត្ថាកសិករ បានវិនិយោគជិត ២ លានដុល្លារអាមេរិក លើគម្រោងបង្កើតឱ្យមានសេវាអេធីអឹម និងប្រព័ន្ធធនាគារចល័តសម្រាប់អតិថិជន ។ ការវិនិយោគទៅលើបច្ចេកវិទ្យាទំនើបនេះ គឺដើម្បីឱ្យកាន់តែមានភាពសម្បូរបែបនូវសេវាហិរញ្ញវត្ថុសម្រាប់អតិថិជន និងដើម្បីបង្កើននូវប្រសិទ្ធភាពនៃ ការបម្រើសេវាអតិថិជនឱ្យកាន់តែរហ័សទាន់ចិត្ត និងមានភាពងាយស្រួលក្នុង ការធ្វើប្រតិបត្តិការសាច់ប្រាក់ តាមរយៈម៉ាស៊ីនអេធីអឹមដក-ដាក់ប្រាក់ និងសេវាធនាគារចល័តរបស់ ហត្ថាកសិករ លីមីតធីត។ ជាមួយនឹងម៉ាស៊ីនអេធីអឹមដ៏ទំនើបដែលមិនធ្លាប់មាន និងប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា និងប្រព័ន្ធធនាគារចល័ត អតិថិជនអាចធ្វើប្រតិបត្តិការហិរញ្ញវត្ថុបានច្រើនយ៉ាងដូចជា ដកប្រាក់ ដាក់ប្រាក់ ផ្ទេរប្រាក់ ប្តូរប្រាក់ព្រមទាំងទិញកាតទូរស័ព្ទតាមតម្រូវការ។ ម៉ាស៊ីនអេធីអឹមដ៏ទំនើបនេះបានដាក់ទៅឱ្យអតិថិជន និងសាធារណជនប្រើប្រាស់ ជាផ្លូវការនៅចុងឆ្នាំ ២០១២ កន្លងទៅនេះ។

## ២០១៤

ហត្ថាកសិករ លីមីតធីត ក៏បានបង្កើននូវដើមទុនចុះបញ្ជីរបស់ខ្លួនពីចំនួន ៤.០៣៦.៨០០ ដុល្លារអាមេរិក ទៅដល់ចំនួន ៥.២៧១.១៨៨ ដុល្លារអាមេរិក ជាមួយធនាគារជាតិនៃកម្ពុជា។ ដើមទុនថ្មីនេះ ធ្វើឱ្យ ហត្ថាកសិករ លីមីតធីត មានលទ្ធភាពពង្រីកប្រតិបត្តិការអាជីវកម្មរបស់ខ្លួននៅទូទាំងប្រទេស។

## ២០១៦

ហត្ថាកសិករ លីមីតធីត ក្លាយជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារក្រុងស្រី ដែលជាធនាគារធំជាងគេលំដាប់ទី៥ នៃព្រះរាជាណាចក្រថៃ និងជាសមាជិកនៃសម្ព័ន្ធហិរញ្ញវត្ថុអន្តរជាតិ Mitsubishi UFJ Financial Group (MUFG) ដែលជា សម្ព័ន្ធក្រុមហ៊ុនផ្តល់សេវាកម្មហិរញ្ញវត្ថុធំបំផុតរបស់ប្រទេសជប៉ុន និងជាក្រុមសម្ព័ន្ធពហុហិរញ្ញវត្ថុ ធំបំផុតមួយក្នុងពិភពលោក។

## ២០១៧

ហត្ថាកសិករ លីមីតធីត ក៏បានបង្កើនដើមទុនចុះបញ្ជីរបស់ខ្លួន រហូតដល់ ២១,៨ លានដុល្លារអាមេរិក នៅក្នុងខែ មីនា ឆ្នាំ ២០១៧។ នៅក្នុងខែកញ្ញា ឆ្នាំ ២០១៧ ហត្ថាកសិករ បានទទួលដើមទុនចុះបញ្ជី ចំនួន ៨,២លានដុល្លារអាមេរិក បន្ថែមទៀតពីធនាគារ ក្រុងស្រី ដែលធ្វើឱ្យដើមទុនចុះបញ្ជីរបស់ខ្លួនកើនដល់ ៣០លានដុល្លារអាមេរិក។

## ២០១៨

នៅខែ សីហា ឆ្នាំ ២០១៨ ហត្ថាកសិករ បានទទួលដើមទុនបន្ថែមទៀត ចំនួន ៤៥ លានដុល្លារអាមេរិក ពីធនាគារក្រុងស្រី ដើម្បីពង្រឹងដើមទុនចុះបញ្ជីរបស់ខ្លួនដល់ ៧៥ លានដុល្លារអាមេរិក។ ក្នុងឆ្នាំ ២០១៨ នេះដែរ ហត្ថាកសិករ ក៏បានបោះផ្សាយសញ្ញាប័ណ្ណសាជីវកម្មដំបូងបំផុតនៅកម្ពុជាចំនួន ១២០ ប៊ីលានរៀល ដែលជាព្រឹត្តិការណ៍មួយសំខាន់គួរឱ្យចាប់អារម្មណ៍មួយសម្រាប់ទីផ្សារមូលធននៅកម្ពុជា។

## ២០១៩

បានទទួលដើមទុនបន្ថែមទៀតពី ធនាគារក្រុងស្រី ដើម្បីពង្រឹងដើមទុនចុះបញ្ជីរបស់ខ្លួនដល់ ១១៥ លានដុល្លារអាមេរិក។ និងបង្កើនផលបត្រឥណទានរហូតដល់ច្រើនជាង ១០០០ លានដុល្លារអាមេរិក ទៅកាន់អតិថិជនច្រើនជាង ១៥០.០០០ នាក់។

# សារប្រធានក្រុមប្រឹក្សាភិបាល



**លោក Dan HARSONO**
**ប្រធានក្រុមប្រឹក្សាភិបាល**

ឆ្នាំ ២០១៩ គឺជាឆ្នាំដ៏គួរឱ្យរំភើបរីករាយសម្រាប់យើងទាំងអស់គ្នា នោះគឺវឌ្ឍនភាពនៅក្នុងក្រុមហ៊ុនក្រុងស៊ីគ្រុបទាំងមូលនៅគ្រប់តំបន់ដែលយើងបានទៅដល់ ក៏ដូចជាការរួមចំណែកធ្វើឱ្យប្រទេសកម្ពុជាទទួលបានភាពរីកចម្រើនកាន់តែខ្លាំងក្លាតាមរយៈ ហត្ថាកសិករ លីមីតធីត ដែលបានបម្រើប្រជាជនកម្ពុជាយ៉ាងជោគជ័យនាពេលកន្លងមក។

តាមរយៈក្រុមហ៊ុនយើង យើងបានធ្វើឱ្យមានការផ្លាស់ប្រែវិជ្ជមានជាច្រើននៅក្នុងវិស័យហិរញ្ញវត្ថុ និងជីវិតរស់នៅរបស់ប្រជាជនរាប់លាននាក់តាមរយៈ ការចូលរួមចំណែកក្នុងការផ្លាស់ប្តូរនូវស្ថានភាពអាជីវកម្ម ក៏ដូចជាស្តង់ដាររស់នៅរបស់ប្រជាជនយើងឱ្យកាន់តែល្អប្រសើរ។ គ្រប់ភាគីទាំងអស់ត្រូវបានផ្សារភ្ជាប់ទំនាក់ទំនងគ្នាកាន់តែល្អប្រសើរ ដោយបានជំរុញឱ្យក្រុមហ៊ុនចាប់អាម្មណ៍បង្កើនសក្តានុពលរបស់ខ្លួនទាំងក្នុងតំបន់ និងលើឆាកអន្តរជាតិ ក៏ដូចជាការដាក់បញ្ចូលនូវបច្ចេកវិទ្យាឌីជីថលក្នុងសកម្មភាពអាជីវកម្ម ដើម្បីសម្រេចបាននូវប្រសិទ្ធភាពក្នុងប្រតិបត្តិការអាជីវកម្ម កាត់បន្ថយចំណាយ និងជាពិសេសគឺការផ្តល់ការបម្រើសេវាអតិថិជនដ៏ល្អប្រសើរ។

នៅឆ្នាំ ២០១៩ ហត្ថាកសិករ បានពង្រឹងជំហររបស់ខ្លួនក្នុងនាមជាស្ថាប័នឈានមុខគេលើទីផ្សារ ជាមួយបណ្តាញការិយាល័យរហូតដល់ ១៧៧ សាខា និងម៉ាស៊ីនអេធីអឹម ១៣៧ ទូទាំងប្រទេស។ យើងបានបង្កើនផលបត្រប្រាក់កម្ចីរហូតដល់ជាង ១ ពាន់លានដុល្លារអាមេរិក ជាមួយនឹងអត្រាឥណទានស្ថិតក្នុងកម្រិតហានិភ័យទាបបំផុតបើធៀបទៅនឹងស្ថាប័នរួមវិស័យរបស់យើង។ ការកើនឡើងនៃផ្នែកហិរញ្ញវត្ថុគួបផ្សំនឹងការគ្រប់គ្រងផ្ទៃក្នុងដែលរឹងមាំធ្វើឱ្យ ហត្ថាកសិករ សម្រេចបាននូវលទ្ធផលប្រាក់ចំណេញខ្ពស់គួរជាទីគាប់ចិត្ត។ វាគឺជាឆ្នាំដែលប្រកបដោយផលិតភាព ការងារ ជាមួយនឹងការអភិវឌ្ឍថ្មីៗ និងធ្វើឱ្យកាន់តែប្រសើរឡើង ដើម្បីឆ្ពោះទៅរកការបម្រើអតិថិជន ដ៏ល្អដើម្បីឆ្លើយតបទៅនឹងទីផ្សារប្រកួតប្រជែងនាពេលបច្ចុប្បន្ន។

ហត្ថាកសិករ នឹងបន្តឆ្នាំ ២០២០ ជាមួយនឹងផែនការអាជីវកម្មរយៈពេលមធ្យម (MTBP) បច្ចុប្បន្នរបស់ខ្លួនដែលបង្ហាញពីយុទ្ធសាស្ត្រ និងទិសដៅអាជីវកម្មដើម្បីប្រែក្លាយខ្លួនទៅជាស្ថាប័នដែលមានស្តង់ដារខ្ពស់ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជននាយុគសម័យបច្ចុប្បន្ន ការវិវត្តនៃបច្ចេកវិទ្យា បង្កើនប្រសិទ្ធភាពនៃការគោរពបទប្បញ្ញត្តិ និងបង្កើនផលិតភាពក្នុងការប្រកួតប្រជែង។

យើងនឹងផ្តោតការយកចិត្តទុកកាន់តែខ្ពស់បន្ថែមទៀតលើការផ្តល់ជូននូវបទពិសោធន៍ដែលគួរឱ្យចងចាំទៅកាន់អតិថិជន ប្រសិទ្ធភាពការគ្រប់គ្រងផ្ទៃក្នុង និងការទទួលយកបច្ចេកវិទ្យាឌីជីថលដើម្បីពង្រឹងអាជីវកម្ម និងការផ្តល់ជូនសេវារបស់យើង។ ការកែលម្អទាំងអស់នេះគឺក្នុងគោលបំណងធ្វើឱ្យ ហត្ថាកសិករ បោះជំហានទៅជាធនាគារពាណិជ្ជដែល ត្រូវបានទទួលស្គាល់ថាមានស្តង់ដារខ្ពស់ជាងគេ។

ជាមួយនឹងទស្សនៈវិជ្ជមាន ខ្ញុំជឿជាក់ថាប្រទេសកម្ពុជា នៅក្នុងឆ្នាំ ២០២០ នេះ នឹងបន្តជាទិសដៅទាក់ទាញ ក្នុងការវិនិយោគពីបរទេសកាន់តែច្រើន និងក្លាយជាទឹកដី ដែលពោរពេញទៅដោយក្តីសង្ឃឹម និងស្ថិរភាព ដូចដែលបានបង្ហាញរួចមកហើយដោយកំណើននៃសេដ្ឋកិច្ចក្នុងរយៈពេល ពីទសវត្សរ៍កន្លងមកនេះម៉្យាងវិញទៀតចំពោះកត្តាហានិភ័យសំខាន់ៗ ដូចជាសង្គ្រាមពាណិជ្ជកម្មរវាងអាមេរិក និងចិន និងការដក EBA ដែលអាចកើតមានយើងបានត្រួតពិនិត្យយ៉ាងដិតដល់ ដើម្បីធានាបាននូវយុទ្ធសាស្ត្រ និងការអនុវត្តត្រឹមត្រូវ ចំពោះអាជីវកម្មរបស់យើង។

ទោះយ៉ាងនេះក្តី ខ្ញុំជឿជាក់ថាសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានឹងនៅតែបន្តរីកចម្រើន ហើយយើងនឹងធ្វើការរួមគ្នាជាមួយរាជរដ្ឋាភិបាលកម្ពុជា និយ័តករ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ក្នុងការធ្វើឱ្យក្រុមហ៊ុនក៏ដូចជាអតិថិជនរបស់យើងនៅទូទាំងប្រទេសកាន់តែទទួលបានការរីកចម្រើន ។

ថ្ងៃអង្គារ ៦កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

លោក Dan HARSONO,
ប្រធានក្រុមប្រឹក្សាភិបាល

# សារប្រធានអគ្គនាយក



## លោកឧកញ៉ា ហួត អៀងតុង
**ប្រធានអគ្គនាយក**

ក្នុងអំឡុងពេញមួយឆ្នាំ ២០១៩ នេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត បានរួបរួមសាមគ្គីគ្នាប្រឹងប្រែងបំពេញការងារមិនខ្លាចនឿយហត់ពីសំណាក់បុគ្គលិក និងគណៈគ្រប់គ្រង ជាមួយនឹងការគាំទ្រពីម្ចាស់ភាគហ៊ុនគឺ ធនាគារ ក្រុងស្រី ដែលជាធនាគារឈានមុខគេមួយនៅក្នុងប្រទេសថៃ និងជាសមាជិករបស់ MUFG ក្នុងការធ្វើឱ្យគ្រឹះស្ថាននេះ ត្រៀមខ្លួនរួចជាស្រេច សម្រាប់ការក្លាយខ្លួនទៅជាធនាគារពាណិជ្ជទាំងធនធានមនុស្ស ដើមទុន សេវាកម្មធនាគារ និងបច្ចេកវិទ្យាព័ត៌មាន ដើម្បីបម្រើសេវាកម្ម និងផលិតផលហិរញ្ញវត្ថុប្រកបដោយវិជ្ជាជីវៈ ភាពសច្ចៈ ស្មោះត្រង់ និងសាមញ្ញ ជាមួយនឹងទស្សនវិស័យឌីជីថលកាន់តែទំនើបជូនអតិថិជន។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត សូមប្រកាសបង្ហាញសមិទ្ធផលគិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ មានជាអាទិ៍៖

- ការដាក់ឱ្យដំណើរការផលិតផលឥណទានថ្មី FIRST CHOICE ក្នុងខែ កក្កដា ឆ្នាំ ២០១៩ សម្រាប់អតិថិជនយកឥណទានទៅទិញ ឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ ទូរស័ព្ទចល័ត និងផលិតផលអេឡិចត្រូនិក បានកាន់តែងាយស្រួល។
- បានបង្កើនដើមទុនចុះបញ្ជីរហូតដល់ ១១៥ លានដុល្លារអាមេរិក ដើម្បីពង្រឹងដើមទុនឱ្យកាន់តែរឹងមាំសម្រាប់ត្រៀមខ្លួនជាស្រេចដើម្បីក្លាយទៅជាធនាគារពាណិជ្ជ។
- បានលើកកម្ពស់ការយល់ដឹងចំពោះទស្សនវិស័យ បេសកកម្ម តម្លៃឈ្នូល និងអត្តសញ្ញាណថ្មីរបស់ក្រុមហ៊ុនដល់បុគ្គលិកតាមរយៈយុទ្ធនាការឈ្មោះខ្ញុំស្រលាញ់ ហត្ថាកសិករ (I LOVE HKL)។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត មានបណ្តាញប្រតិបត្តិការចំនួន ១៧៧សាខា ជាមួយនឹងម៉ាស៊ីនអេធីអឹមចំនួន ១៣៧ នៅទូទាំងប្រទេស។ បុគ្គលិកសរុបមាន ៤.៣៨២ នាក់ កំពុងផ្តល់ជូនសេវាកម្មហិរញ្ញវត្ថុដ៏ល្អបំផុត តាមរយៈបណ្តាញសាខាយ៉ាងធំទូលំទូលាយទូទាំងផ្ទៃប្រទេស។

គោលដៅសម្រាប់ឆ្នាំ ២០២០ គ្រឹះស្ថានមីក្រូហិរញ្ញ-វត្ថុ ហត្ថាកសិករ លីមីតធីត គ្រោងដាក់បន្ថែមសេវាថ្មីនៅក្នុងផលិតផលធនាគារចល័ត ការផ្លាស់ប្តូរពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទទួលប្រាក់បញ្ញើ ទៅជាធនាគារ ហត្ថា ដើម្បីបម្រើសសេវាកម្មជូនអតិថិជនឱ្យកាន់តែបានទូលំទូលាយ ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ នាយុគសម័យឌីជីថល។

ក្នុងនាមជាអ្នកដឹកនាំ និងថ្នាក់គ្រប់គ្រងមួយរូប ខ្ញុំក៏សូមថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅទៅដល់គណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់ ដែលបានប្តេជ្ញាចិត្តធ្វើឱ្យ សម្រេចសមិទ្ធផលដ៏អស្ចារ្យនេះ។

ខ្ញុំក៏សូមកោតសរសើរ និងដឹងគុណចំពោះទំនុកចិត្ត និងការគាំទ្រពីសំណាក់អតិថិជន ដៃគូអាជីវកម្ម និងសាធារណជន ហើយខ្ញុំសង្ឃឹម និងជឿជាក់ថា ហត្ថាកសិករ នឹងនៅតែបន្តផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុស្តង់ដារខ្ពស់បំផុតក្នុងនៅ រយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ។

ថ្ងៃអង្គារ ៦កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩



លោកឧកញ៉ា ហួត អៀងតុង
ប្រធានអគ្គនាយក




# ឆ. ទិដ្ឋភាពលើសកម្មភាពអាជីវកម្ម

## ភាគហ៊ុនិក

ក្រុងស្រ៊ី (ធនាគារអយុធ្យា ម.ក និងបុត្រសម្ព័ន្ធរបស់ខ្លួន) ជាក្រុមហ៊ុនហិរញ្ញវត្ថុធំជាងគេលំដាប់ទី៥ នៅប្រទេសថៃ លើទ្រព្យសកម្ម ប្រាក់កម្ចី និងប្រាក់បញ្ញើ និងជាធនាគារមួយក្នុងចំណោមធនាគារសំខាន់ៗក្នុងស្រុកទាំង៥ របស់ប្រទេសថៃ ដែលមានប្រវត្តិ ៧៤ ឆ្នាំនៅក្នុងប្រទេសនេះ។ ធនាគារក្រុងស្រ៊ី ជាសមាជិកយុទ្ធសាស្រ្តនៃ Mitsubishi UFJ Financial Group (MUFG) ដែលជាសម្ព័ន្ធក្រុមហ៊ុនហិរញ្ញវត្ថុធំជាងគេបំផុតរបស់ប្រទេសជប៉ុន និងជាស្ថាប័នហិរញ្ញវត្ថុធំជាងគេមួយនៅលើពិភពលោក។ ធនាគារក្រុងស្រ៊ី ផ្តល់សេវាកម្មធនាគារដ៏សម្បូរបែប សេវាហិរញ្ញវត្ថុប្រើប្រាស់ផ្ទាល់ខ្លួន ការវិនិយោគ ការគ្រប់គ្រងទ្រព្យសម្បត្តិ និងផលិតផល និងសេវាកម្មហិរញ្ញវត្ថុផ្សេងៗទៀត ជូនដល់អតិថិជន សហគ្រាសធុនតូច និងមធ្យម និងក្រុមហ៊ុនសាជីវកម្មធំៗ តាមរយៈបណ្តាញសាខាចំនួន ៦៩០ កន្លែង (សាខាធនាគារចំនួន ៦៥០ កន្លែង និងសាខាអាជីវកម្មយានយន្តចំនួន ៤០ កន្លែង) ព្រមទាំងតាមរយៈកន្លែងផ្តល់សេវាកម្មជាង ៣៤.៩០២ កន្លែងទៀតនៅទូទាំងប្រទេស។ សម្ព័ន្ធក្រុមហ៊ុនហិរញ្ញវត្ថុក្រុងស្រ៊ី ជាក្រុមហ៊ុនចេញកាតឥណទានច្រើនជាងគេបំផុតនៅក្នុងប្រទេសថៃ ដែលបានចេញប័ណ្ណឥណទានចំនួន៩,១លានប័ណ្ណលើឥណទានទិញសំភារៈប្រើប្រាស់ដោយបង់រំលស់និងគណនីឥណទានប្រើប្រាស់ផ្ទាល់ខ្លួនក្នុងផលប័ត្រឥណទានរបស់ខ្លួន។ ក្រុមហ៊ុនផ្តល់កម្ចីទិញយានយន្តដ៏ធំគឺ Krungsri Auto ជាក្រុមក្រុមហ៊ុនគ្រប់គ្រងទ្រព្យសកម្ម ដែលមានការរីកចម្រើនយ៉ាងលឿនជាងគេមួយ(Krungsri Asset Management) និងក្រុមហ៊ុន មីក្រូហិរញ្ញវត្ថុ Ngern Tid Lor។

## ដៃគូហិរញ្ញវត្ថុ

ដើម្បីធានាបាននូវប្រភពដើមទុនដ៏រឹងមាំ យើងបានសាងទំនាក់ទំនងដ៏ល្អ ជាមួយនឹងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិល្បីៗជាច្រើនដូចជា៖

យើងខ្ញុំសូមថ្លែងអំណរគុណដល់វិនិយោគិន សញ្ញាបណ្ណ សាជីវកម្មរបស់យើង រួមមាន៖ ធនាគារវឌ្ឍនៈ ធនាគារ អេស៊ីលីដា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអាក់ទីវភីផលភីអិលស៊ី ធនាគារ កម្ពុជាពាណិជ្ជ ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រី" និង IFC។

# ក្រុមប្រឹក្សាភិបាល



**លោក Dan HARSONO**
**ប្រធានក្រុមប្រឹក្សាភិបាល**

លោក Dan គឺជាអនុប្រធានអគ្គនាយកប្រតិបត្តិជាន់ខ្ពស់នៃធនាគារក្រុងស្រី ។ ជាមួយបទពិសោធន៍ ដ៏ទូលំទូលាយរបស់លោកនៅក្នុងការគ្រប់គ្រងអាជីវកម្ម និងសេវាហិរញ្ញវត្ថុ ។ លោក Dan ធ្លាប់ទទួលបានមុខតំណែងសំខាន់ៗ ប្រចាំស្ថាប័នជាច្រើនរួមមាន អគ្គនាយកម៉ាឃីតធីង នាយក នាយកដ្ឋានម៉ាឃីតធីង និងលក់ នាយកនាយកដ្ឋាន ម៉ាឃីតធីង និងអភិវឌ្ឍអាជីវកម្មអន្តរជាតិ នាយក នាយកដ្ឋានម៉ាឃីតធីង និង ប្រេនដីង និងនាយក នាយកដ្ឋានសេវា ធនាគារផ្ទាល់ខ្លួនមុនពេលចូលមកកាន់តំណែងបច្ចុប្បន្ន។ លោក Dan បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ពីសាកលវិទ្យាល័យ Indiana។ ហើយបន្ថែមលើ បរិញ្ញាបត្រវិស្វកម្មអគ្គិសនី និងវិស្វកម្ម ជីវវេជ្ជសាស្ត្រពីសាកលវិទ្យាល័យ Southern California នៃរដ្ឋ Los Angeles, California។





**លោកឧកញ៉ា ហួត អៀងតុង**
**អភិបាល**

លោកឧកញ៉ា ហួត អៀងតុង គឺជាសហស្ថាបនិករបស់ ហត្ថាកសិករ លីមីតធីត ក្នុងឆ្នាំ ១៩៩៤ ហើយបានដឹកនាំស្ថាប័ននេះចាប់តាំងពីពេលនោះមក។ លោកឧកញ៉ា ហួត អៀងតុង មានបទពិសោធន៍ច្រើនជាង ៣០ឆ្នាំ លើវិស័យមីក្រូហិរញ្ញវត្ថុ ដែលជាកត្តាធ្វើឱ្យលោកក្លាយទៅជាប្រតិបត្តិករយ៉ាងប៉ិនប្រសប់ ទាំងក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុនៅក្នុងស្ថាប័ន។ បន្ទាប់ពីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រលើជំនាញកសិកម្មនៅឆ្នាំ ១៩៩១ លោកក៏បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតរដ្ឋបាលនិងគ្រប់គ្រងអាជីវកម្ម។ ពិសេសជាងនេះទៅទៀត លោកធ្លាប់ចូលរួមសិក្ខាសាលាជាច្រើន នៅក្រៅប្រទេសពាក់ព័ន្ធនឹងវិស័យមីក្រូហិរញ្ញវត្ថុ ដូចជានៅប្រទេសហ្វីលីពីន សហរដ្ឋអាមេរិក ឥណ្ឌូនេស៊ី បារាំង អាល្លឺម៉ង់ និងប្រទេសជាច្រើនទៀត។

**លោក Wanchairabin JITWATTANATAM**
**អភិបាល**

លោក Wanchairabin បានចូលបម្រើការងារនៅ ហត្ថាកសិករ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៦ ដោយនាំមកជាមួយនូវបទពិសោធ៍ ជំនាញវិជ្ជាជីវៈការងារចម្រុះជាង២០ឆ្នាំ លើវិស័យធនាគារនិងហិរញ្ញវត្ថុ ការប្រឹក្សាយោបល់ទៅលើការគ្រប់គ្រងទូទៅ និងជាពិសេសវិស័យវិស្វកម្មនៅក្នុងក្រុមហ៊ុនដែលសំខាន់ៗមួយចំនួនដូចជាធនាគារអយុធ្យា (ក្រុងស្រី) ក្រុមហ៊ុន GE Capital និង AT Kearney ។ មុនពេលចូលរួមជាមួយនឹង ហត្ថាកសិករ លោក Wanchairabin គឺជានាយកគ្រប់គ្រងផ្នែកគ្រប់គ្រងយុទ្ធសាស្ត្រសហគមន៍សេដ្ឋកិច្ចអាស៊ាននៃធនាគារក្រុងស្រី ដោយលោកមានតួនាទីសំខាន់គ្រប់គ្រងលើការពង្រីកសកម្មភាពអាជីវកម្មរបស់ ធនាគារនេះនៅក្នុងបណ្តាប្រទេសមហាអនុតំបន់ទន្លេមេគង្គ។ តាមរយៈបទពិសោធន៍លើវិស័យធនាគារជាមួយនឹងសមត្ថភាពលើការប្រឹក្សាយោបល់លើការដឹកនាំនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ លោកក៏បានរៀបចំ និងការដឹកនាំ ផែនការយុទ្ធសាស្ត្រយ៉ាងជោគជ័យជាច្រើន ហើយសម្រេចគម្រោងទាំងនោះទៅតាមការកំណត់ចំណែកទីផ្សារ និងទិសដៅអាជីវកម្ម។ គម្រោងសំខាន់ៗទាំ២ នោះរួមមាន ការកំណត់យុទ្ធសាស្ត្រក្រុមហ៊ុន ការអភិវឌ្ឍផលិតផល និងចរន្តបែងចែកការពង្រឹងប្រព័ន្ធ telemarketing ការកែលម្អដំណើរការខ្សែចង្វាក់នៃផលិតកម្ម និងការបង្កើតគំរូសេវាកម្មនៃការលក់ផលិតផល។ លោក Wanchairabin បានទទួលនូវសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែក គ្រប់គ្រងធុរកិច្ចពី សាកលវិទ្យាល័យពាណិជ្ជសាស្ត្រ នៃទីក្រុង Melbourne ប្រទេសអូស្ត្រាលី និងបរិញ្ញាបត្រវិស្វកម្មពីសាកលវិទ្យាល័យ Chulalongkorn ប្រទេសថៃ។





**លោក Chandrashekar SUBRAMANIAN KRISHOOLND-MANGALAM**
**អភិបាល**

លោក Chandrashekar SUBRAMANIAN KRISHOOLNDMANGALAM (Chandra) ត្រូវបានតែងតាំងជាអគ្គនាយក នាយកដ្ឋានគ្រប់គ្រង ហានិភ័យ របស់ ធនាគារ ក្រុងស្រ៊ី នៅខែ មករា ឆ្នាំ ២០០៧ ។ ហើយបច្ចុប្បន្នលោក មានមុខងារជា សមាជិកមួយរូបនៃ គណៈកម្មការគ្រប់គ្រងហានិភ័យ គណៈកម្មការប្រតិបត្តិ និងគណៈកម្មការទ្រព្យ សកម្ម និងអកម្ម។ មុនចូលបម្រើការងារនៅ ធនាគារ ក្រុងស្រ៊ី លោក Chandra បានបម្រើការងារជា អគ្គនាយក នាយកដ្ឋានគ្រប់គ្រងហានិភ័យនៅក្រុមហ៊ុន GE ប្រទេសឥណ្ឌា ទទួលបន្ទុកពិនិត្យអាជីវកម្ម លក់រាយ ដែលរាប់បញ្ចូលទាំងសេវាកម្ចីគេហដ្ឋាន កម្ចីផ្ទាល់ខ្លួន កម្ចីយានយន្តនិងកាតឥណទានជាដើម។ លោក Chandra ក៏បានបញ្ចប់ថ្នាក់ក្រោយសកលវិទ្យាល័យបុមបៃ ផ្នែកពាណិជ្ជកម្ម នៅក្នុងឆ្នាំ ១៩៨៥។

**កញ្ញា Duangdao WONGPANITKRI**
**អភិបាល**

កញ្ញា Duangdao WONGPANITKRI ត្រូវបានតែងតាំងជា អគ្គនាយិកានាយកដ្ឋានហិរញ្ញវត្ថុ នៃធនាគារក្រុងស្រ៊ីនៅថ្ងៃទី ០១ ខែមករា ឆ្នាំ ២០១៣។ កញ្ញា បានបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រផ្នែកគណនេយ្យ ព្រមទាំងហិរញ្ញវត្ថុពីសាកលវិទ្យាល័យ Thammasat និង បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងហិរញ្ញវត្ថុពីសាកលវិទ្យាល័យ Chulalongkorn។ បន្ថែមពីនេះកញ្ញា ក៏ធ្លាប់ទទួលបានសញ្ញាបត្របញ្ជាក់ ពីជំនាញផ្នែកគណនេយ្យសាធារណៈ Certified Public Accountant ពី CPA ព្រះរាជាណាចក្រថៃ។ កញ្ញា Duangdaoមានបទពិសោធន៍ការងារជាច្រើនឆ្នាំលើផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ តាមស្ថាប័ននានា ដូចជា KPMG, Star Petroleum និង ធនាគារ Standard Chartered Bank មុនពេលបម្រើការងារនៅធនាគារ ក្រុងស្រ៊ី។





**លោក Rohit KHANA**
**អភិបាល**

លោក Rohit Khanna បានចូលបម្រើការងារនៅធនាគារអយុធ្យា (ធនាគារ Krungsri) ក្នុងឆ្នាំ ២០១០ ដោយមានមុខតំណែងចុងក្រោយ នៅ ធនាគារKrungsri ជានាយក នាយកដ្ឋានផែនការ និងយុទ្ធសាស្ត្រ ដោយទទួលខុសត្រូវលើការបង្កើត និងអនុវត្តយុទ្ធសាស្ត្រក្រុមហ៊ុន ក្នុងគោលបំណងធ្វើឲ្យធនាគារ Krungsri ក្លាយជាស្ថាប័នហិរញ្ញវត្ថុឈានមុខគេមួយក្នុងពិភពលោក។ នៅខែតុលា ឆ្នាំ ២០១៥ លោកក៏បានពង្រីកតួនាទីរបស់លោកផងដែរ លើការត្រួតពិនិត្យផ្នែកម៉ាឃីតធីង សកម្មភាពផ្សព្វផ្សាយ និងBranding ការទំនាក់ទំនង និងផ្នែកគាំទ្រធុរកិច្ចសង្គម។ នៅខែសីហា ឆ្នាំ ២០១៩ លោក Rohit Khanna ត្រូវបានតែងតាំងដោយធនាគារ MUFG ដើម្បីឲ្យទៅបំពេញការងារជាមួយធនាគារ MUFG Union, នៅរដ្ឋសាន់ឌីហ្គោ សហរដ្ឋអាមេរិក ដែលជាបុត្រសម្ព័ន្ធរបស់ធនាគារ MUFG ក្នុងឋានៈជាអគ្គនាយក សម្រាប់ដឹកនាំក្រុមផ្លាស់ប្តូរប្រព័ន្ធស្នូលរបស់ធនាគារ។ លោក Rohit ទទួលបានបរិញ្ញាបត្រលើជំនាញវិស្វកម្មអេឡិចត្រូនិក និងបរិញ្ញាបត្រជាន់ខ្ពស់ផ្នែករដ្ឋបាលអាជីវកម្មពី សាកលវិទ្យាល័យ XLRI នៃប្រទេសឥណ្ឌា។លើសពីនេះទៅទៀត លោកជាគ្រូបង្គោលខ្សែក្រវាត់ខ្មៅ និងអ្នកអប់រំផ្នែក Six Sigma។

**លោក ប៉ាក សេរីវឌ្ឍនា**
**អភិបាលឯករាជ្យ**

លោក ប៉ាក សេរីវឌ្ឍនា គឺជាអ្នកឯកទេសលើវិស័យហិរញ្ញវត្ថុ និងជាអ្នកផ្តល់ការប្រឹក្សាលើការវិនិយោគ ដែលមានបទពិសោធន៍ជាង ២០ឆ្នាំ ក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងហិរញ្ញប្បទានគម្រោង។ លោកមានជំនាញផ្នែកផែនការយុទ្ធសាស្ត្រ និងការធ្វើគម្រោងអាជីវកម្ម ការសិក្សាលើលទ្ធភាពគម្រោង ការវាយតម្លៃលើការវិនិយោគ និងឥណទានធនាគារ។ បទពិសោធន៍របស់លោក វឌ្ឍនា រួមមានការដឹកនាំក្រុមការងារ Axis Investment Consulting ដើម្បីអភិវឌ្ឍ និងអនុវត្តការប្រឹក្សាយោបល់សម្រាប់អាជីវកម្ម និងទីភ្នាក់ងារអភិវឌ្ឍន៍ផ្សេងៗនៅកម្ពុជា។ លោកបានធ្វើការជាច្រើនពាក់ព័ន្ធនឹងឥណទានធនាគារ យុទ្ធសាស្ត្រផ្តល់ដើមទុនសម្រាប់វិស័យហិរញ្ញវត្ថុ និងហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ ដែលជាផ្នែកមួយនៃការងាររបស់លោក ជាមួយក្រុមធនាគារពិភពលោក។ លោក វឌ្ឍនា ទទួលបានបរិញ្ញាបត្រសេដ្ឋកិច្ច ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង (អតីតវិទ្យាស្ថានសេដ្ឋកិច្ច) និងអនុបណ្ឌិតផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យ Central Queensland នៅប្រទេសអូស្ត្រាលី។



**លោកបណ្ឌិត ឌី ដារុវុឌ្ឍ**
**អភិបាលឯករាជ្យ**

បណ្ឌិត ឌី ដារុវុឌ្ឍ ជាទីប្រឹក្សាដែលមានបទពិសោធខ្ពស់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ។ លោកធ្លាប់បម្រើការងារនៅស្ថាប័នជាតិ និងអន្តរជាតិជាច្រើន ជាមួយនឹងការទទួលខុសត្រូវលើគម្រោងសំខាន់ៗរួមមាន ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ធនាគារពិភពលោក (World Bank) និង SMEC International ជាដើម។ លោកបណ្ឌិត ឌី ដារុវុឌ្ឍ ក៏មានគុណវុឌ្ឍិក្នុងការគ្រប់គ្រងការសិក្សាថ្នាក់ឧត្តម ដោយបច្ចុប្បន្នលោកបណ្ឌិត មានតួនាទីជាសាកលវិទ្យាធិការរងជាន់ខ្ពស់នៃសាកលវិទ្យាល័យបៀលប្រាយ ហើយលើសពីនេះទៀត លោកបណ្ឌិតក៏មានបទពិសោធន៍ក្នុងវិស័យមីក្រូហិរញ្ញវត្ថុជាង ២០ឆ្នាំ ផងដែរ។

**លោក ឡូញ ហៃ**
**អភិបាលឯករាជ្យ**

លោក ឡូញ ហៃ បានចូលនិវត្តន៍នៅខែតុលា ឆ្នាំ ២០០៨ បន្ទាប់ពីបម្រើការងារនៅធនាគារជាតិនៃកម្ពុជា អស់រយៈពេលជាង ២៥ ឆ្នាំ លោកបានកាន់មុខតំណែងចុងក្រោយជា អគ្គនាយករង និងជាទីប្រឹក្សានៃអគ្គទេសាភិបាលធនាគារជាតិ នៃកម្ពុជា។ អំឡុងពេលបំពេញការងារនៅកម្ពុជា លោកបានធ្វើការងារនៅក្នុងនាយកដ្ឋាននានា ជាច្រើន និងធ្វើការងារទាក់ទងនឹងសកម្មភាពផ្នែកហិរញ្ញវត្ថុទាំងក្នុងតំបន់និងអន្តរជាតិដែលទាំងនេះបានធ្វើឱ្យលោកទទួលបាននូវបទពិសោធន៍ជាច្រើន ទាក់ទងនឹងការងាររបស់ខ្លួន។



# ការប្រជុំគណៈកម្មាធិការក្រុមប្រឹក្សាភិបាល

## ១-ការប្រជុំក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទក្លាយជាអភិបាល | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | លោក Dan HARSONO | ប្រធានក្រុមប្រឹក្សាភិបាល | ១២ កញ្ញា ១៦ | ១២ | ១២ |
| ២ | កញ្ញា Duangdao WONGPANITKRIT | អភិបាល | ១២ កញ្ញា ១៦ | ១០ | ១២ |
| ៣ | លោក Rohit KHANNA | អភិបាល | ១២ កញ្ញា ១៦ | ៤ | ១២ |
| ៤ | លោក Chandrashekar SUBRAMANIAN KRISHOOLNDMANGALAM | អភិបាល | ១២ កញ្ញា ១៦ | ៩ | ១២ |
| ៥ | លោកឧកញ៉ា ហួត អៀងតុង | អភិបាល | ១២ កញ្ញា ១៦ | ១១ | ១២ |
| ៦ | លោក Wanchairabin JITWATTANATAM | អភិបាល | ២៧ ឧសភា ១៩ | ៨ | ១២ |
| ៧ | លោក ឌី ដាវុឌ្ឍ | អភិបាលឯករាជ្យ | ១២ កញ្ញា ១៦ | ១១ | ១២ |
| ៨ | លោក ឡូញ ហៃ | អភិបាលឯករាជ្យ | ១២ កញ្ញា ១៦ | ១២ | ១២ |
| ៩ | លោក ប៉ាក សេរីវឌ្ឍនា | អភិបាលឯករាជ្យ | ២៧ ឧសភា ១៩ | ៨ | ១២ |

## ២-ការប្រជុំគណៈកម្មាធិការក្រុមប្រឹក្សាភិបាល

### ២.១-គណៈកម្មាធិការសវនកម្មនៃក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះ | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | លោក ឌី ដាវុឌ្ឍ | ប្រធាន | ១២ កញ្ញា ១៦ | ១១ | ១២ |
| ២ | កញ្ញា Duangdao WONGPANITKRIT | សមាជិក | ១២ កញ្ញា ១៦ | ១០ | ១២ |
| ៣ | លោក ឡូញ ហៃ | សមាជិក | ១២ កញ្ញា ១៦ | ១២ | ១២ |

### លទ្ធផលការងាររបស់គណៈកម្មាធិការសវនកម្ម

- បានអនុម័តវិសោធនកម្មគោលការណ៍ប្រតិបត្តិសវនកម្មផ្ទៃក្នុង
- បានអនុម័តផែនការ និងយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុងសម្រាប់ឆ្នាំ២០១៩
- បានអនុម័តរបាយការណ៍ត្រួតពិនិត្យផ្ទៃក្នុងប្រចាំឆ្នាំ២០១៨ សម្រាប់ផ្ញើជូនធនាគារជាតិនៃកម្ពុជា
- បានអនុម័តរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ២០១៨ របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសទី១ ទី២ ទី៣ ឆ្នាំ២០១៩ ដែលបានធ្វើសវនកម្ម និងត្រួតពិនិត្យដោយសវនករឯករាជ្យ
- បានផ្តល់អនុសាសន៍ទៅក្រុមប្រឹក្សាភិបាល និងភាគទុនិកក្នុងការតែងតាំសវនករឯករាជ្យសម្រាប់ធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០១៩
- បានអនុម័តវិសោធនកម្មផែនការសវនកម្មឆ្នាំ២០១៩
- បានអនុម័តគោលការណ៍ប្រតិបត្តិស្តីពីការធ្វើសុពលភាពរបកគំហើញសវនកម្ម (Issue Validation Manual)

### ២.២-គណៈកម្មាធិការផ្តល់តម្លៃការនៃក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះ | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | លោក ឡូញ ហៃ | ប្រធាន | ១២ កញ្ញា ១៦ | ១០ | ១០ |
| ២ | លោក Dan HARSONO | សមាជិក | ១២ កញ្ញា ១៦ | ១០ | ១០ |
| ៣ | លោកឧកញ៉ា ហួត អៀងតុង | សមាជិក | ១២ កញ្ញា ១៦ | ៩ | ១០ |

### លទ្ធផលការងាររបស់គណៈកម្មាធិការផ្តល់តែម្លការ

- បានអនុម័តវិសោធនកម្មរចនាសម្ព័ន្ធគ្រប់គ្រងឆ្នាំ២០១៩
- បានអនុម័តអត្រាដំឡើងប្រាក់បៀវត្សរ៍របស់កម្មករនិយោជិតសម្រាប់ឆ្នាំ២០១៨
- បានអនុម័តវិសោធនកម្មគោលនយោបាយជ្រើសរើសបុគ្គលិក
- បានអនុម័តវិសោធនកម្មរចនាសម្ព័ន្ធគ្រប់គ្រងឆ្នាំ២០១៩ របស់អគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
- បានអនុម័តគោលនយោបាយគ្រប់គ្រងលទ្ធផលការងារ
- បានអនុម័តគោលនយោបាយអភិវឌ្ឍធនធានមនុស្ស
- បានអនុម័តវិសោធនកម្មក្រមប្រតិបត្តិរបស់គណៈកម្មាធិការប្រតិបត្តិ
- បានអនុម័តគោលនយោបាយអត្ថប្រយោជន៍
- បានអនុម័តរចនាសម្ព័ន្ធគ្រប់គ្រងឆ្នាំ២០២០

## ២.៣-គណៈកម្មាធិការទ្រព្យសកម្ម អកម្ម និងហានិភ័យនៃក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះ | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | លោក ប៉ាក សេរីវឌ្ឍនា | ប្រធាន | ២៧ ឧសភា ១៩ | ៨ | ១២ |
| ២ | កញ្ញា Duangdao WONGPANITKRIT | សមាជិក | ១២ កញ្ញា ១៦ | ១០ | ១២ |
| ៣ | លោក Chandrashekar SUBRAMANIAN KRISHOOLNDMANGALAM | សមាជិក | ១២ កញ្ញា ១៦ | ៩ | ១២ |
| ៤ | លោក Rohit KHANNA | សមាជិក | ១២ កញ្ញា ១៦ | ៤ | ១២ |

### លទ្ធផលការងាររបស់គណៈកម្មាធិការទ្រព្យសកម្ម អកម្ម និងហានិភ័យ

- បានអនុម័តទទួលស្គាល់លទ្ធផលវាតតម្លៃប្រឆាំងការសម្អាតប្រាក់ប្រចាំឆ្នាំ២០១៨
- បានអនុម័តរចនាសម្ព័ន្ធមុខងារប្រតិបត្តិតាមឆ្នាំ២០១៩
- បានវាយតម្លៃលទ្ធផលការងារប្រធានមុខងារប្រតិបត្តិតាម ឆ្នាំ២០១៨
- បានអនុមតិកម្រិតឥណទានតាមវិស័យសម្រាប់ឆ្នាំ២០១៩
- បានអនុមតិចំណាត់ថ្នាក់ហានិភ័យទីផ្សារ និងសាច់ប្រាក់ងាយស្រួល (Liquidity)
- បានអនុម័តគោលនយោបាយហានិភ័យប្រតិបត្តិការ
- បានអនុម័តវិសោធនកម្មគោលនយោបាយគ្រប់គ្រងហានិភ័យឥណទាន
- បានអនុម័តលទ្ធផលវាយតម្លៃផ្ទាល់ខ្លួនលើហានិភ័យឥណទានប្រចាំឆ្នាំ
- បានអនុម័តកម្រិត Liquid Asset Ratio
- បានអនុម័ត Behavioral Assumption Rate
- បានអនុម័តវិសោធនកម្មគោលនយោបាយឥណទាន
- បានអនុម័ត Quarterly Behavioral Assumption Rate
- បានអនុម័ត Semi-Annual Market and Liquidity Risk
- បានអនុម័តទទួលស្គាល់គោលការណ៍ណែនាំគ្រប់គ្រងហានិភ័យបច្ចេកវិទ្យាព័ត៌មាន របស់ធនាគារជាតិនៃកម្ពុជា
- បានអនុម័តគោលនយោបាយចំណាត់ថ្នាក់ឥណទាន និងហានិភ័យឥណទាន
- បានអនុម័តវិសោធនកម្មគោលនយោបាយរៀបចំឥណទានឡើងវិញ
- បានអនុម័តវិសោធនកម្មគោលនយោបាយគ្រប់គ្រងហានិភ័យការកេងបន្លំ
- បានអនុម័តវិសោធនកម្មគោលនយោបាយគណនី (Accounting Policy)
- បានអនុម័តផែនការប្រតិបត្តិការឆ្នាំ២០២០
- បានអនុម័តវិសោធនកម្មគោលនយោបាយហានិភ័យទីផ្សារ និង សាច់ប្រាក់ងាយស្រួល
- បានអនុម័តទទួលស្គាល់នីតិវិធីស្តីពីផែនការយថាភាពសាច់ប្រាក់ងាយស្រួល (Liquidity Contingency Plan)
- បានអនុម័តវិសោធនកម្មគោលនយោបាយ Impairment
- បានអនុម័តវិសោធនកម្មគោលនយោបាយគ្រប់គ្រងផែនការនិរន្តរភាពអាជីវកម្ម
- បានអនុម័តវិសោធនកម្មគោលនយោបាយគ្រប់គ្រងលទ្ធផលសង្គម
- បានអនុម័តវិសោធនកម្មគោលនយោបាយអាថ៌កំបាំងវិជ្ជាជីវៈ
- បានអនុម័តរចនាសម្ព័ន្ធគ្រប់គ្រងនាយកដ្ឋានប្រតិបត្តិតាម។

## ២.៤-គណៈកម្មាធិការបច្ចេកវិទ្យាព័ត៌មាននៃក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះ | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | លោក Rohit KHANNA | ប្រធាន | ១២ កញ្ញា ១៦ | ៣ | ៨ |
| ២ | លោក Wanchairabin JITWATTANATAM | សមាជិក | ២៧ ឧសភា ១៩ | ៦ | ៨ |
| ៣ | លោក ឌី ដាវុឌ្ឍ | សមាជិក | ១២ កញ្ញា ១៦ | ៨ | ៨ |

### លទ្ធផលការងាររបស់គណៈកម្មាធិការបច្ចេកវិទ្យាព័ត៌មាន

- បានអនុម័តវិសោធនកម្មរចនាសម្ព័ន្ធគ្រប់គ្រងអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
- បានអនុម័តគោលនយោបាយសន្តិសុខព័ត៌មានវិទ្យា
- បានអនុម័តក្រមប្រតិបត្តិរបស់គណៈកម្មាធិការគ្រប់គ្រងព័ត៌មានវិទ្យាកម្រិតថ្នាក់គ្រប់ គ្រង។

## ២.៥-គណៈកម្មាធិការឥណទាននៃក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះ | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | លោក Chandrashekar SUBRAMANIAN KRISHOOLNDMANGALAM | ប្រធាន | ១២ កញ្ញា ១៦ | ១ | ១ |
| ២ | លោក ឡុញ ហៃ | សមាជិក | ១២ កញ្ញា ១៦ | ១ | ១ |
| ៣ | លោកឧកញ៉ា ហួត អៀងតុង | សមាជិក | ១២ កញ្ញា ១៦ | ១ | ១ |
| ៤ | លោក Wanchairabin JITWATTANATAM | សមាជិក | ២៧ ឧសភា ១៩ | ១ | ១ |

### លទ្ធផលការងាររបស់គណៈកម្មាធិការឥណទាន

មិនមាន

## ការប្រែប្រួលសមាជិកនៅក្នុងគណៈកម្មាធិការ

| ល.រ | គណៈកម្មាធិការ | ឈ្មោះ | មូលហេតុ |
|---|---|---|---|
| ១ | សវនកម្ម | មិនមាន | មិនមាន |
| ២ | តែងតាំង និងតម្លៃការ | មិនមាន | មិនមាន |
| ៣ | ទ្រព្យសកម្ម អកម្ម និងហានិភ័យ | លោកស្រី តាល់ ណៃរ៉ុម | ចូលនិវត្តន៍ |
| ៤ | បច្ចេកវិទ្យាព័ត៌មាន | លោក Rohit KHANNA | ផ្លាស់កន្លែងការងារទៅ សហរដ្ឋអាមេរិក |
| ៥ | ឥណទាន | លោក Piyasak UKRITNUKUN | លាលែង |

# រចនាសម្ព័ន្ធស្ថាប័ន



# សមាជិកគណៈកម្មាធិការប្រតិបត្តិ



**១. លោកឧកញ៉ា ហួត អៀងតុង**
ប្រធានអគ្គនាយក



**២. លោក Wanchairabin JITWATTANATAM**
អនុប្រធានអគ្គនាយក



**៣. កញ្ញា អ៊ឹម វណ្ណិត**
អគ្គនាយិកា ប្រតិបត្តិការ និងអភិបាលកិច្ច



**៤. លោក ហ៊ឹម វិបុល**
អគ្គនាយកហិរញ្ញវត្ថុ



**៥. លោក រស់ រ៉ុល**
អគ្គនាយកសវនកម្មផ្ទៃក្នុង (អ្នកសង្កេតការណ៍)



**៦. លោក ម៉ិច សុខមេត្រី**
អគ្គនាយកអភិវឌ្ឍន៍អាជីវកម្ម



**៧. លោក ជឹន បូរាណច័ន្ទបូរ៉ាត់**
អគ្គនាយកនីតិកម្ម



**៨. លោក ទូច លីណា**
អគ្គនាយកអនុម័តឥណទាន



**៩. លោក យឹម ទិត្យា**
អគ្គនាយកបច្ចេកវិទ្យាព័ត៌មាន



**១០. លោក សេម សោភ័ណ**
អគ្គនាយកធនធានមនុស្ស



**១១. លោកស្រី ឆេង សុគន្ធ**
អគ្គនាយិកាគ្រប់គ្រងហានិភ័យ



**១២. លោក ដួង ច័ន្ទសុវិជ្ជា**
អគ្គនាយកលក់និងចែកចាយ



**១៣. កញ្ញា ហេង ស្រីប៉ុច**
នាយិកាប្រតិបត្តិតាម (អ្នកសង្កេតការណ៍)

# ជីវប្រវត្តិសមាជិកគណៈកម្មាធិការប្រតិបត្តិ



**លោកឧកញ៉ា ហួត អៀងតុង**
**ប្រធានអគ្គនាយក**

លោកឧកញ៉ា ហួត អៀងតុង គឺជាសហស្ថាបនិករបស់ ហត្ថាកសិករលីមីតធីត ក្នុងឆ្នាំ ១៩៩៤ ហើយបានដឹកនាំស្ថាប័ននេះចាប់តាំងពីពេលនោះមក។ លោកឧកញ៉ា ហួត អៀងតុង មានបទពិសោធន៍ច្រើនជាង ៣០ឆ្នាំ លើវិស័យមីក្រូហិរញ្ញវត្ថុដែលជាកត្តាធ្វើឱ្យលោកក្លាយជាប្រតិបត្តិករយ៉ាងប៉ិនប្រសប់ ទាំងក្នុងការគ្រប់គ្រងហិរញ្ញវត្ថុនិងមិនមែនហិរញ្ញវត្ថុនៅក្នុងស្ថាប័ន។ បន្ទាប់ពីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រលើជំនាញកសិកម្មនៅឆ្នាំ ១៩៩១ លោកក៏បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតរដ្ឋបាលនិងគ្រប់គ្រងអាជីវកម្ម។ ពិសេសជាងនេះទៅទៀត លោកធ្លាប់ចូលរួមសិក្ខាសាលាជាច្រើននៅក្រៅប្រទេសពាក់ព័ន្ធទៅនឹងវិស័យមីក្រូហិរញ្ញវត្ថុ ដូចជានៅប្រទេស ហ្វីលីពីន សហរដ្ឋអាមេរិក ឥណ្ឌូនេស៊ី បារាំង អាល្លឺម៉ង់ និងប្រទេសជាច្រើនទៀត។





**លោក Wanchairabin JITWATTANATAM**
**អនុប្រធានអគ្គនាយក**

លោក Wanchairabin បានចូលបម្រើការងារនៅ ហត្ថាកសិករ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៦ ដោយនាំមកជាមួយនូវបទពិសោធ ជំនាញវិជ្ជាជីវៈការងារចម្រុះជាង២០ឆ្នាំ លើវិស័យធនាគារនិងហិរញ្ញវត្ថុ ការប្រឹក្សាយោបល់ទៅលើការគ្រប់គ្រងទូទៅ និងជាពិសេសវិស័យវិស្វកម្មនៅក្នុងក្រុមហ៊ុនដែលសំខាន់ៗមួយចំនួនដូចជាធនាគារអយុធ្យា (ក្រុងស្រី) ក្រុមហ៊ុន GE Capital និង AT Kearney ។ មុនពេលចូលរួមជាមួយនឹង ហត្ថាកសិករ លោក Wanchairabin គឺជានាយកគ្រប់គ្រងផ្នែកគ្រប់គ្រងយុទ្ធសាស្ត្រសហគមន៍សេដ្ឋកិច្ចអាស៊ានៃធនាគារក្រុងស្រី ដោយលោកមានតួនាទីសំខាន់គ្រប់គ្រងលើការពង្រីកសកម្មភាពអាជីវកម្មរបស់ ធនាគារនេះនៅក្នុងបណ្តាប្រទេសមហាអនុតំបន់ទន្លេមេគង្គ។ តាមរយៈបទពិសោធពលើវិស័យធនាគារជាមួយនឹងសមត្ថភាពលើការប្រឹក្សាយោបល់លើការដឹកនាំនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ លោកក៏បានរៀបចំ និងការដឹកនាំ ផែនការយុទ្ធសាស្ត្រយ៉ាងជោគជ័យជាច្រើន ហើយសម្រេចគម្រោងទាំងនោះទៅតាមការកំណត់ចំណែកទីផ្សារ និងទិសដៅអាជីវកម្ម។ គម្រោងសំខាន់ៗទាំ២ នោះរួមមាន ការកំណត់យុទ្ធសាស្ត្រក្រុមហ៊ុន ការអភិវឌ្ឍផលិតផល និងចរន្តបែងចែកការពង្រឹងប្រព័ន្ធ telemarketing ការកែលម្អដំណើរការខ្សែចង្វាក់នៃផលិតកម្ម និងការបង្កើតគំរូសេវាកម្មនៃការលក់ផលិតផល។ លោក Wanchairabin បានទទួលនូវសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែក គ្រប់គ្រងធុរកិច្ចពី សាកលវិទ្យាល័យពាណិជ្ជសាស្ត្រ នៃទីក្រុង Melbourne ប្រទេសអូស្ត្រាលី និងបរិញ្ញាបត្រវិស្វកម្មពីសាកលវិទ្យាល័យ Chulalongkorn ប្រទេសថៃ។

**កញ្ញា អ៊ឹម វណ្ណិត**
**អគ្គនាយិកា ប្រតិបត្តិការ និងអភិបាលកិច្ច**

កញ្ញា អ៊ឹម វណ្ណិត បានចាប់ផ្តើមអាជីពការងារនៅ ហត្ថាកសិករក្នុងឆ្នាំ ១៩៩៥ ក្នុងចំណោមក្រុមបុគ្គលិកដំបូងគេបង្អស់ មុនពេលចូលរួមជាមួយនឹង ហត្ថាកសិករ ។ កញ្ញាបានបម្រើការនៅ អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំនៅប្រទេស កម្ពុជា (អ៊ុនតាក់) សម្រាប់ការរៀបចំការបោះឆ្នោតជាតិនៅកម្ពុជា និងអង្គការផ្តល់ជំនួយ មួយរបស់សហរដ្ឋអាមេរិចឈ្មោះ The American Relief Committee ។ កញ្ញា អ៊ឹម វណ្ណិត បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញគណនេយ្យ មកពីសាកលវិទ្យាល័យបៀលប្រាយនៅឆ្នាំ ២០០៨។ កញ្ញាក៏បានបន្តពង្រីកចំណេះដឹងតាមរយៈ ការចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលនានាទៅលើវិស័យហិរញ្ញវត្ថុ និងវិស័យពាក់ព័ន្ធដទៃទៀតទាំងក្នុងនិងក្រៅប្រទេស។



**លោក ហ៊ឹម វិបុល**
**អគ្គនាយកហិរញ្ញវត្ថុ**

លោក ហ៊ឹម វិបុល បានចូលបម្រើការងារនៅ ហត្ថាកសិករនៅខែ មិថុនា ឆ្នាំ ២០១៥ ដោយនាំមកជាមួយនូវបទពិសោធជាង ១៥ ឆ្នាំក្នុងវិស័យមីក្រូហិរញ្ញវត្ថុ។ មុនពេលចូលរួមជាមួយនឹង ហត្ថាកសិករ លោក វិបុល ក៏ធ្លាប់បានកាន់តួនាទីជាច្រើនរួមមាន សវនកម្មផ្ទៃក្នុង គណនេយ្យនិង ហិរញ្ញវត្ថុហើយលោកបានទទួល តួនាទីជាអគ្គនាយកហិរញ្ញវត្ថុ នៅស្ថាប័នមីក្រូហិរញ្ញវត្ថុធំមួយ។ បន្ថែមពីលើតួនាទីនេះ លោក វិបុលបានទទួលខុសត្រូវក្នុងការគ្រប់គ្រង គម្រោងនៃការផ្លាស់ប្តូរប្រព័ន្ធធនាគារស្នូលផងដែរ។ ជាមួយលទ្ធផលឆ្នើមក្នុងការសិក្សា លោក វិបុល បានទទួលសញ្ញាបត្របរិញ្ញាបត្រផ្នែកសេដ្ឋកិច្ចនៅឆ្នាំ ២០០២ និងបញ្ចប់ថ្នាក់បរិញ្ញា បត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុនិងគណនេយ្យនៅឆ្នាំ ២០០៥ ។ នៅឆ្នាំ២០១៧ លោកបានបញ្ចប់ការសិក្សាពី ACCA ហើយបានក្លាយទៅជា សមាជិកនៃសមាគមគណនេយ្យករជំនាញ (ACCA) នៃចក្រភពអង់គ្លេសនៅ ខែ កុម្ភៈ ឆ្នាំ ២០១៨។



**លោក រស់ វ៉ុល**
**អគ្គនាយកសវនកម្មផ្ទៃក្នុង (អ្នកសង្កេតការណ៍)**

លោក រស់ វ៉ុលត្រូវបានតែងតាំងជាអនុប្រធានអគ្គនាយក និងជាអគ្គនាយកសវនកម្មផ្ទៃក្នុង នៅឆ្នាំ ២០១៥។ លោកមានបទពិសោធន៍ជាង ៨ឆ្នាំ នៅក្នុងផ្នែកសវនកម្មផ្ទៃក្នុង និងការគ្រប់គ្រងសាខានិងមានបទពិសោធន៍ជាង ១១ឆ្នាំ លើការគ្រប់គ្រង សវនកម្ម។ លោកទទួលបាន បរិញ្ញាបត្រជាន់ខ្ពស់ ពីសាកលវិទ្យាល័យ Preston និងបានបញ្ចប់បរិញ្ញាបត្រជំនាញគ្រប់គ្រងនៅឯសាកលវិទ្យាល័យ Maharishi Verdic ក្នុងឆ្នាំ ១៩៩៨ ផងដែរ។



**លោក ម៉ិច សុខមេត្រី**
**អគ្គនាយកអភិវឌ្ឍន៍អាជីវកម្ម**

លោក ម៉ិច សុខមេត្រី ត្រូវបានដំឡើងតួនាទីទៅជា អនុប្រធានអគ្គនាយក និងអគ្គនាយកអភិវឌ្ឍន៍អាជីវកម្មនៅខែ មករា ឆ្នាំ ២០១៤ បន្ទាប់ពីលោកបានបំពេញការងារអស់រយៈពេល ៨ ឆ្នាំ នៅក្នុង ហត្ថាកសិករ នៅនាយកដ្ឋានម៉ាឃីតធីងនិងគ្រប់គ្រងហានិភ័យ។ លោកមានបទពិសោធន៍ជាច្រើនឆ្នាំលើម៉ាឃីតធីង ការគ្រប់គ្រងស្លាកសញ្ញាការគ្រប់គ្រងទំនាក់ទំនងអតិថិជន និងការគ្រប់គ្រងហានិភ័យនិងប្រតិបត្តិតាម(អនុលោមភាព)។ នៅឆ្នាំ ២០១៣ លោក មេត្រី ទទួលសញ្ញាបត្រជាអ្នកជំនាញផ្នែកគ្រប់គ្រងហានិភ័យ នៃសាលាហិរញ្ញវត្ថុ និងគ្រប់គ្រងហ្វ្រែងហ្វើត។



**លោក ជឹន បូរាណច័ន្ទបូរ៉ាត់**
**អគ្គនាយកនីតិកម្ម**

លោក ជឹន បូរាណច័ន្ទបូរ៉ាត់ បានចូលបម្រើការងារនៅ ហត្ថាកសិករ នៅខែធ្នូ ឆ្នាំ ២០១១ ក្នុងតួនាទីជានាយកនីតិកម្ម និងលេខាធិការ។ នៅក្នុងឆ្នាំ ២០១៨ លោកត្រូវបានតែងតាំងជាអនុប្រធានអគ្គនាយក និងអគ្គនាយកនីតិកម្ម។ លោកមានបទពិសោធជាង ១០ ឆ្នាំ នៅធនាគារពាណិជ្ជកម្ម។ លោក ច័ន្ទបូរ៉ាត់ បានទទួលសញ្ញាបត្រថ្នាក់បរិញ្ញបត្រ និងអនុបណ្ឌិតផ្នែកនីតិឯកជន នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។





**លោក ទូច លីណា**
**អគ្គនាយកអនុម័តឥណទាន**

លោក ទូច លីណាត្រូវបានតែងតាំងជាអនុប្រធានអគ្គនាយក និងអគ្គនាយកប្រតិបត្តិការនៅឆ្នាំ ២០០៣ បន្ទាប់ពីបានចាប់ផ្តើមអាជីពការងារ នៅ ហត្ថាកសិករ នៅខែ មីនា ឆ្នាំ ២០០៥។ លោកទទួលខុសត្រូវរាល់ប្រតិបត្តិការរបស់ ហត្ថាកសិករ រាប់ទាំងប្រតិបត្តិការឥណទាននិង ការគ្រប់គ្រងសាខា។ លោក លីណា បានបញ្ចប់ការសិក្សានៅវិទ្យាស្ថាន ជាតិគ្រប់គ្រងក្នុងឆ្នាំ ២០០៣ រួចហើយលោកក៏បាន ចូលរួមនៅក្នុងកម្មវិធីបណ្តុះបណ្តាលជាច្រើនទាំងក្នុងនិងក្រៅប្រទេសដូចជា ហ្វីលីពីន វៀតណាម និងលុចសំបួរជាដើម។

**លោក យឹម ទិត្យា**
**អគ្គនាយកបច្ចេកវិទ្យាព័ត៌មាន**

លោក យឹម ទិត្យា បានចូលរួម ហត្ថាកសិករ នៅខែ កញ្ញា ឆ្នាំ ២០១៧ ក្នុងតួនាទីជានាយកជាន់ខ្ពស់នៃ នាយកដ្ឋានផែនការ និងអភិបាលកិច្ចព័ត៌មានវិទ្យា ហើយត្រូវបានដំឡើងឋានៈ ជាអគ្គនាយកបច្ចេកវិទ្យាព័ត៌មាននៅខែ មិថុនា ឆ្នាំ ២០១៨។ តួនាទីរបស់គាត់គឺ គ្រប់គ្រងការត្រួតពិនិត្យការងារសម្រាប់ ការធ្វើផែនការយុទ្ធសាស្ត្របច្ចេកវិទ្យា ស្ថាបត្យកម្មសហគ្រាស ការគ្រប់គ្រងគម្រោង និងអភិបាលកិច្ចបច្ចេកវិទ្យា សម្រាប់ ហត្ថាកសិករ លីមីតធីត។





**លោក សេម សោភ័ណ**
**អគ្គនាយកធនធានមនុស្ស**

លោក សេម សោភ័ណ ចូលរួមបម្រើការងារនៅហត្ថាកសិករ នៅខែធ្នូ ឆ្នាំ ២០១០ ក្នុងតួនាទីជានាយកនាយកដ្ឋានធនធានមនុស្ស។ លោកមានបទពិសោធន៍ការងារជាង ២៧ ឆ្នាំ ក្នុងវិស័យផ្សេងៗ រួមមានការគ្រប់គ្រងធនធានមនុស្សរយៈពេល ១៤ ឆ្នាំ ការអភិវឌ្ឍស្ថាប័ន និងការធ្វើផែនការធានមនុស្ស និងការអភិវឌ្ឍភាពជាអ្នកដឹកនាំ។ លោក សោភ័ណ បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើជំនាញការអភិវឌ្ឍភាពជាអ្នកដឹកនាំមក ពីសាកលវិទ្យាល័យ Eastern University នៅក្នុងរដ្ឋ Philadelphia នៃសហរដ្ឋអាមេរិក និងបរិញ្ញាបត្រលើជំនាញនីតិសាធារណៈពីសាកលវិទ្យាល័យន័រតុន។

**លោកស្រី ឆេង សុគន្ធ**
**អគ្គនាយិកាគ្រប់គ្រងហានិភ័យ**

លោកស្រី ឆេង សុគន្ធ បានចាប់ផ្តើមការងារនៅ ហត្ថាកសិករ នៅក្នុងខែមេសា ឆ្នាំ ២០១៥ ក្នុងតួនាទីជានាយិកា នាយកដ្ឋានហានិភ័យ និងប្រតិបត្តិតាម។ មុនពេលចូលបម្រើការងារនៅ ហត្ថាកសិករ លោកស្រីបានឆ្លងកាត់បទពិសោធ ៩ឆ្នាំនៅធនាគារមួយ។ លោកស្រីបានចូលរួមសិក្សាវគ្គបណ្តុះបណ្តាល ជាច្រើនដែលរួមមានដូចជា ការកំណត់ហានិភ័យក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ ផែនការនិរន្តរភាពអាជីវកម្ម គ្រប់គ្រងបង្ការហានិភ័យ ភតិសន្យាហិរញ្ញវត្ថុ ហិរញ្ញប្បទានពាណិជ្ជកម្មលើជំនួញឥណទាន ផ្នែកទីផ្សារ និងវគ្គគរុកោសល្យ បង្រៀនភាសាអង់គ្លេសជាដើម។ លោកស្រីទទួលបានបរិញ្ញាបត្រផ្នែកព័ត៌មានវិទ្យា នៅឯសាកលវិទ្យាល័យភូមិន្ទភ្នំពេញនៅឆ្នាំ ២០០៦ ព្រមទាំងបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុ និងធនាគារពី សាកលវិទ្យាល័យជាតិគ្រប់គ្រងនៅឆ្នាំ ២០១១។ លោកស្រីទទួលបានសញ្ញាបត្រជាអ្នកជំនាញផ្នែកគ្រប់គ្រងហានិភ័យនៃសាលាហិរញ្ញវត្ថុនិងគ្រប់គ្រងហ្រ្វេងហ្វេីត នៅឆ្នាំ ២០១៧។





**លោក ដួង ច័ន្ទសុវិជ្ជា**
**អគ្គនាយកលក់ និងចែកចាយ**

លោក ដួង ច័ន្ទសុវិជ្ជា ចូលបម្រើការងារនៅ ហត្ថាកសិករឆ្នាំ ២០១៧ ក្នុងតួនាទីជានាយកនាយកដ្ឋាន ផ្នែកប្រតិបត្តិការហានិភ័យនិងការគ្រប់គ្រងការកេងបន្លំ។ ហើយត្រូវបានតម្លើងឋានៈ ទៅជាអគ្គនាយករងនៃអគ្គនាយកដ្ឋានលក់ និងចែកចាយ នៅក្នុងខែ សីហា ឆ្នាំ ២០១៨។ លោកមានបទពិសោធន៍ជាង ១៦ ឆ្នាំ នៅក្នុងវិស័យធនាគារ និងមីក្រូហ្វាយណាន់។

**កញ្ញា ហេង ស្រីប៉ុច**
**នាយិកាប្រតិបត្តិតាម (អ្នកសង្កេតការណ៍)**

កញ្ញា ហេង ស្រីប៉ុច ទើបតែចូលបម្រើការងារ នៅហត្ថាកសិករក្នុងតួនាទីជានាយិកាប្រតិបត្តិតាម (អនុលោម) បន្ទាប់ពីដាក់បញ្ចូលគ្នាជាមួយនឹងធនាគារក្រុងស្រី៊។ កញ្ញាធ្លាប់ទទួលតួនាទីជានាយិកានៃនាយកដ្ឋាននៅធនាគារពាណិជ្ជជាង ៦ ឆ្នាំ ដែលរាប់បញ្ចូលទាំងការងារប្រតិបត្តិតាមក្រមច្បាប់ ការអនុវត្តភាពពន្ធទៅលើជនបរទេស វិធាន VOLCKER និងគ្រោងការគ្រប់គ្រងហានិភ័យ។ កញ្ញា ស្រីប៉ុច បានទទួលការបណ្តុះបណ្តាលជំនាញនៅឯតៃវ៉ាន់ សិង្ហបុរី និងប្រទេសថៃ លើផ្នែកប្រតិបត្តិតាមការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិកាធនាគារ។






# កិច្ចការទីផ្សារ និងការស្រាវជ្រាវ

ហត្ថាកសិករ លីមីតធីត តែងតែធ្វើការវិភាគកត្តាបរិយាកាសខាងក្រៅ (PESTLE) ប្រចាំត្រីមាសក្នុងគោលបំណងតាមដានកត្តាពាក់ព័ន្ធផ្សេងៗដែលមាន ឥទ្ធិពលមកលើអាជីវកម្ម រួមមាន នយោបាយ សង្គមកិច្ច បច្ចេកវិទ្យា ច្បាប់ និងបរិស្ថាន។ របាយការណ៍វិភាគនេះផ្តល់នូវការយល់ដឹងកាន់តែស៊ីជម្រៅតាមរយៈការចង្អុលបង្ហាញឱ្យដឹងស្តីពីកត្តាគំរាមកំហែង និងជាពិសេសឱកាសដើម្បីធ្វើឱ្យអាជីវកម្មទាំងមូលកាន់តែរីកចម្រើនបន្តទៅមុខ។

របាយការណ៍កំណត់តម្លៃរបស់ដៃគូប្រកួតប្រជែងត្រូវបានធ្វើបច្ចុប្បន្នភាព ប្រចាំត្រីមាសក្នុងគោលដៅតាមដានគូប្រកួតប្រជែងសក្តានុពលមួយចំនួន ទាំងស្ថាប័នមីក្រូហិរញ្ញវត្ថុ និងស្ថាប័នធនាគារដោយផ្តោតជាចម្បងលើព័ត៌មានលក្ខណៈពិសេសរបស់ផលិតផល។ របាយការណ៍បច្ចុប្បន្នភាពនេះបានកំណត់ឱ្យដឹងនូវនិន្នាការហិរញ្ញវត្ថុចម្បងៗអំពីការកំណត់តម្លៃផលិតផលដែលមានការវិវត្តជាបន្តបន្ទាប់នៅលើទីផ្សារទាំងមូល។ តាមរយៈរបាយការណ៍នេះ ហត្ថាកសិករ លីមីតធីត ទទួលបាននូវព័ត៌មានទីផ្សារថ្មីៗបំផុតដើម្បីរួមចំណែកក្នុងការធ្វើយុទ្ធសាស្ត្រកំណត់តម្លៃផលិតផល និងបន្តរក្សាឱ្យបាននូវការប្រកួតប្រជែងនៅលើទីផ្សារ។

នៅឆ្នាំ ២០១៩ កន្លងមក ហត្ថាកសិករ លីមីតធីត បានធ្វើការសិក្សាស្រាវជ្រាវទីផ្សារសំខាន់ៗមួយចំនួន មានជាអាទិ៍រួមមានការសិក្សាស្តីពីការពេញចិត្តរបស់អតិថិជន ការសិក្សាស្តីពីការចាកចេញរបស់អតិថិជន ការសិក្សាអំពីការបង់ផ្តាច់មុនកាលកំណត់ ការសិក្សាអពីការពេញចិត្តរបស់បុគ្គលិក និងការសិក្សាពាក់ព័ន្ធនឹងផលិតផល/សេវាកម្ម ផ្សេងៗមានដូចជា ការសិក្សាអំពីលទ្ធភាព ការផ្តល់ព័ត៌មានគ្រលប់ និងការវាយតម្លៃលើផលិតផល/សេវាកម្មហិរញ្ញវត្ថុ។ ការសិក្សាទាំងអស់នេះផ្តល់ឱ្យ ហត្ថាកសិករ លីមីតធីត ធ្វើការស្វែងយល់បន្ថែមទៀតអំពីចំណង់ចំណូលចិត្ត និងឥរិយាបថអតិថិជនរបស់ខ្លួន។

ម្យ៉ាងទៀត ដើម្បីធ្វើការគាំទ្រដល់កំណើនអាជីវកម្មរបស់ហត្ថាកសិករ ទាំងផលិតផលឥណទាន និងផលិតផលផ្សេងៗទៀត តាមរយៈការបង្កើត និងដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រទីផ្សារជាច្រើន។ យុទ្ធសាស្ត្រទាំងនោះរួមមាន ការត្រួតពិនិត្យ និងពង្រឹងការអនុវត្តទៅលើកម្មវិធី ណែនាំអតិថិជនយករង្វាន់ និងបង្កើតកម្មវិធី ផ្តល់រង្វាន់លើកទឹកចិត្តជូនអតិថិជនដែលបានប្រើប្រាស់អតិថិជនខ្នាតតូចបំផុត និងខ្នាតតូច ដើម្បីគាំទ្រដល់កំណើនប្រាក់ចំណូលតាមរយៈបង្កើនការទំលាក់ឥណទានខ្នាតតូច និងតូចបំផុត។ បន្ថែមពីលើនេះ យើងបានធ្វើការជំរុញលក់ដល់ផលិតផលប្រាក់បញ្ញើសន្សំ និងសន្សំមានកាលកំណត់ តាមរយៈការផ្សព្វផ្សាយបន្ថែមទៀត និងផ្តល់រង្វាន់ លើកទឹកចិត្តដល់អតិថិជន។



# ផលិតផល និងសេវាកម្មហិរញ្ញវត្ថុ

## ផលិតផលផ្សេងៗក្រៅពីឥណទាន
## ផលិតផលបញ្ញើសន្សំ

### ផលិតផលសន្សំ
ហត្ថាកសិករ ផ្តល់ជូនអតិថិជនរបស់ខ្លួនជាមួយនឹងផលិតផលសន្សំជាច្រើនប្រភេទ ដែលក្នុងនោះមាន គណនីសន្សំសំចៃ គណនីអ៊ីស្ស៊ី គណនីស្មាត គណនីនិស្សិត និងគណនីសន្សំផលច្រើន។ អតិថិជនអាចធ្វើប្រតិបត្តិការដាក់ប្រាក់ និងដកប្រាក់ បានតាមតម្រូវការ គ្រប់ពេលវេលា និង គ្រប់ទីកន្លែងនៅគ្រប់សាខា និង ម៉ាស៊ីនអេធីអឹមរបស់ហត្ថាកសិករទាំងអស់។ កាន់តែពិសេសទៀតនោះ អតិថិជននឹងទទួលបាននូវ អត្រាការប្រាក់ ដែលមានលក្ខណៈ ប្រកួតប្រជែង និងសមតុល្យអប្បបរមា ចាប់ពី ២ ដល់ ៥០០ ដុល្លារអារមេរិក អាស្រ័យទៅតាមប្រភេទគណនី និងរូបិយប័ណ្ណដែលដាក់សន្សំ។

### ផលិតផលសន្សំផលច្រើន
ផលិតផលសន្សំផលច្រើន គឺជាប្រភេទគណនីដ៏ពិសេសមួយដែល បង្កើតឡើងសម្រាប់អតិថិជនរូបវន្តបុគ្គលដែលកំពុង ជួបប្រទះនូវការលំបាកក្នុងការស្វែងរកការដាក់ប្រាក់សន្សំមួយដែលទទួលបានទាំងការប្រាក់ខ្ពស់ និងងាយស្រួលដកប្រាក់ ក្នុងពេលវេលាចាំបាច់ណាមួយភ្លាមៗ។ ជាមួយផលិតផលនេះ អតិថិជននឹងទទួលបានអត្រាការប្រាក់ខ្ពស់ ប្រហាក់ប្រហែលនឹងគណនីបញ្ញើមានកាលកំណត់អាស្រ័យ តាមសមតុល្យជាក់ស្តែងដែលអតិថិជនមានក្នុងគណនីប្រចាំថ្ងៃ។ លើសពីនេះទៅទៀត អតិថិជនអាចដកប្រាក់បានយ៉ាងងាយស្រួលតាមរយៈការិយាល័យ ម៉ាស៊ីនអេធីអឹម និងសេវាធនាគារចល័ត របស់ ហត្ថាកសិករ លីមីតធីត។

### ផលិតផលបញ្ញើមានកាលកំណត់
ផលិតផលបញ្ញើមានកាលកំណត់ គឺជាជម្រើសដ៏ល្អសម្រាប់អតិថិជនដែលមានបំណងចង់ដាក់បញ្ញើសាច់ប្រាក់របស់ពួកគាត់ ដោយទទួលបានការប្រាក់ខ្ពស់ និងមានសុវត្ថិភាព។ អតិថិជនមានជម្រើសជាច្រើនក្នុងការជ្រើសរើសរយៈពេលចាប់ពី ១ ខែ ដល់ ៣៦ ខែ ដើម្បីសន្សំជាមួយហត្ថាកសិករ។ ហត្ថាកសិករ នឹងធ្វើការផ្តល់អត្រាការប្រាក់ អាស្រ័យតាមប្រភេទគណនី និងរយៈពេលដែលអតិថិជនជ្រើសរើស។ ការប្រាក់នឹងផ្តល់ជូនជាប្រចាំខែ (ករណីអតិថិជនប្រើប្រាស់ជាមួយគណនីកើនចំណូល) ឬផ្តល់ជូនពេលដល់ថេរវេលាបានកំណត់ (ករណីអតិថិជនប្រើប្រាស់ជាមួយគណនីកើនទ្រព្យ)។ អតិថិជនអាចបើកគណនីនេះចាប់ពីទំហំទឹកប្រាក់ ៥០ ដុល្លារអាមេរិកឡើងទៅ (សមមូលនឹងរូបិយប័ណ្ណផ្សេង)។



## ផលិតផលផ្សេងៗ

### សេវាធនាគារចល័ត

សេវាធនាគារចល័ត គឺជាសេវាហិរញ្ញវត្ថុដ៏ទំនើបចុងក្រោយដែលអនុញ្ញាតឱ្យអតិថិជនធ្វើប្រតិបត្តិការហិរញ្ញវត្ថុបានគ្រប់ពេលវេលា និងគ្រប់ទីកន្លែងតាមរយៈទូរស័ព្ទដៃ។ តាមរយៈសេវាកម្មនេះ អតិថិជនអាចធ្វើប្រតិបត្តិការសាច់ប្រាក់ជាច្រើនដូចជាផ្ទេរប្រាក់ ទិញកាតទូរស័ព្ទ ប្រមូលសាច់ប្រាក់ សងត្រលប់ឥណទានព្រមទាំងអាចធ្វើប្រតិបត្តិការផ្សេងៗជាច្រើនទៀតដូចជាពិនិត្យសមតុល្យគណនី របាយការសង្ខេប ព័ត៌មានឥណទាន និងទីតាំងការិយាល័យ ឬអេធីអឹមជាដើម ។ល។ ពិសេសជាងនេះទៅទៀត អតិថិជនអាចធ្វើការសន្សំពិន្ទុតាមរយៈការធ្វើប្រតិបត្តិការ ដើម្បីយករង្វាន់ជាច្រើនដូចជាកាតទូរស័ព្ទ មួកសុវត្ថិភាព វ៉ាលីដាក់អីវ៉ាន់ និងទូរស័ព្ទដៃ ជាដើម។

### សេវាអេធីអឹម

ម៉ាស៊ីនអេធីអឹម ដ៏ទំនើបជាមួយសេវាកម្មសម្បូរបែបត្រូវបានដាក់បម្រើការទូទាំងប្រទេសកម្ពុជា ដើម្បីសម្រួលដល់ប្រតិបត្តិការហិរញ្ញវត្ថុប្រចាំថ្ងៃប្រកបដោយភាពងាយស្រួលតាមបណ្តាញម៉ាស៊ីនអេធីអឹម ដែលមានទីតាំងនៅជិតលោកអ្នកបំផុត។ អតិថិជន អាចធ្វើប្រតិបត្តិការដូចជា ដាក់ប្រាក់ ដកប្រាក់ ផ្ទេរប្រាក់ ប្តូរប្រាក់ ទិញកាតទូរស័ព្ទ ពិនិត្យសមតុល្យសាច់ប្រាក់ ពិនិត្យរបាយការណ៍សង្ខេប និងប្រតិបត្តិការហិរញ្ញវត្ថុតាមតម្រូវការគ្រប់ពេលវេលា និងទីកន្លែង។

### សេវាផ្ទេរប្រាក់ក្នុងស្រុក

សេវាផ្ទេរប្រាក់ក្នុងស្រុក គឺជាដំណោះស្រាយដ៏ប្រសើរបំផុតសម្រាប់អតិថិជនដែលបានបំណងផ្ទេរប្រាក់ទៅគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា។ ជាមួយភាពជឿជាក់ មានសុវត្ថិភាព និងសេវាកម្មរហ័សទាន់ចិត្ត អតិថិជនអាចធ្វើការផ្ទេរ ប្រាក់ទៅកាន់មនុស្សជាទីស្រលាញ់ បងប្អូន សាច់ញាតិ និងដៃគូអាជីវកម្មបានយ៉ាងងាយស្រួល និងរហ័សទាន់ចិត្ត តាមបណ្តាញការិយាល័យប្រតិបត្តិការ និងម៉ាស៊ីនអេធីអឹមនៅទូទាំង ២៥ ខេត្ត/រាជធានី។

### សេវាបើកប្រាក់បៀវត្ស

សេវាបើកប្រាក់បៀវត្ស គឺជាសេវាកម្មហិរញ្ញវត្ថុដែល ហត្ថាកសិករ បង្កើតឡើង ដើម្បីជួយសម្រួលដល់សហគ្រាស អង្គការ ក្រុមហ៊ុនឯកជន និងស្ថាប័នរដ្ឋ ក្នុងការបើកបៀវត្សរ៍ជូនបុគ្គលិកមានភាពងាយស្រួល និងឆាប់រហ័សដោយគ្រាន់តែមានគណនីជាមួយហត្ថាកសិករ។ អតិថិជនជាក្រុមហ៊ុន និងនិយោជិតនឹងត្រូវបានផ្តល់ជាមួយ នឹងគណនីប្រាក់សន្សំ ដែលអាចផ្តល់នូវអត្រាការប្រាក់ និងមានអត្ថប្រយោជន៍ផ្សេងៗទៀតជាច្រើន។

### សេវាទូទាត់រហ័ស

សេវាទូទាត់រហ័ស ជាសេវាផ្ទេរប្រាក់ថ្មី ដែលបានផ្តួចផ្តើមដោយធនាគារជាតិនៃកម្ពុជា និងចូលរួមសហការដោយធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដើម្បីផ្តល់ជាភាពងាយស្រួលដល់អតិថិជនក្នុង ការផ្ទេរប្រាក់ ឬទទួលប្រាក់រៀលទៅបណ្តាធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលជាដៃគូទាំងអស់។

### សេវាប្រមូលសាច់ប្រាក់

សេវាប្រមូលសាច់ប្រាក់ គឺជាសេវាកម្មថ្មីដែលបានបង្កើតឡើងដើម្បីបង្កភាពងាយស្រួលដល់អតិថិជនហត្ថាកសិករ ក្នុងការបង់ថ្លៃប្រើប្រាស់ជាប្រចាំថ្ងៃ ឬប្រចាំខែ លើការប្រើប្រាស់អគ្គិសនីជាមួយ EDC ទឹកជាមួយរដ្ឋករទឹកស្វយ័តក្រុងភ្នំពេញ PPWSA ថ្លៃអ៊ីនធឺណែត និងបង់ថ្លៃវិក្កយបត្រផ្សេងៗទៀតតាមរយៈការិយាល័យ ហត្ថាកសិករ ម៉ាស៊ីនអេធីអឹម និងសេវាធនាគារចល័ត។



## ផលិតផលឥណទាន

### ឥណទានទូទៅ

ឥណទានទូទៅ គឺជាប្រភេទផលិតផលឥណទានសម្រាប់អតិថិជនជាលក្ខណៈបុគ្គល សហគ្រាសខ្នាតតូចបំផុត និងសហគ្រាសខ្នាត មធ្យមដែលមានគោលបំណងប្រើប្រាស់ឥណទានច្បាស់លាស់មួយក្នុង ការបង្កើតអាជីវកម្មថ្មី ក៏ដូចជាពង្រីក អាជីវកម្មដែលមានស្រាប់។ អតិថិជន អាចទទួលបានកម្ចី រហូតដល់ ២០០.០០០ ដុល្លារអាមេរិក (សមមូលនឹង រូបិយប័ណ្ណផ្សេង)។ អតិថិជននឹងទទួលបាននូវ លក្ខខណ្ឌឥណទានដែលមានភាពបត់បែនស្រប តាមតម្រូវការ និងលក្ខខណ្ឌរបស់អតិថិជន រួមជាមួយ វិធីបង់ត្រឡប់ងាយស្រួល និងអត្រាការប្រាក់សមរម្យ ក្នុងភាពប្រកួតប្រជែង។

### ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន

ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន គឺជាប្រភេទឥណទាន ផ្តល់ជូនអតិថិជនដែលមានតម្រូវការទិញសម្ភារ ប្រើប្រាស់ផ្សេងៗ ក្នុងគោលបំណងប្រើប្រាស់ផ្ទាល់ខ្លួន ឬប្រើប្រាស់ក្នុងគ្រួសារ។ សម្ភារៈប្រើប្រាស់ផ្សេងៗ រួមមានដូចជាផលិតផលថ្មី ឬផលិតផលមួយទឹក ដែលមានអាយុកាលមិនលើសពី ៥ ឆ្នាំគិតចាប់ពីឆ្នាំផលិត។

### ឥណទានកែលម្អគេហដ្ឋាន

ឥណទានកែលម្អគេហដ្ឋាន ផ្តល់ជូនអតិថិជនដែលមានគោលបំណងជួសជុលកែលម្អ ឬការសង់បំពេញបន្ថែមផ្នែកមួយចំនួននៃគេហដ្ឋាន ដើម្បីបង្កើនស្ថានភាពរស់នៅក្នុងគ្រួសារ។ អតិថិជនអាចស្នើ សុំឥណទានរហូតដល់ទៅ ៣០.០០០ ដុល្លារអាមេរិក (សមមូលនឹងរូបិយប័ណ្ណផ្សេង) ជាមួយអត្រាការប្រាក់សមរម្យ និងរយៈពេលឥណទានបត់បែន ផ្អែកលើទំហំឥណទាន។

### ឥណទានគេហដ្ឋាន

ឥណទានគេហដ្ឋាន ផ្តល់ចំពោះអតិថិជនដែលមានគោលបំណងសាងសង់ ឬទិញគេហដ្ឋានថ្មីដើម្បី រស់នៅ។ អតិថិជនអាចស្នើសុំឥណទាន រហូតដល់ ១០០.០០០ ដុល្លារអាមេរិក (សមមូលនឹងរូបិយប័ណ្ណផ្សេង) រួមជាមួយអត្រាការប្រាក់សមរម្យ និងរយៈពេលឥណទានបត់បែនផ្អែក លើទំហំឥណទាន។

### ឥណទានថែរក្សាអនាម័យ និងបរិស្ថាន

ឥណទានបរិស្ថាន និងសង្គម គឺជាឥណទានដែលផ្តោតទៅលើអតិថិជនដែលមានគោលបំណងបង្កើន កម្រិតជីវភាពកាន់តែប្រសើរឡើង តាមរយៈការប្រើប្រាស់ថាមពលធម្មជាតិ ដូចជាការសាងសង់ឡជីវឧស្ម័ន ទិញបន្ទះអគ្គិសនីសូឡា សាងសង់ បន្ទប់ទឹក ទិញធុងចម្រោះទឹកស្អាត អនាម័យការរស់នៅជាដើម។ អតិថិជន អាចខ្ចីបានរហូតដល់ទៅ ២.៥០០ ដុល្លារអាមេរិក (សមមូលនឹងរូបិយប័ណ្ណផ្សេង ) ដែលមានរយៈពេលកម្ចី រហូតដល់ ២៤ ខែ ជាមួយវិធីបង់ត្រឡប់ងាយស្រួល និងអត្រាការប្រាក់សមរម្យ ។

### ឥណទាននិស្សិតខ្មែរ

ឥណទាននិស្សិតខ្មែរ ផ្តល់ជូនទៅដល់អាណាព្យាបាល ឬសិស្សនិស្សិតនូវជំនួយផ្នែកហិរញ្ញវត្ថុសម្រាប់បន្តការសិក្សានៅកំរិតឧត្តមសិក្សា បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ ឬជំនាញវិជ្ជាជីវៈផ្សេងៗហើយមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុង ការចំណាយទៅលើបង់ថ្លៃសាលា និងការចំណាយផ្សេងៗទៀតនៅក្នុងអំឡុងពេលនៃការសិក្សា។ ឥណទានប្រភេទនេះ អាចស្នើសុំបាន រហូតដល់ ៨.០០០ ដុល្លារអាមេរិក (សមមូលនឹងរូបិយប័ណ្ណផ្សេង) ជាមួយរយៈពេលបង់សង រហូតដល់ ៧ ឆ្នាំ ។




### ឥណទានកាតគ្រី

ឥណទានកាតគ្រី ជាប្រភេទឥណទានដែលនូវផ្តល់កម្ចីឆាប់រហ័សជាមួយលក្ខខណ្ឌងាយស្រួល។ ហត្ថាកសិករ ផ្តល់ជូនទំហំឥណទានរហូតដល់ទៅ ៣០.០០០ ដុល្លារអាមេរិក (សមមូលនឹងរូបិយប័ណ្ណផ្សេង) ដោយគ្រាន់តែដាក់តម្កល់ប័ណ្ណកម្មសិទ្ធិយានយន្តរបស់លោកអ្នកជាទ្រព្យបញ្ចាំ។

### ឥណទានកសិកម្ម

ឥណទានកសិកម្មគឺជាប្រភេទឥណទានដែលផ្តល់ប្រាក់កម្ចីជូនប្រជាកសិករ និងអ្នកជំនួញ ឬអ្នកផ្តល់ សេវាកម្មផ្នែកកសិកម្មដែលមាន គោលបំណងប្រើប្រាស់កម្ចី សម្រាប់ធ្វើការគាំទ្រលើមុខរបរកសិកម្ម សេវាកម្មកសិកម្មផ្សេងៗ ឬប្រើប្រាស់សម្រាប់បង្កបង្កើនទិន្នផលកសិកម្ម នានា។ ឥណទានកសិកម្មបែងចែកជា ៤ ផលិតផលឥណទានរួមមាន ឥណទានកសិកម្មតាមរដូវកាល ឥណទានកសិកម្មចំណូលទៀងទាត់ឥណទាន កសិកម្មបង្កើនទ្រព្យ ឥណទានអាជីវកម្ម និងសេវាកម្មកសិកម្ម។ ចំពោះទំហំឥណទាន អតិថិជន អាចស្នើសុំចាប់ពី ២៥០ ដុល្លារអាមេរិក រហូតដល់ ៥០.០០០ ដុល្លារអាមេរិក (សមមូលនឹងរូបិយប័ណ្ណផ្សេង) ដោយផ្អែកតាមប្រភេទផលិតផលឥណទាននីមួយៗ។

### ឥណទាន HOME FOR CASH

ឥណទាន HOME FOR CASH ជាឥណទានមួយប្រភេទដែលបង្កើតឡើងសម្រាប់អតិថិជនដែលមានចំណូលទៀងទាត់ជាប្រាក់បៀវត្សរ៍ (ប្រាក់ខែ) ហើយមានតម្រូវការប្រើប្រាស់ឥណទាននេះដើម្បីបង្កើនប្រាក់ចំណូលបន្ថែមពីមុខ របរអាជីវកម្ម ឬ ដើម្បីលើកកម្ពស់ លក្ខខណ្ឌរស់នៅ ឱ្យមានភាព ល្អប្រសើរជាងមុន។ ឥណទាននេះតម្រូវឱ្យអតិថិជន មានគេហដ្ឋានដែលកំពុងរស់នៅស្រាប់ ឬដីទំនេរ ដែលទុកសាងសង់លំនៅដ្ឋាននាពេល អនាគតដាក់ជា ទ្រព្យធានា។ ចំពោះទំហំឥណទាន អតិថិជនអាចស្នើសុំរហូតដល់ ៥០.០០០ ដុល្លារអាមេរិក (សមមូលនឹងរូបិយប័ណ្ណផ្សេង) ជាមួយរយៈពេលឥណទានរហូតដល់ ៦០ ខែ (៥ ឆ្នាំ)។

### ឥណទានសង្គម

ឥណទានសង្គម ជាប្រភេទឥណទានដែលបង្កើតឡើងសម្រាប់ជួយគាំទ្រលើសុខមាលភាពនៃសង្គមដោយធ្វើការ ផ្តល់ជូនចំពោះ អតិថិជនដែលស្ថិតនៅក្រោមបន្ទាត់នៃភាពក្រីក្រ ស្ត្រីមេម៉ាយ ឬស្ត្រីដែលងាយរងគ្រោះ ឬក៏អតិថិជនដែលងាយរងគ្រោះដោយសារគ្រោះធម្មជាតិជាដើម។ គោលបំណងនៃការប្រើប្រាស់ឥណទានប្រភេទ ទាំងនេះ គឺដើម្បីធ្វើឱ្យជីវភាពនៃការរស់នៅមានភាពល្អប្រសើរ ធ្វើឱ្យការរស់នៅមានអនាម័យល្អប្រសើរ សម្រាប់ធ្វើការគាំទ្រលើការបន្តការសិក្សារបស់កូនៗ ឬក៏ជាការស្តារជីវភាពឡើងវិញបន្ទាប់ពីការកើតឡើង នៃគ្រោះធម្មជាតិ។ ចំពោះឥណទានសង្គម យើងបានបែងចែកជាប្រភេទ ផលិតផលឥណទាន ៥ប្រភេទផ្សេងៗគ្នារួមមាន៖ ឥណទានទូទៅ ឥណទានបរិស្ថាន ឥណទានសម្រាប់ការសិក្សា ឥណទានសង្គ្រោះ និងឥណទានគាំទ្រស្ត្រី។ ដោយឡែកទំហំឥណទាន គឺផ្អែកទៅតាមប្រភេទនៃឥណទាននីមួយៗ ដោយទំហំខ្ចី អាចចាប់ពី ២៥០ ដុល្លារអាមេរិក រហូតដល់ ២.០០០ ដុល្លារអាមេរិក (សមមូលនឹងរូបិយប័ណ្ណផ្សេង)។

### ឥណទាន HATTHA FIRST CHOICE

ឥណទាន HATTHA FIRST CHOICE ត្រូវបានបង្កើតឡើងជាពិសេសសម្រាប់បុគ្គលិកក្រុមហ៊ុន ឬស្ថាប័ននានា ក៏ដូចជាអតិថិជនដែលមានអាជីវកម្មផ្ទាល់ខ្លួន ដែលមានតម្រូវការទិញទូរស័ព្ទ សម្ភារប្រើប្រាស់ក្នុងផ្ទះ កុំព្យូទ័រ ពីហាងដៃគូអាជីវកម្មរបស់ ហត្ថាកសិករ លីមីតធីត ដោយពុំចាំបាច់មានទ្រព្យបញ្ចាំ។ ទំហំឥណទាននឹងត្រូវបានផ្តល់ជូនរហូតដល់ ៣.៥០០ ដុល្លារអាមេរិក ជាមួយនឹងរយៈពេលរហូតដល់ ១៨ ខែ សម្រាប់ការទិញទូរស័ព្ទ និង រហូតដល់ ២៤ ខែ សម្រាប់សម្ភារផ្សេងទៀត។

### ឥណទាន HATTHA AUTO LOAN

ឥណទាន HATTHA AUTO LOANត្រូវបានបង្កើតឡើងជាពិសេសសម្រាប់អតិថិជនដែលមានតម្រូវការទិញរថយន្តដឹកទំនិញថ្មី ឬមួយទឹកពីបរទេស និងម៉ូតូថ្មីដោយមិនមានទ្រព្យបញ្ចាំក្រៅពីយានយន្ត។ ទំហំឥណទាននឹងត្រូវបានផ្តល់ជូនរហូតដល់ ១០០.០០០ ដុល្លារអាមេរិក សម្រាប់រយៈពេល ៦ឆ្នាំ ចំពោះរថយន្ត និងរហូតដល់ ៤.០០០ ដុល្លារអាមេរិក សម្រាប់រយៈពេល ៤ឆ្នាំ ចំពោះការទិញម៉ូតូ។




# សកម្មភាពសេវាបម្រើអតិថិជន

សេវាបម្រើអតិថិជនគឺជាផ្នែកដ៏សំខាន់ដែលមិនអាចខ្វះបាននៅក្នុងដំណើរប្រតិបត្តិការរបស់ស្ថាប័ននីមួយៗ។ ការសម្រេចចិត្តរបស់អតិថិជនក្នុងការជ្រើសរើសប្រើប្រាស់សេវាកម្មរបស់ស្ថាប័នមួយសម្រាប់រយៈពេលវែងគឺមិនមែនដោយសារការផ្សព្វផ្សាយដែលគួរឱ្យចាប់អារម្មណ៍ ឬខិត្តប័ណ្ណដែលមានពណ៌ចម្រុះនោះទេ ប៉ុន្តែវាគឺជាអ្វីដែលពួកគេត្រូវការពិតប្រាកដ នោះគឺ ផលិតផលដែលមានគុណភាព និងអត្ថប្រយោជន៍ខ្ពស់ ជាមួយការផ្តល់ជូនសេវាកម្មប្រកបដោយភាពរហ័សរហួន និងមានប្រសិទ្ធភាពខ្ពស់។

ហត្ថាកសិករ បានខិតខំប្រឹងប្រែងយ៉ាងយកចិត្តទុកដាក់ក្នុងការផ្តល់ជូនអតិថិជនរបស់ខ្លួននូវសេវាកម្មដ៏ប្រសើរ និងមានភាពឆាប់រហ័សតាមរយៈបុគ្គលិកដែលប្រកបដោយវិជ្ជាជីវៈខ្ពស់នៅទូទាំងប្រទេស ក៏ដូចជាតាមរយៈប្រព័ន្ធឌីជីថលនានារបស់ខ្លួន។

ដោយហេតុថាអតិថិជនរបស់យើងមានគ្រប់ស្រទាប់វណ្ណៈ និងច្រើនប្រភេទ ក្នុងនោះរួមបញ្ចូលទាំងអ្នកប្រកបអាជីវកម្មផ្ទាល់ខ្លួន និងជាបុគ្គលិកក្រុមហ៊ុនផ្សេងៗផងនោះ ហត្ថាកសិករ បានដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធទូរស័ព្ទពិសេសមួយខ្សែបន្ថែមទៀត ដែលអតិថិជនអាចទាក់ទងមកដោយមិនអស់ប្រាក់ (Toll Free: ១៨០០ ២១២ ២២២) ហើយរាល់ការទាក់ទងសាកសួរព័ត៌មានតាមរយៈការបម្រើសេវាតាមទូរស័ព្ទនេះផងដែរ ត្រូវបានបើកដំណើរការជារៀងរាល់ថ្ងៃ គឺពីថ្ងៃ ចន្ទ ដល់ អាទិត្យ និង ពីម៉ោង ៦ ព្រឹក ដល់ ម៉ោង ១០ យប់ ។

យើងជឿជាក់ថាតាមរយៈការខិតខំប្រឹងប្រែងផ្តល់ជូននូវគុណតម្លៃទាំងនេះ រួមនឹងភាពស្មោះត្រង់ដែលយើងមាននៅក្នុងអាជីវកម្ម អតិថិជននឹងចងចាំពី ហត្ថាកសិករ កាន់តែច្បាស់ និងបន្តចែករំលែកនូវបទពិសោធន៍ល្អៗជាក់ស្តែងដែលទទួលបានពីការប្រើប្រាស់សេវានៅហត្ថាកសិករ ទៅកាន់សាច់ញាតិ និងមនុស្សជុំវិញខ្លួនរបស់គេឱ្យទទួលបាននូវបទពិសោធន៍ល្អៗនិងភាពរីកចម្រើនដូចអ្វីដែលគេធ្លាប់ទទួលបានពីហត្ថាកសិករអ៊ីចឹងដែរសមដូចពាក្យស្លោករបស់យើងនោះគឺ "រួមគ្នាសាងអនាគតកាន់តែប្រសើរ"៕

# របាយការណ៍គ្រប់គ្រងធនធានមនុស្ស

ដើម្បីសម្រេចបាននូវគោលដៅ បន្ទាប់ពីក្លាយខ្លួនជាបុត្រសម្ព័ន្ធរបស់ធនាគារ ក្រុងស្រី នាយកដ្ឋានធនធានមនុស្សកែលម្អ លំហូរការងារជ្រើសរើសបុគ្គលិក។ ហត្ថាកសិករ បានត្រៀមខ្លួនជាស្រេចដើម្បីប្រកួតប្រជែងក្នុងទីផ្សារហិរញ្ញវត្ថុតាមរយៈផែនការយុទ្ធសាស្ត្រច្បាស់លាស់។ ឆ្នាំ ២០១៩ ជាឆ្នាំដែលមានការជ្រើសរើសបុគ្គលិកថ្មីច្រើន ដើម្បីគាំទ្រមុខងារទាំងខាងក្នុង និងទាំងខាងក្រៅ។ ជាលទ្ធផល ក្រុមហ៊ុនបានជ្រើសរើសបុគ្គលិកថ្មីចំនួន ១.៥១៤ នាក់ ខណៈពេលដែលអត្រាចាកចេញមានត្រឹមកម្រិត ១០,៣៤%។

### ចំនួនបុគ្គលិកសរុប និងជ្រើសរើសឆ្នាំថ្មី ២០១៩

| បរិយាយ | ២០១៧ | ២០១៨ | ២០១៩ |
|---|---|---|---|
| បុគ្គលិកថ្មី | ៩៧១ | ៩៧១ | ១.៥១៤ |
| បុគ្គលិកសរុប | ៣.០២៤ | ៣.៤៧៦ | ៤.៣៨២ |

### ទំនួលខុសត្រូវចំពោះបុគ្គលិក

| បរិយាយ | ២០១៧ | ២០១៨ | ២០១៩ |
|---|---|---|---|
| អត្រាបុគ្គលិកស្ត្រី | ២៩,៩៩% | ២៨,៤២% | ២៥,៦០% |
| អត្រាថែរក្សាបុគ្គលិក | ៩១,៥៣% | ៨៨,៨៧% | ៨៩,៦៦% |
| រយៈពេលបំពេញការងារជាមធ្យមរបស់បុគ្គលិក(ឆ្នាំ) | ៣,៥១ | ៣,៧១ | ៣,៥៣ |

## កម្មវិធីសិក្សាធិការនិង អភិវឌ្ឍបុគ្គលិក




នៅក្នុងឆ្នាំ ២០១៩ នេះ ហត្ថាកសិករ លីមីតធីត បានចូលរួមចំណែកក្នុងការអភិវឌ្ឍធនធានមនុស្សជូនសង្គមជាតិ ដោយបង្កើតឱ្យមានកម្មវិធីការងារស្ម័គ្រចិត្ត និងកម្មសិក្សាដល់និស្សិត។ កិច្ចការទាំងពីរនេះបានផ្តល់ឱកាសឱ្យនិស្សិតមកពីសាកលវិទ្យាល័យនានាចំនួន ៧៨ នាក់ ទទួលបានបទពិសោធន៍ការងារជាក់ស្តែងពីនិយោជិតរបស់គ្រឹះស្ថាន និងសិក្សាស្រាវជ្រាវអំពីប្រតិបត្តិការរបស់គ្រឹះស្ថាន តាមរយៈការសរសេរនិក្ខេបបទ និងរបាយការណ៍សិក្សាផ្សេងៗ។ កម្មវិធីហ្វឹកហ្វឺនកូនជាងចំនួន ៤៤ នាក់ ត្រូវបានរៀបចំឡើងយ៉ាងត្រឹមត្រូវ ដើម្បីបំពេញកាតព្វកិច្ចផ្លូវច្បាប់តាមប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ក្រៅពីនោះ នាយកដ្ឋានសិក្សាធិការ និងអភិវឌ្ឍន៍ បានរៀបចំអញ្ជើញបុគ្គលិកថ្មីចំនួន ១.៥៤៨ នាក់ ឱ្យចូលរួមសិក្សាវគ្គតម្រង់ទិសការងារទាំង ៤០វគ្គ។ ក្នុងចំណោមបុគ្គលិកថ្មីទាំងនេះ រួមជាមួយបុគ្គលិកសាខាដែលប្តូរតួនាទី សរុបចំនួន ១.៤៨៨ នាក់ ត្រូវបានបណ្តុះបណ្តាលអំពីចំណេះជំនាញមូលដ្ឋានយ៉ាងយកចិត្តទុកដាក់។ បុគ្គលិកជួរមុខដែលទើបម្រើការងារចន្លោះពី ៦ ខែ ទៅ ១២ ខែ ចំនួន ៣៧៦ នាក់ ត្រូវបានអញ្ជើញឱ្យត្រឡប់មកចូលរួមវគ្គសិក្សាចំណេះជំនាញមូលដ្ឋានលើកទី២ ដើម្បីបង្កើនភាពជឿជាក់ ភាពក្លាហាន និង ពង្រឹងសមត្ថភាពក្នុងមុខតំណែងថ្មីរបស់ខ្លួន។ រីឯអ្នកប្រើប្រព័ន្ធធនាគារស្នូល (Flexcube) ចំនួន ១.៣៩៨ នាក់ ទទួលបានការបណ្តុះបណ្តាលថ្មី និងរម្លឹកឡើងវិញស្តីពីការប្រើប្រព័ន្ធឱ្យបានកាន់តែប្រសើរ។

បន្ទាប់ពីបញ្ចប់វគ្គទ្រឹស្តីពីការិយាល័យកណ្តាលបុគ្គលិកថ្មីចំនួន ១.៥២៤ នាក់ ត្រូវបានបញ្ជូនឱ្យចូលរួមក្នុងវគ្គហាត់អនុវត្តការងារជាក់ស្តែងអំឡុងពេលការងារសាកល្បង ដើម្បីហ្វឹកហាត់ និងសម្រួចជំនាញសមត្ថភាពមុននឹងក្លាយជាបុគ្គលិកពេញសិទ្ធិរបស់គ្រឹះស្ថាន។ កម្មវិធីបណ្តុះបណ្តាលស្វ័យប្រវត្តិកម្ម (Online Training) និងស្វ័យសិក្សា (Self E-Learning)បានផ្តល់ឱកាសដល់បុគ្គលិកចំនួន ៨៥៧ នាក់ ឱ្យចូលរួមពីចម្ងាយដើម្បីបង្កើនចំណេះដឹង ពង្រឹងសមត្ថភាព និងកាត់បន្ថយចំណាយលើការបណ្តុះបណ្តាលក្នុងថ្នាក់។ អ្នកគ្រប់គ្រងបុគ្គលិកចាប់ពីប្រធានក្រុមឡើងចំនួន ៥៣៤ នាក់ ត្រូវបានអញ្ជើញឱ្យចូលរួមវគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំដែលបង្រៀនដោយថ្នាក់ដឹកនាំផ្ទៃក្នុង និងគ្រូបណ្តុះបណ្តាលបរទេសដែលមានជំនាញ និងបទពិសោធន៍ខ្ពស់ក្នុងការងារ។

លើសអំពីការសិក្សាជំនាញបច្ចេកទេសផ្ទៃក្នុង បុគ្គលិកសិក្ខាកាមចំនួន ៥០៧ នាក់ ទទួលបានការឧបត្ថម និងលើកទឹកចិត្តឱ្យចូលរួមវគ្គសិក្សាខាងក្រៅ មិនថាថ្នាក់អនុបណ្ឌិតតាមសាកលវិទ្យាល័យ វគ្គខ្លី ឬសិក្ខាសាលាក្នុងប្រទេស-ក្រៅប្រទេស និងស្វ័យប្រវត្តិកម្មសិក្សា ដែលបណ្តុះបណ្តាលដោយគ្រូឧទ្ទេស និងអ្នកប្រឹក្សាយោបល់ជំនាញទាំងថ្នាក់ជាតិ និងអន្តរជាតិផងដែរ។

សិក្ខាកាមនៃបុគ្គលិកបច្ចុប្បន្នចំនួន ៦.៩៥៦ នាក់ ទទួលបានការអញ្ជើញឱ្យចូលរៀនវគ្គសិក្សាខ្លីស្តីពីផលិតផលសេវាកម្មថ្មី និងវគ្គរម្លឹកឡើងវិញនូវគោលនយោបាយ នីតិវិធី គោលការណ៍ប្រតិបត្តិ និងសេចក្តីណែនាំនានា ដើម្បីពង្រឹងគុណភាពការងារ ដែលរៀបចំឡើងដោយគ្រូជំនាញតាមនាយកដ្ឋាន ផ្សេងៗពីការិយាល័យកណ្តាល ខណៈដែលបុគ្គលិកសាខាមានឱកាសសិក្សាលើសពី ៥ ដង លើមុខវិជ្ជាផ្សេងៗក្នុងវគ្គពង្រឹងសមត្ថភាព និងរម្លឹកឡើងវិញ ដែលបង្រៀនដោយថ្នាក់គ្រប់គ្រងនៅតាមតំបន់ និងសាខាសាមី។

ជាយុទ្ធសាស្ត្រ ដើម្បីពង្រឹងវប្បធម៌បង្វឹកផ្ទេរចំណេះជំនាញ និងបង្កើនការចូលរួមដោយការពេញចិត្តរបស់បុគ្គលិក ជាមួយនឹងការអភិវឌ្ឍអ្នកដឹកនាំបន្តវេន កម្មវិធីបង្វឹកប្រឹក្សាយោបល់ត្រូវបានអនុម័តដាក់ជាសូចនាករវាយតម្លៃលទ្ធផលការងារប្រចាំឆ្នាំរបស់អ្នកគ្រប់គ្រង ដែលជាលទ្ធផលកម្មវិធីនេះមានការកើនឡើងលើស ៥ ដង បើប្រៀបធៀបទៅនឹងឆ្នាំមុន (ដោយមានបុគ្គលិកទទួលបានការបង្វឹកចំនួន ១.១២០ នាក់)។ ជារួមបុគ្គលិកសកម្មជាង ៩៨% នៃនិយោជិតសរុប (Training Coverage) ទទួលបានឱកាសសិក្សា និងអភិវឌ្ឍខ្លួន រយៈពេលជាមធ្យមច្រើនជាង ១២ ថ្ងៃ សម្រាប់បុគ្គលិកម្នាក់ៗ (Training Man Day) ក្នុងឆ្នាំ ២០១៩ នេះ។



# ការគ្រប់គ្រងហានិភ័យ

ហត្ថាកសិករ លីមីតធីត បានបង្កើតរចនាសម្ព័ន្ធគ្រប់គ្រងហានិភ័យយ៉ាងរឹងមាំមួយ ដែលសមស្របទៅនឹងទំហំ និងបរិបថអាជីវកម្មរបស់ខ្លួន។ រចនាសម្ព័ន្ធគ្រប់គ្រងហានិភ័យនេះជួយសម្របសម្រួលក្នុងការគ្រប់គ្រងឱ្យមានប្រសិទ្ធភាព ទៅលើការប្រមើលមើល និងការប្រតិបត្តិនៃការគ្រប់គ្រងហានិភ័យ និងដំណើរការនៃការត្រួតពិនិត្យហានិភ័យ។

បន្ទាប់ពីសមាហរណកម្មជាមួយធនាគារអយុធ្យា (ធនាគារក្រុងស្រី) ហត្ថាកសិករ លីមីតធីត មានក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ និងរចនាសម្ព័ន្ធគ្រប់គ្រងហានិភ័យយ៉ាងរឹងមាំ។ ហត្ថាកសិករ លីមីតធីត នាពេលបច្ចុប្បន្នគឺអនុវត្តដោយផ្សារភ្ជាប់ជាមួយនីតិវិធី និងគោលនយោបាយគ្រប់គ្រងហានិភ័យ ពីធនាគារ ក្រុងស្រី ដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួនក្នុងការកំណត់បញ្ហាហានិភ័យ ការវាយតម្លៃហានិភ័យ ការកាត់បន្ថយហានិភ័យ និងការតាមដានហានិភ័យឱ្យស្ថិតនៅក្នុងកម្រិតមួយដែលអាចទទួលយកបាន។

ហត្ថាកសិករ លីមីតធីត អនុវត្តវិធីសាស្ត្រខ្សែបន្ទាត់ការពារបីកម្រិត ដោយអនុលោមតាមស្តង់ដារអន្តរជាតិ និងក្រុមហ៊ុនមេ ដូចខាងក្រោម៖
ខ្សែបន្ទាត់ការពារទី១៖ ផ្នែកជួរមុខ
ខ្សែបន្ទាត់ការពារទី២៖ ការគ្រប់គ្រងហានិភ័យ
ខ្សែបន្ទាត់ការពារទី៣៖ សវនកម្មខាងក្នុង

គណៈកម្មាធិការគ្រប់គ្រង ទ្រព្យសកម្ម អកម្ម និងហានិភ័យកម្រិតក្រុមប្រឹក្សាភិបាល (ARBC) ត្រូវបានបង្កើតឡើង ដើម្បីរៀបចំ និងត្រួតពិនិត្យទៅលើក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ។
គណៈកម្មាធិការគ្រប់គ្រង ទ្រព្យសកម្ម អកម្ម និងហានិភ័យកម្រិតថ្នាក់គ្រប់គ្រង (ALRMC) ជាគណៈកម្មាធិការមួយផ្សេងទៀត ស្ថិតនៅកម្រិតថ្នាក់គ្រប់គ្រង ដើម្បីត្រួតពិនិត្យមើលលើការគ្រប់គ្រងហានិភ័យប្រចាំថ្ងៃ របស់ ហត្ថាកសិករ លីមីតធីត។

នាយកដ្ឋានគ្រប់គ្រងហានិភ័យ ត្រូវបានដំឡើងទៅជា អគ្គនាយកដ្ឋានគ្រប់គ្រងហានិភ័យ ដែលមាននាយកដ្ឋានចំណុះចំនួនពីរ
១- នាយកដ្ឋានគ្រប់គ្រងហានិភ័យឥណទាន និងទីផ្សារ
២- នាយកដ្ឋានគ្រប់គ្រងហានិភ័យប្រតិបត្តិការ និងការកេងបន្លំ។

អគ្គនាយកដ្ឋានគ្រប់គ្រងហានិភ័យ ដើរតួក្នុងខ្សែបន្ទាត់ការពារទី២ និងមានមុខងារឯករាជ្យ ក្នុងការគ្រប់គ្រងហានិភ័យ និងរាយការណ៍ដោយផ្ទាល់ជូន លោកប្រធានអគ្គនាយកគណៈកម្មាធិការគ្រប់គ្រង ទ្រព្យសកម្ម អកម្ម និង ហានិភ័យកម្រិតថ្នាក់គ្រប់គ្រង (ALRMC) និងគណៈកម្មាធិការគ្រប់គ្រង ទ្រព្យសកម្ម អកម្ម



## ហានិភ័យឥណទាន

មុខងារចំបងគឺទទួលខុសត្រូវក្នុងការរៀបចំគោលនយោបាយគ្រប់គ្រងហានិភ័យឥណទាន ការកំណត់លក្ខខណ្ឌសម្រាប់ការវិនិច្ឆ័យលើការអនុម័តឥណទាន ការតាមដាន និងគ្រប់គ្រងហានិភ័យ ការចាត់ថ្នាក់ហានិភ័យឥណទាន និងការគណនាសំវិធានធនលើអ៊ីមភែរមិន (Impairment) ការវិភាគហានិភ័យលើផលបត្រឥណទានដោយមានការផ្តល់ជាអនុសាសន៍ និងការចុះទៅត្រួតពិនិត្យឥណទានដោយឯករាជ្យនៅសាខា។

## ហានិភ័យប្រតិបត្តិការ

ក្រុមការងារផ្នែកហានិភ័យប្រតិបត្តិការ អនុវត្តការងាររបស់ខ្លួនដើម្បីធានាថាមានផលប៉ះពាល់មកលើ ហត្ថាកសិករ លីមីតធីត តិចបំផុតអំពី រាល់ព្រឹត្តិការណ៍នៃការបរាជ័យ ដែលកើតមានឡើងដោយសារ កត្តាខាងក្នុង និង/ឬខាងក្រៅ ឬដោយការដាច់ចរន្ត ឬដាច់បណ្តាញ។ ហត្ថាកសិករ លីមីតធីត តែងតែអនុវត្តជាប្រចាំទៅលើ ការវាយតម្លៃដោយខ្លួនឯងលើហានិភ័យ និងការគ្រប់គ្រង (RCSA) ការតាមដានសូចនាករហានិភ័យសំខាន់ៗ (KRIs) ធៀបនឹងកម្រិតកំណត់ការធ្វើរបាយការណ៍ឧប្បត្តិហេតុហានិភ័យប្រតិបត្តិការ (Operational risk incident) និងការធ្វើតេស្តជាប្រចាំទៅលើផែនការនិរន្តរភាពអាជីវកម្ម (BCP)។ ការដាក់ឱ្យប្រើប្រាស់ផលិតផលសេវាកម្មថ្មីៗ និងការកែសម្រួលផលិតផលសេវាកម្មដែលមានស្រាប់ ឬការកែសម្រួលដំណើរការ ឬការកែសម្រួលផ្នែកបច្ចេកវិជ្ជា គឺតម្រូវឱ្យធ្វើការវាយតម្លៃហានិភ័យឱ្យបានយ៉ាងល្អិតល្អន់ ដើម្បីការពារហានិភ័យ និងកាត់បន្ថយហានិភ័យចម្បងៗ។

## ហានិភ័យទីផ្សារ

ហានិភ័យទីផ្សារ មានន័យថាគឺជាការខាតបង់របស់ ហត្ថាកសិករ លីមីតធីត បណ្តាលមកពីការប្រែប្រួលប៉ារ៉ាម៉ែត្រ (តម្លៃ ឬអត្រា) លើទីផ្សារ ដែលអាចកើតមាននូវហានិភ័យក្នុងបញ្ជីជួញដូរ និង/ឬក្នុងបញ្ជីដែលមិនជួញដូរ ដែលមាននៅ ក្នុងតារាងតុល្យការ និងក្រៅតារាងតុល្យការ។ ទោះបីជាយ៉ាងណាក៏ដោយ ហត្ថាកសិករ លីមីតធីត ប្រឈមមុខនឹងហានិភ័យតែមួយប៉ុណ្ណោះ គឺហានិភ័យលើបញ្ជីមិនជួញដូរ ដែលរួមមានដូចជា ហានិភ័យអត្រាការប្រាក់ និងហានិភ័យអត្រាប្តូរប្រាក់។ គោលនយោបាយហានិភ័យទីផ្សារ. កម្រិតកំណត់ហានិភ័យ និងឧបករណ៍វាស់វែងហានិភ័យ ត្រូវបានដាក់ឱ្យប្រើប្រាស់ និងកំពុងអនុវត្ត។

## ហានិភ័យសាច់ប្រាក់ងាយស្រួល

ហត្ថាកសិករ លីមីតធីត ទទួលស្គាល់សារសំខាន់នៃការផ្លាស់ប្តូរបទបញ្ញត្តិ និងការគ្រប់គ្រង ហានិភ័យសន្ទនីយភាព ដែលសមស្របទៅតាមលក្ខខណ្ឌទីផ្សារ និងកម្រិតហានិភ័យដែលអាចទទួលយកបាន។ ដូច្នេះ ហត្ថាកសិករ លីមីតធីត ដាក់ឱ្យមានគោលនយោបាយហានិភ័យសាច់ប្រាក់ងាយស្រួល ឧបករណ៍វាស់វែងដែលគ្រប់គ្រាន់. ការតាមដានកម្រិតសន្ទនីយភាព. ការវិភាគនិន្នាការ ឬឥរិយាបថសន្ទនីយភាព. និងការធ្វើស្រ្តេសតេស្ត (Stress Testing)។ ហត្ថាកសិករ លីមីតធីត រហូតមកដល់ពេលនេះបានរក្សា អនុបាតគ្របខណ្ឌសន្ទនីយភាព (LCR) ដោយបូកបន្ថែមការការពារខាងក្នុង ពីលើការការកំណត់ដោយបទបញ្ញត្តិ។



# ៨. ការត្រួតពិនិត្យផ្ទៃក្នុង និងសវនកម្មផ្ទៃក្នុង

បន្ទាប់ពីការរួមបញ្ចូលគ្នាជាមួយនឹងធនាគារអយុធ្យា (ក្រុងស្រី) ហត្ថាកសិករ មានរចនាសម្ពន្ធក្នុងការគ្រប់គ្រងហានិភ័យនិងក្របខ័ណ្ឌការត្រួតពិនិត្យព្ទផ្ទៃក្នុងកាន់តែរឹងមាំ។ ហត្ថាកសិករ បានរៀបចំស្របតាមគោលការណ៍និងនីតិវិធីគ្រប់គ្រងហានិភ័យនៃធនាគារក្រុងស្រី ដើម្បីពង្រឹងសមត្ថភាពក្នុងការកំណត់ វាយតម្លៃ កាត់បន្ថយ និងត្រួតពិនិត្យហានិភ័យឱ្យស្ថិតក្នុងកម្រិតដែលអាចទទួលយកបាន។ ហត្ថាកសិករ បានបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដ៏ច្បាស់លាស់ស្របទៅតាមការអនុវត្តអន្តរជាតិដែលរួមមាន "បន្ទាត់ការពារ៣ជាន់": អាជីវកម្ម ការប្រតិបត្តិតាម និងសវនកម្មផ្ទៃក្នុង។

ផ្នែកទាំង៣នេះសហការគ្នាតាមរយៈនីតិវិធីការងារដែលបានធ្វើឡើងសម្រាប់កម្រិតនីមួយៗ។ សវនកម្មផ្ទៃក្នុងនៃ ហត្ថាកសិករ ទទួលខុសត្រូវក្នុងការវាយតម្លៃលើភាពគ្រប់គ្រាន់និងត្រឹមត្រូវនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរួមទាំងពិនិត្យមើលការប្រតិបត្តិតាមរបស់ស្ថាប័នទៅនឹងបទប្បញ្ញត្តិនិងច្បាប់ទម្លាប់នានាផងដែរ ហើយរាយការណ៍ដោយឯករាជ្យទៅប្រធានគណៈកម្មាធិការសវនកម្មនៃក្រុមប្រឹក្សាភិបាល និងសវនកម្មផ្ទៃក្នុងនៃធនាគារក្រុងស្រីនិងរាយការណ៍ជាលក្ខណៈរដ្ឋបាលទៅកាន់ប្រធានអគ្គនាយកនៃ ហត្ថាកសិករ ផងដែរ។

សកម្មភាពសវនកម្មផ្ទៃក្នុងមានភាពឯករាជ្យមិនលម្អៀងក្នុង ការធានាអះអាងនិងប្រឹក្សាយោបល់ដែលត្រូវបាន រៀបចំឡើងក្នុងគោលបំណងបន្ថែមតម្លៃនិងធ្វើឱ្យប្រសើរឡើងទៅលើប្រតិបត្តិការរបស់ហត្ថាកសិករ។ សវនកម្មផ្ទៃក្នុងជួយ ហត្ថាកសិករ ក្នុងការសម្រេចគោលបំណងតាមរយៈការផ្តល់នូវវិធីសាស្ត្រវាយតម្លៃបែបប្រព័ន្ធនិងមានវិន័យនិងជួយធ្វើឱ្យប្រសើរឡើងទៅលើប្រសិទ្ធភាពនៃដំណើរការការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យ និងដំណើរការអភិបាលកិច្ច។

សកម្មភាពសនវកម្មផ្ទៃក្នុងនឹងមិនត្រូវបានរារាំងពីផ្នែកណាមួយនៅក្នុងអង្គភាពរួមមានការជ្រើសរើសក្នុងការធ្វើសវនកម្ម វិសាលភាព នីតិវិធី ភាពញឹកញាប់ពេលវេលា ឬមាតិកាក្នុងការរាយការណ៍ ដើម្បីរក្សាឱ្យមានឯករាជ្យភាពនិងសុក្រឹតភាពតាមការចាំបាច់។ សវនករផ្ទៃក្នុងមិនត្រូវត្រួតពិនិត្យលើផ្នែកឬនាយកដ្ឋានដែលជាកន្លែងមានសាច់ញាតិរបស់ពួកគាត់កំពុងបម្រើការងារឬជាកន្លែងដែលសវនករផ្ទៃក្នុងធ្លាប់ធ្វើការយ៉ាងហោចណាស់ក្នុងរយៈពេល ១ ឆ្នាំ។

សនវករផ្ទៃក្នុង ត្រូវមានឯករាជ្យភាពពីប្រតិបត្តិការប្រចាំថ្ងៃនិងត្រូវចៀសវាងការចូលរួមក្នុងសកម្មភាពដែលអាចត្រូវបានគេឃើញថាប៉ះពាល់លទ្ធភាពរបស់ពួកគាត់ក្នុងការផ្តល់សេវាកម្មដោយឯករាជ្យភាពនិងសុក្រិតភាព។ ក្នុងការធ្វើសវនកម្ម សវនករផ្ទៃក្នុងមិនមានតួនាទីឬសិទ្ធិលើសពីសកម្មភាពណាមួយដែលត្រូវត្រួតពិនិត្យនោះទេ។

# ការប្រតិបត្តិតាម

មុខងារប្រតិបត្តិតាមមិនពាក់ព័ន្ធនឹងប្រតិបត្តិការអាជីវកម្មនោះទេ មុខងារប្រតិបត្តិតាមត្រូវបានចាត់តាំងឱ្យធ្វើការរាយការណ៍ផ្ទាល់ទៅកាន់គណៈកម្មាធិការក្រុមប្រឹក្សាភិបាល។ នាយកដ្ឋានប្រតិបត្តិតាមទទួលខុសត្រូវក្នុងការត្រួតពិនិត្យទៅលើប្រតិបត្តិការ ដើម្បីធានានូវការអនុវត្តតាមច្បាប់ប្រឆាំងការលាងសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម តាមរយៈការអភិវឌ្ឍនូវគោលការណ៍ស្គាល់អតិថិជន (KYC policy) ដែលស្របជាមួយបទបញ្ញត្តិ និងការតម្រូវពី ហ្គ្រុប។

នៅក្នុងឆ្នាំ ២០១៩ យើងបានរៀបចំដាក់ឱ្យមាននូវប្រព័ន្ធត្រួតពិនិត្យព័ត៌មានអតិថិជន/ដៃគូពាណិជ្ជកម្ម ជាមួយនឹងទិន្នន័យផ្ទាល់ពី DowJones និងប្រព័ន្ធតាមដានបន្តប្រតិបត្តិការអតិថិជន ដើម្បីពង្រឹងលើការអនុវត្តតាមការតម្រូវលើប្រឆាំងការលាងសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។មុខងារប្រតិបត្តិតាមធ្វើការវាយតម្លៃលើកម្រិតនៃការអនុវត្តតាមបទប្បញ្ញត្តិ និងផលប៉ះពាល់ទូទៅពីបទប្បញ្ញត្តិដទៃទៀតដែលពាក់ព័ន្ធ និងការតម្រូវពី ហ្គ្រុប ដែលមានផលប៉ះពាល់ ប្រតិ-បត្តិការរបស់ ហត្ថាកសិករ។ ការអនុវត្តតាមការផ្លាស់ប្តូរនៃបទបញ្ញត្តិថ្មីៗ ដែលនៅសេសសល់ ត្រូវបានធ្វើការតាមដានពីមុខងារប្រតិបត្តិតាម និងធ្វើការផ្សព្វផ្សាយនៃបច្ចុប្បន្នភាពទៅកាន់ថ្នាក់គ្រប់គ្រង និងក្រុមប្រឹក្សាភិបាលផងដែរ។ របាយការណ៍ដែលរកឃើញលើសកម្មភាពអាជីកម្ម និងប្រតិបត្តិការនៃការប្រតិបត្តិតាម ក៏រាយការណ៍ផងដែរទៅក្រុមប្រឹក្សាភិបាល។

ការបញ្ជ្រាបចូលនូវវប្បធម៌ប្រតិបត្តិតាមទៅកាន់បុគ្គលិកចាប់ពីចំណាប់ផ្តើមនៃការចូលបម្រើការងារជាមួយហត្ថាកសិករ តាមរយៈវគ្គបណ្តុះបណ្តាលរួមមានក្រមប្រតិបត្តិ (ដែលយើងហៅថា ក្រមប្រតិបត្តិសីលធម៌ និងគោលការណ៍ S&L) ទំនាស់ផលប្រយោជន៍ ការប្រឆាំងនឹងអំពើពុករលួយ ការប្រឆាំងនឹងការលាងសម្អាតប្រាក់។ មុខងារប្រតិបត្តិតាមក៏រាយការណ៍ផងដែរនូវរបាយការណ៍ត្រួតពិនិត្យផ្ទាល់ដល់ទីកន្លែង ភាពខ្វះខាត និងការមិនប្រតិបត្តិតាម។

# ក្រមប្រតិបត្តិសីលធម៌ និងគោលការណ៍

គ្រប់បុគ្គលិកទាំងអស់ត្រូវមានការប្តេជ្ញាចិត្តដើម្បីឱ្យទទួលបានជោគជ័យទៅលើលទ្ធផលការងារ ទោះបីជាយើងត្រូវចំណាយពេលវេលា និងកំលាំងកាយចិត្តក៏ដោយ។ ការប្តេជ្ញារបស់បុគ្គលិកគឺត្រូវបានផ្តល់តម្លៃគាំទ្រ និងលើកទឹកចិត្តដើម្បីសម្រេចបាននូវគោលដៅ និងគោលបំណងរបស់បុគ្គលិក។

សកម្មភាពនៃការប្តេជ្ញាខ្ពស់ត្រូវបានកំណត់ដូចខាងក្រោម៖
- បណ្តុះអារម្មណ៍ស្រលាញ់ ហត្ថាកសិករ
- ខិតខំប្រឹងប្រែងធ្វើការទៅតាមតួនាទី និងភារកិច្ចដែលបានចាត់តាំង
- មិនរួញរាក្នុងការឆ្លើយតប និងចូលរួមគ្រប់សកម្មភាពដែលចាត់តាំងដោយហត្ថាកសិករ
- បញ្ចេញសមត្ថភាពរបស់ខ្លួនក្នុងការអនុវត្តការងារ
- រៀនសូត្រនូវចំណេះដឹង និងជំនាញដើម្បីអភិវឌ្ឍខ្លួនឱ្យទាន់សម័យកាល។

លើសពីនេះទៅទៀត បុគ្គលិក ហត្ថាកសិករ ត្រូវសម្រេបខ្លួនទៅនឹងក្រមសីលធម៌រួមមាន៖
- គោរពតាមច្បាប់ និងបទប្បញ្ញត្តិ ដែលគ្រប់គ្រងអាជីវកម្មរបស់យើង
- ត្រូវមានភាពស្មោះត្រង់ ស្មើភាព និងទុកចិត្តបាន ក្នុងរាល់សកម្មភាព និងទំនាក់ទំនងរបស់អ្នកសម្រាប់ ហត្ថាកសិករ
- ជៀសវាងទំនាស់ផលប្រយោជន៍រវាងការងារ និង កិច្ចការផ្ទាល់ខ្លួន
- ជម្រុញនូវបរិយាកាសស្មើភាពក្នុងការងាររហូតដល់គ្រប់សមាជិកនៃសហគមន៍ហត្ថាកសិករដទៃទៀត
- ខិតខំបង្កើតសុវត្ថិភាពនៅកន្លែងធ្វើការ និងចូលរួមក្នុងការការពារបរិស្ថាន
- តាមរយៈភាពជាអ្នកដឹកនាំនៅគ្រប់ជាន់ថ្នាក់ ត្រូវរក្សានូវវប្បធម៌មួយដែលការអនុវត្តក្រមសីលធម៌ត្រូវបានទទួលស្គាល់ ឱ្យតម្លៃ និងជាគំរូដល់បុគ្គលិក។

បុគ្គលិកត្រូវប្រកាន់ខ្ជាប់គ្រប់ពេលវេលានូវក្រមសីលធម៌ ក្នុងពេលដែលយើងបម្រើការងារនៅ ហត្ថាកសិករ។ សេចក្តីជូនដំណឹងត្រូវបានប្រកាសទៅបុគ្គលិកទាំងអស់ ដើម្បីឱ្យប្រកាន់ភ្ជាប់នូវក្រមទាំងនេះសម្រាប់អនុវត្តការងារ។ អ្នកគ្រប់គ្រងមានភារកិច្ចក្នុងការអង្កេត និងធានានូវការអនុវត្តនូវក្រមសីលធម៌របស់បុគ្គ-លិក។ អ្នកបំពានក្រមនេះត្រូវទទួលរងទណ្ឌកម្មដែលរួមបញ្ចូលទាំងការបញ្ឈប់ពីការងារជាដើម។

បុគ្គលិកនឹងត្រូវបានស្នើសុំឱ្យទទួលស្គាល់ ទៅលើការយល់ដឹងពីក្រមសីលធម៌ដែលគ្រប់បុគ្គលិកទាំអស់ដែលស្ថិតក្រោម សម្ព័ន្ធអាជីវកម្មហិរញ្ញវត្ថុក្រុងស្រ៊ី (Krungsri Financial Business Group) ត្រូវតែអនុវត្តតាមក្រមប្រតិបត្តិសីលធម៌ និងគោលការណ៍ក្រុមហ៊ុន (Corporate Policies) និងលើកឡើងពីកង្វល់ទៅលើការបំពានច្បាប់ ឬការប្រព្រឹត្ត ឬគោលនយោបាយទៅកាន់ថ្នាក់គ្រប់គ្រង ឬ Ombudserson ឬ នាយកដ្ឋានប្រតិបត្តិតាម ឬនាយកដ្ឋានផ្នែកច្បាប់។

ក្រមសីលធម៌ដូចដែលបានដាក់ចេញគឺមិនគ្រប់ជ្រុងជ្រោយទាំងអស់ទេ ហើយវាត្រូវកំណត់ជាការងាររបស់បុគ្គលិកទាំងអស់ពីគ្រប់កម្រិត ដើម្បីធ្វើការវិនិច្ឆ័យទៅលើសកម្មភាពត្រឹមត្រូវទៅតាមកាលៈទេសៈណាមួយ។

# ឈ. របាយការណ៍នៃការគ្រប់គ្រងធុរកិច្ចសង្គម

ហត្ថាកសិករ គឺជាគ្រឹះស្ថានហិរញ្ញវត្ថុមួយឈានមុខគេ នៅក្នុងប្រទេសកម្ពុជា ដែលបានបម្រើ និងផ្ដល់សេវាកម្មហិរញ្ញវត្ថុជូនប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានអស់រយៈពេលជាង ២៦ ឆ្នាំ (ពីឆ្នាំ ១៩៩៤) ដោយគិតទាំងការជួយផ្ដល់ទុនដល់ស្ត្រីក្រីក្រ ។ល។ ហត្ថាកសិករ គឺជាក្រុមហ៊ុនរកប្រាក់ចំណេញដែលបានដំណើរការអាជីវកម្មស្របជាមួយនឹងការសម្រេចនូវបេសកកម្មសង្គមរបស់ក្រុមហ៊ុន ពោលគឺការប្ដេជ្ញាចិត្តក្នុងការចូលរួមចំណែកនៅក្នុងប្រទេសកម្ពុជាតាមរយៈសកម្មភាពសង្គមនានា និងការប្រតិបត្តិនូវការចូលរួមក្នុងសកម្មភាពសង្គមជាមួយនឹងប្រជាពលរដ្ឋនៅតាមសហគមន៍ និងជាមួយនឹងសាធារណជនទូទៅ។

## សកម្មភាពទំនួលខុសត្រូវសង្គម

ដើម្បីគាំទ្របេសកកម្ម និងទស្សនវិស័យរបស់ ហត្ថាកសិករ យើងបានខិតខំធ្វើសកម្មភាពទំនួលខុសត្រូវសង្គមជាច្រើនដើម្បីបង្ហាញអំពីឆន្ទៈរបស់ ហត្ថាកសិករ ក្នុងគាំទ្រដល់សហគមន៍ និងសង្គមជាតិ។ ហត្ថាកសិករ បានបង្កើតសកម្មភាពទទំនួលខុសត្រូវសង្គមនៅក្នុងវិស័យ ៣ សំខាន់ៗ ដូចខាងក្រោម៖

### ធ្វើឱ្យប្រសើរឡើងចំណេះដឹងហិរញ្ញវត្ថុ

ហត្ថាកសិករ លីមីតធីត បានចូលរួមឧបត្ថម្ភថវិកាផ្ទាល់ខ្លួនសម្រាប់ព្រឹត្តិការណ៍ចំនួន ២ នៃយុទ្ធនាការអប់រំរបស់ធនាគារជាតិនៃកម្ពុជា និងមួយព្រឹត្តិការណ៍ទៀត ដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់វិស័យអប់រំនៅកម្ពុជា។ ក្រៅពីនេះ សាខាហត្ថាកសិករ ទូទាំងប្រទេសក៏បានរៀបចំកម្មវិធីទំនួលខុសត្រូវសង្គម ចំនួន ៧៤ កម្មវិធី ដែលមានអ្នកចូលរួមសរុប ២.២៤៧ នាក់ នៃបុគ្គលិកហត្ថាកសិករ ដែលសកម្មភាពនោះគឺការផ្ដល់សម្ភារៈសិក្សាដល់សិស្សានុសិស្សសាលាបឋម និងនិស្សិតនៃសកលវិទ្យាល័យមួយចំនួន ហើយបានផ្ដល់ឱ្យពួកគេនូវចំណេះដឹងហិរញ្ញវត្ថុជាមូលដ្ឋាន។ សកម្មភាពទាំងនេះ មានគោលបំណងគាំទ្រការផ្ដល់សម្ភារៈសិក្សាគ្រប់គ្រាន់ដល់សិស្ស និស្សិត ដើម្បីធ្វើឱ្យប្រសើរឡើងនូវវិស័យអប់រំនៅកម្ពុជា ជាពិសេសតាមតំបន់ជនបទ និងលើកទឹកចិត្តសិស្សានុសិស្សឱ្យខិតខំរៀនសូត្រ ព្រមទាំង បង្ហាញពីកិច្ចសហប្រតិបត្តិការល្អរវាង ហត្ថាកសិករ និងសហគមន៍ រួមទាំងចែករំលែកសេចក្ដីស្រឡាញ់តាមរយៈសកម្មភាពទំនួលខុសត្រូវសង្គម។

### ពង្រឹងផ្នែកសុខភាព និងសុវត្ថិភាព

ហត្ថាកសិករបានរៀបចំកម្មវិធីចំនួន ២៤ ក្រោមក្របខ័ណ្ឌសុខភាព និងសុវត្ថិភាពដូចជាការបរិច្ចាគឈាម ផ្ដល់អាហារ និងសម្លៀកបំពាក់ដល់អ្នកបើកស៊ីក្លូ ការបរិច្ចាគគ្រឿងឧបភោគដល់ក្រុមគ្រួសារក្រីក្រនៅតំបន់ជនបទ និងការបរិច្ចាគគ្រែអ្នកជំងឺដល់មន្ទីរពេទ្យ ដោយមានបុគ្គលិក ហត្ថាកសិករ ចូលរួមសរុបចំនួន ១.១៩០ នាក់។ គោលបំណងក្នុងសកម្មភាពទាំងមូលគឺដើម្បីបង្ហាញនូវការប្ដេជ្ញាចិត្តរបស់ហត្ថាកសិករឆ្ពោះទៅរកការកែលម្អសុខភាព និងសុខុមាលភាពនៅកម្ពុជា និងដើម្បីលើកកម្ពស់ការយល់ដឹងអំពីអត្ថប្រយោជន៍នៃការបរិច្ចាគឈាមដល់និយោជិត និងសាធារណជន ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវសុខភាពប្រជាជននៅតាមជនបទ និងកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។

### ការពារផ្នែកបរិស្ថាន

ហត្ថាកសិករ លីមីតធីត បានរៀបចំព្រឹត្តិការណ៍ចំនួន ១៤ សម្រាប់បរិស្ថាន ដែលក្នុងនោះមានដូចជាការប្រមូលសំរាមតាមដងស្ទឹងសៀមរាប តាមផ្លូវជាតិនានា និងតាមរមណីយដ្ឋាន ការដាំដើមឈើនៅបរិវេណសាលារៀន និងវត្តអារាម និង ការកសាងផ្លូវជាមួយអ្នកភូមិនៅក្នុងសហគមន៍ ក្នុងការិយាល័យប្រតិបត្តិការរបស់ហត្ថាកសិករ ដែលមានអ្នកចូលរួមសរុប ១.០៤៩នាក់ នៃបុគ្គលិកហត្ថាកសិករទាំងអស់ទូទាំងប្រទេស។ គោលបំណង គឺដើម្បីអភិរក្ស និងថែរក្សាបរិស្ថានស្អាត និងដើម្បីបង្ហាញការយល់ដឹងដល់សាធារណជនឱ្យយកចិត្តទុកដាក់ខ្ពស់ចំពោះបរិស្ថាន។

## សូចនាករសមិទ្ធិផលបរិស្ថាន

ដើម្បីរក្សាឱ្យបាននិងបន្តការកាត់បន្ថយផលប៉ះពាល់បរិស្ថាន ហត្ថាកសិករ នៅតែបន្តការតាមដានលើការប្រើប្រាស់នូវ ធនធានមួយចំនួនដោយត្រូវធ្វើការប្រៀបធៀបជាមួយទិន្នន័យនៃការប្រើប្រាស់ពីឆ្នាំមុន។
នៅឆ្នាំ ២០១៩ ការប្រើប្រាស់ធនធានមួយចំនួនពោល គឺមានការថយចុះលើបរិមាណនៃការប្រើប្រាស់របស់បុគ្គលិកម្នាក់ៗមានដូចបង្ហាញក្នុងតារាងខាងក្រោម៖

| ល.រ. | ចំណាយ | ២០១៨ | ២០១៩ |
|---|---|---|---|
| ១ | ទឹក (គីប) | ១២,៩០ | ១០,៩៧ |
| ២ | ក្រដាស (សន្លឹក) | ៧,៨០ | ៧,១៤ |
| ៣ | ក្រដាសអនាម័យ (ដុំ) | ៥,៥៨ | ៤,៦៩ |
| ៤ | ភ្លើងអគ្គិសនី (គីឡូវ៉ាត់) | ១.០៤២,៩៤ | ៩៣៦,៤៥ |
| ៥ | ប្រេង (លីត្រ) | ០,៦៨ | ០,៤១ |
| ៦ | ប្រេងសាំង (លីត្រ) | ៧,១៦ | ៨,៦៧ |
| ៧ | ប្រេងម៉ាស៊ូត (លីត្រ) | ៣០,២០ | ៣៣,៣៨ |

# ៣- របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុម ប្រឹក្សាភិបាលមានក្ដីសោមនស្សរីករាយ ក្នុងការបង្ហាញជូននូវរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល និងរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ក្រុមហ៊ុន ហត្ថា-កសិករ លីមីតធីត (ហៅកាត់ថា "ក្រុមហ៊ុន" ឬ "អេច ខេ អិល") និងក្រុមហ៊ុនបុត្រសម្ព័ន្ធ (ជារួមហៅកាត់ថា "សម្ព័ន្ធក្រុមហ៊ុន និងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែករបស់ ក្រុមហ៊ុន (ហៅកាត់ថា "របាយការណ៍ហិរញ្ញវត្ថុ សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៩។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្ដល់សេវាប្រាប់កម្ចី សេវាប្រាក់សន្សំ និងសេវាហិរញ្ញវត្ថុផ្សេងៗទៀតជាពិសេសផ្ដល់ដល់ស្ត្រី និងគ្រួសារដែលមានប្រាក់ចំណូលទាប តាមរយៈទីស្នាក់ការកណ្ដាលនៅរាជធានីភ្នំពេញ និងសាខាតាមបណ្ដាខេត្តផ្សេងៗទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ត្រូវបានបង្ហាញនៅក្នុងរបាយ-ការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗរួម និងដាច់ដោយឡែក នៅលើទំព័រ១២ និង១៨។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តទៅលើទុនបម្រុង និងសំវិធានធន នៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## ភាគលាភ

នៅក្នុងការិយបរិច្ឆេទនេះសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ពុំបានប្រកាសភាគលាភទេ (២០១៨ : ពុំមាន)។

## ដើមទុន

នៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៩ ធនាគារជាតិ នៃកម្ពុជា បានអនុម័តសំណើររបស់ក្រុមហ៊ុនក្នុងការបង្កើនទុនចំនួន ៤០ លានដុល្លារអាមេរិក ពី ៧៥ លានដុល្លារអាមេរិក ដល់ ១១៥ លានដុល្លារអាមេរិក។ ការកែតម្រូវលក្ខន្តិកៈរបស់ក្រុមហ៊ុន ត្រូវបានអនុម័តដោយក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ ២០២០។

## ការលុបចេញពីបញ្ជី និងសំវិធានធនលើទ្រព្យសកម្មហិរញ្ញវត្ថុ

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមាន មូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាសកម្មភាពដែលពាក់ព័ន្ធនឹងការលុបចេញពីបញ្ជីលើទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមិនមានការរំពឹងទុកថាអាចប្រមូលបានមកវិញនូវលំហូរសាច់ប្រាក់តាមកិច្ចសន្យាទាំងស្រុង ឬចំណែកណាមួយ និងបានធ្វើសំវិធានធនលើការខាតបង់ពីការធ្លាក់ចុះតម្លៃទៅលើទ្រព្យសកម្មហិរញ្ញវត្ថុ ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថា រាល់ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានដឹងថានឹងមិនមានការរំពឹងទុកថាអាចប្រមូលបានមកវិញ នូវលំហូរសាច់ប្រាក់តាមកិច្ចសន្យា ត្រូវបានលុបចោល និងបានធ្វើសំវិធានធនគ្រប់គ្រាន់ ចំពោះការខាតបង់ពីការធ្លាក់ចុះតម្លៃទៅលើទ្រព្យសកម្មហិរញ្ញវត្ថុ ។

## ការលុបចេញពីបញ្ជី និងសំវិធានធនលើទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកលើការយល់ដឹង ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ ណាមួយដែលនឹងមានផលប៉ះពាល់ជាសារវន្តដល់ចំនួនទឹកប្រាក់នៃការធ្វើសំវិធានធនលើការខាតបង់ពីការធ្លាក់ ចុះតម្លៃទៅលើទ្រព្យសកម្មហិរញ្ញវត្ថុ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន នោះទេ។

## ទ្រព្យសកម្ម

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមាន មូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មទាំងអស់ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់សម្ព័ន្ធ ក្រុមហ៊ុន និងក្រុមហ៊ុន ដែលទំនងជាមិនអាចទទួលស្គាល់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ត្រូវបានកាត់បន្ថយ ឲ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចប្រមូលបានជាក់ស្តែង។
នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មនៅក្នុងរបាយ-ការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវនោះទេ។

## វិធីសាស្រ្តកំណត់តម្លៃ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹង ធ្វើឲ្យមានផលប៉ះពាល់ដល់ការអនុវត្តវិធីសាស្រ្តដែលមានកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុល នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវ និងមិនសមស្របនោះទេ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗទៀត

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមាន៖
(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ដែលកើតមានឡើងចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទ ក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាមួយឡើយ ក្រៅអំពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។
(ខ) បំណុលយថាហេតុណាមួយ ដែលកើតមានឡើងចំពោះសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទ ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន។
ក្រុមប្រឹក្សាភិបាលមានមតិថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ដែលត្រូវសង ឬអាចនឹងត្រូវសងក្នុងរយៈពេល ១២ ខែបន្ទាប់ពីចុងការិយបរិច្ឆេទនេះ ដែលនឹងធ្វើឲ្យមាន ផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ក្នុងការបំពេញ កាតព្វកិច្ចរបស់ខ្លួន ដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់។

## ការផ្លាស់ប្តូរហេតុការណ៍

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលមិនបានរៀបរាប់នៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ដែលនឹងអាចបណ្តាលឲ្យមានតួលេខនៃចំនួនណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវនោះទេ។

## ប្រតិបត្តិការមិនប្រក្រតី

ក្រុមប្រឹក្សាភិបាលមានមតិថា លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយ ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។
ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទ រហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានប្រតិបត្តិការ ឬព្រឹត្តិ-ការណ៍ណាមួយ ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើងដែលអាចនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

## ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទនៃរបាយការណ៍

ពុំមានព្រឹត្តិការណ៍ជាសារវន្តដែលបានកើតឡើង ក្រោយកាលបរិច្ឆេទនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ដែលតម្រូវឲ្យមានការបង្ហាញ ឬកែតម្រូវនោះទេ ក្រៅពីការបង្ហាញដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល ដែលបានបម្រើការនៅក្នុងការិយបរិច្ឆេទ និងគិតត្រឹមកាលបរិច្ឆេទនៃ របាយការណ៍នេះ រួមមាន៖
• លោក Dan HARSONO ជាប្រធានក្រុមប្រឹក្សាភិបាល និងជាប្រធានផ្នែកលក់ និងបម្រើអតិថិជនរបស់ Krungsri
• លោក Rohit KHANNA ជាអភិបាល និងជាប្រធានក្រុមផ្នែកយុទ្ធសាស្ត្រ និងគម្រោងសាជីវកម្ម
• អ្នកស្រី Duangdao WONGPANITKRIT ជាអភិបាល និងជាអគ្គនាយកផ្នែកហិរញ្ញវត្ថុរបស់ Krungsri
• លោក Chandrashekar SUBRAMANIAN KRISHCONDMANGALAM ជាអភិបាល និងអគ្គនាយកផ្នែកគ្រប់គ្រងហានិភ័យ
• លោក Piyasak UKRITNUKUN ជាអភិបាល និងជានាយកគ្រប់គ្រងក្រុមហ៊ុន Ngern Tid Lor Co., Ltd. (លាលែងនៅថ្ងៃ២៧ ខែឧសភា ឆ្នាំ២០១៩)
• បណ្ឌិត ឌី ដាវុឌ្ឍ ជាអភិបាលឯករាជ្យ និងជាសកលវិទ្យាធិការរងសកលវិទ្យាល័យ Build Bright
• លោក ឡុញ ហៃ ជាអភិបាលឯករាជ្យ
• អ្នកស្រី តាល់ ណៃអឹម ជាអភិបាលឯករាជ្យ (លាលែង នៅថ្ងៃ២៧ ខែឧសភា ឆ្នាំ២០១៩)
• លោកឧកញ៉ា ហួត អៀងតុង ជាអភិបាល និងជាប្រធានអគ្គនាយករបស់ក្រុមហ៊ុនហត្ថាកសិករ លីមីតធីត
• លោក Wanchairabin JITWATTANATAM ជាអភិបាល និងជាអនុប្រធានអគ្គនាយករបស់ក្រុមហ៊ុនហត្ថាកសិករ លីមីតធីត (តែងតាំងនៅថ្ងៃ២៧ ខែឧសភា ឆ្នាំ២០១៩)
• លោក ប៉ាក់ សេរីវឌ្ឍនា ជាអភិបាលឯករាជ្យ (តែងតាំងនៅថ្ងៃ២៧ ខែឧសភា ឆ្នាំ២០១៩)

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុង និងនាចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានការរៀបចំណាមួយដែលមានសម្ព័ន្ធក្រុមហ៊ុន និង ក្រុមហ៊ុនជាគូភាគី ក្នុងគោលបំណងជួយដល់សមាជិកក្រុមប្រឹក្សាភិបាលរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដោយមធ្យោបាយទិញយកភាគហ៊ុននោះទេ។

ចាប់តាំងពីដើមការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ របស់សម្ព័ន្ធ ក្រុមហ៊ុន និងក្រុមហ៊ុន ទទួលបាន ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានទទួលដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ឬក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលនោះជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលនោះ មានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើននោះទេ លើកលែងតែមានការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈធ្វើឲ្យប្រាកដថា របាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងត្រឹមត្រូវ ដើម្បីចង្អុលបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៩ និងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ៖
• អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព។
• អនុវត្តទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRSs) ឬប្រសិនបើមានការប្រាសចាកណាមួយក្នុងការបង្ហាញឲ្យមានភាពត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថា ការប្រាសចាកទាំងនេះត្រូវបានបង្ហាញពន្យល់ និងកំណត់បរិមាណឲ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។
• រក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព។
• រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លុះត្រាតែមានករណីមិនសមរម្យក្នុងការសន្មតថា សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន នឹងមិនបន្តធ្វើប្រតិបត្តិការអាជីវកម្មនាពេលអនាគត។
• ត្រួតពិនិត្យ និងដឹកនាំសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ឲ្យមានប្រសិទ្ធភាព និងចូលរួមរាល់សេចក្តីសម្រេចសំខាន់ៗទាំងឡាយណាដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថា កិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ក្រុមប្រឹក្សាភិបាលធានាអះអាងថា សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន បានអនុវត្តនូវរាល់ការតម្រូវដូចបានរាយការណ៍ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

"

## ការបញ្ជាក់របស់ក្រុមប្រឹក្សាភិបាល

របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់ជាមួយ បានបង្ហាញនូវភាពត្រឹមត្រូវ នូវរបាយការណ៍ស្ថានភាព ហិរញ្ញវត្ថុរួមនិងដាច់ដោយឡែក នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់
សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹង ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា
ហើយនាកាលបរិច្ឆេទចេញផ្សាយរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលជឿជាក់ថា សម្ព័ន្ធក្រុមហ៊ុន
និងក្រុមហ៊ុនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទូទាត់បំណុលនៅពេលដល់កំណត់សង។

**ចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាភិបាល**



**លោកឧកញ៉ា ហួត អៀងតុង**
**ប្រធានអគ្គនាយក**
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទ៖ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០

"

# ង. របាយការណ៍របស់សវនករឯករាជ្យ

## តារាងតុល្យការ

| ទ្រព្យសកម្ម | នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ ដុល្លារអាមេរិក | នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ រៀល'000 | នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ CIFRS ដុល្លារអាមេរិក | នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ CIFRS រៀល'000 | នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ CIFRS ដុល្លារអាមេរិក | នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ CIFRS រៀល'000 |
|---|---|---|---|---|---|---|
| សាច់ប្រាក់ក្នុងដៃ | ៣៧.២១១.១៥៥ | ១៤៩.៥១៤.៤២១ | ៣៧.២១១.១៥៥ | ១៤៩.៥១៤.៤២១ | ៣៤.១៩០.៤៤៥ | ១៣៩.៣២៦.០៦៣ |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | ៧៧.៥៤១.៧៣៤ | ៣១១.៥៦២.៨៤៨ | ៧៧.៦០២.១៨៨ | ៣១១.៨០៥.៥៩១ | ៩៥.៩៣៤.៥៨៥ | ៣៩០.៩៣៣.៤៣៤ |
| សមតុល្យនៅធនាគារនានា-សុទ្ធ | ៣៩.២១០.៦៣៦ | ១៥៧.៥៤៨.៣៣៥ | ៣៩.៥៩៤.៣១៥ | ១៥៩.០៨៩.៩៥៨ | ៩.៦៥៧.៨០៣ | ៣៩.៣៥៥.៥៤៧ |
| ឥណទានផ្តល់ដល់អតិថិជន-សុទ្ធ | ៧៤៧.០០៥.០៦៤ | ៣.០០១.៤៦៦.៣៤៧ | ៧៤១.៨៣៩.០២៨ | ២.៩៨០.៧០៩.២១៥ | ១.០៣៦.២៧២.៩៣០ | ៤.២២២.៨១២.១៩០ |
| វិនិយោគលើមូលបត្រ | - | - | ២០.០០០ | ៨០.៣៦០ | ២០.០០០ | ៨១.៥០០ |
| វិនិយោគលើក្រុមហ៊ុនបុត្រសម្ព័ន្ធ | - | - | - | - | ៤៩០ | ១.៩៩៧ |
| ទឹកប្រាក់ត្រូវទទួលពីសម្ព័ន្ធញាតិ | ១៤.៦៩២ | ៥៩.០៣២ | - | - | - | - |
| ទ្រព្យសកម្មផ្សេងៗ | ១១.៩១៤.៣៧២ | ៤៧.៨៧១.៩៤៧ | ៧.៩៣៨.៨៧៧ | ៣១.៨៩៨.៤០៨ | ២៨.០៧១.៦៧៦ | ១១៤.៣៩២.០៨១ |
| ទ្រព្យសម្បត្តិ និងបរិក្ខា | ៤.១៤៨.៦៣៤ | ១៦.៦៦៩.២១១ | ៤.១៤៨.៦៣៤ | ១៦.៦៦៩.២១១ | ៤.២០១.១២៩ | ១៧.១១៩.៦០១ |
| សិទ្ធិក្នុងការប្រើទ្រព្យសកម្ម | - | - | ១២.៧៨៨.២៦៥ | ៥១.៣៨៣.២៤៩ | ១២.២៨១.២៥៧ | ៥០.០៤៦.១២២ |
| ទ្រព្យសកម្មអរូបិយ | ៨៣៥.៩១១ | ៣.៣៥៨.៦៩០ | ៨៣៥.៩១១ | ៣.៣៥៨.៦៩០ | ២.៣០០.៤៧១ | ៩.៣៧៤.៤១៩ |
| ពន្ធពន្យាជាទ្រព្យសកម្មសុទ្ធ | ១.៨៧១.២៧១ | ៧.៥១៨.៧៦៧ | ៣.១០០.២១២ | ១២.៤៥៦.៦៥២ | ៣.៩០២.៦៨៣ | ១៥.៩០៣.៤៣៣ |
| **សរុបទ្រព្យសកម្ម** | **៩១៩.៧៥៣.៥០៩** | **៣.៦៩៥.៥៦៩.៥៩៨** | **៩២៥.០៧៨.៥៨៥** | **៣.៧១៦.៩៦៥.៧៥៥** | **១.២២៦.៨៣៣.៤៦៩** | **៤.៩៩៩.៣៤៦.៣៨៧** |

## បំណុល និងមូលធន

### បំណុល

| | | | | | | |
|---|---|---|---|---|---|---|
| ប្រាក់បញ្ញើរបស់អតិថិជន | ៤៨០.០៩៣.៥៤១ | ១.៩២៩.០១៥.៨៤៨ | ៤៩១.៣៥៣.៣៩០ | ១.៩៧៤.២៥៧.៩២១ | ៦១០.០៩៩.៣២៧ | ២.៤៨៦.១៥៤.៧៥៨ |
| មូលបត្របំណុល | ២៩.៨៦៥.៦០៥ | ១២០.០០០.០០០ | ២៩.៨៦៥.៦០៥ | ១១៧.៨២៨.៨៦៣ | ២៩.១៩៦.០៧២ | ១១៨.៩៧៣.៩៩៣ |
| ប្រាក់កម្ចី | ១៩២.៣៨៤.៩៣២ | ៧៧៣.០០២.៦៥៧ | ១៩១.៧២៥.១៥៨ | ៧៧០.៣៥១.៦៥៧ | ៣១១.៤៨៥.៩៨២ | ១.២៦៩.៣០៥.៣៧៧ |
| ទឹកប្រាក់ជំពាក់សម្ព័ន្ធញាតិ | ១៣៥.៣២២ | ៥៤៣.៧២៤ | - | - | - | - |
| អនុបំណុល | ២២.៧២៩.៣១៩ | ៩១.៣២៦.៤០៤ | ២៣.២៣៦.២៩៦ | ៩៣.៣៦៣.៤៣៧ | ១១.៩៧៤.៩២១ | ៤៨.៧៩៧.៨០៣ |
| និស្សន្ទសម្រាប់ទប់ស្កាត់ហានិភ័យ | - | - | ២៧.៧៩៤ | ១១១.៦៧៦ | ១.៨៨៧.៥៨៤ | ៧.៦៩១.៩០៥ |
| បំណុលភតិសន្យា | - | - | ១៣.១៧២.៤៤៨ | ៥២.៩២៦.៨៩៦ | ១៣.០០៥.២១០ | ៥២.៩៩៦.២៣១ |
| អត្ថប្រយោជន៍ក្រោយឈប់ពីការងារ | ១២.៥៨០ | ៥០.៥៤៦ | - | - | - | - |
| បំណុលផ្សេងៗ | ១៨.៤៩៨.២៥៥ | ៧៤.៣២៥.៩៨៩ | ៥.១២៧.៧៥៣ | ២០.៦០៣.៣១២ | ៤៨.១៧៩.២៦០ | ១៩៦.៣៣០.៤៨៥ |
| បំណុលពន្ធលើប្រាក់ចំណេញ | ៤.៨៦២.៥៤២ | ១៩.៥៣៧.៦៩៤ | ៤.៨៦២.៥៤២ | ១៩.៥៣៧.៦៩៤ | ២.៦៣២.៨៩៩ | ១០.៧២៩.០៦៣ |
| សំវិធានធនសម្រាប់ខ្ទង់ក្រៅតារាងតុល្យការ | ១១.២៩៨ | ៤៥.៣៩៤ | ៣.៥៩៩ | ១៤.៤៦១ | ២.៧១៧ | ១១.០៧២ |
| **សរុបបំណុល** | ៧៤៨.៥៩៣.៣៩៤ | ៣.០០៧.៨៤៨.២៥៦ | ៧៥៨.៨៣៤.២៣២ | ៣.០៤៨.៩៩៩.៩៤៥ | ១.០២៨.៤៦៣.៩៧២ | ៤.១៩០.៩៩០.៦៨៧ |

### មូលធន

| | | | | | | |
|---|---|---|---|---|---|---|
| ដើមទុន | ៧៥.០០០.០០០ | ៣០១.៣៥០.០០០ | ៧៥.០០០.០០០ | ៣០១.៣៥០.០០០ | ៧៥.០០០.០០០ | ៣០៥.៦២៥.០០០ |
| បុព្វលាភភាគហ៊ុន | ១៩.០៨២.៥០២ | ៧៦.៦៧៣.៤៩៣ | ១៩.០៨២.៥០២ | ៧៦.៦៧៣.៤៩៣ | ១៩.០៨២.៥០២ | ៧៧.៧៦១.១៩៦ |
| ទុនបម្រុងស្របច្បាប់ | ៦៨២.៤៥៩ | ២.៧៤២.១២០ | ៦៨២.៤៥៩ | ២.៧៤២.១២០ | ៦៨២.៤៥៩ | ២.៧៨១.០២០ |
| ទុនបម្រុងផ្សេងៗ | ១.២៩២.៧៥៥ | ៥.១៩៤.២៩០ | ៣.៧០៦.៧២៧ | ១៣.៤៦៨.៤៧៩ | ៨.១៣៥.៩៣៣ | ៣៧.៦៥៣.៩៧៦ |
| ប្រាក់ចំណេញរក្សាទុក | ៧៥.១០២.៣៩៩ | ៣០១.៧៦១.៤៣៩ | ៦៧.៧៧២.៦៦៥ | ២៧៣.៧៣៥.៧១៨ | ៩៥.៤៦៨.៦០៣ | ៣៨៤.៥៣៤.៥០៨ |
| **សរុបមូលធន** | **១៧១.១៦០.១១៥** | **៦៨៧.៧២១.៣៤២** | **១៦៦.២៤៤.៣៥៣** | **៦៦៧.៩៦៩.៨១០** | **១៩៨.៣៦៩.៤៩៧** | **៨០៨.៣៥៥.៧០០** |
| **សរុបបំណុល និងមូលធន** | **៩១៩.៧៥៣.៥០៩** | **៣.៦៩៥.៥៦៩.៥៩៨** | **៩២៥.០៧៨.៥៨៥** | **៣.៧១៦.៩៦៥.៧៥៥** | **១.២២៦.៨៣៣.៤៦៩** | **៤.៩៩៩.៣៤៦.៣៨៧** |

## របាយការណ៍លទ្ធផល

| | សម្រាប់ការិយបរិច្ឆេទដែលបាន បញ្ចប់នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ | | សម្រាប់ការិយបរិច្ឆេទដែលបាន បញ្ចប់នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ CIFRS | | សម្រាប់ការិយបរិច្ឆេទដែលបាន បញ្ចប់នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ CIFRS | |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | រៀល'000 | ដុល្លារអាមេរិក | រៀល'000 | ដុល្លារអាមេរិក | រៀល'000 |
| ចំណូលពីការប្រាក់ | ១១៤.៩៧០.៥៤៣ | ៤៦១.៩៥១.៦៤២ | ១១០.៥៩៤.៩៤៧ | ៤៤៧.៣៥៦.៥៦១ | ១៤១.៩៦០.៦៣១ | ៥៧៥.២២៤.៤៧៧ |
| ចំណាយលើការប្រាក់ | (៤៦.៨២១.៣៤៨) | (១៨៨.១២៨.១៧៦) | (៤៦.៨៩៧.០៧៧) | (១៨៩.៦៩៨.៦៧៦) | (៥៩.៤៩៧.៤៧០) | (២៤១.០៨៣.៧៤៨) |
| **ចំណូលពីការប្រាក់សុទ្ធ** | **៦៨.១៤៩.១៩៥** | **២៧៣.៨២៣.៤៦៦** | **៦៣.៦៩៧.៨៧០** | **២៥៧.៦៥៧.៨៨៥** | **៨២.៤៦៣.១៦១** | **៣៣៤.១៤០.៧២៩** |
| ចំណូលពីកំរ៉ៃជើងសារ | - | - | ៣.២៥៧.៩៩៣ | ១៣.១៧៨.៥៨២ | ៤.៩០៩.៥០៧ | ១៩.៨៩៣.៣២២ |
| ចំណាយលើកំរ៉ៃជើងសារ | - | - | (៧០២.៦៥៣) | (២.៨៤២.២៣១) | (៦៩៨.០៣២) | (២.៨២៨.៤២៦) |
| **ចំណូលសុទ្ធពីកំរ៉ៃជើងសារ** | - | - | **២.៥៥៥.៣៤០** | **១០.៣៣៦.៣៥១** | **៤.២១១.៤៧៥** | **១៧.០៦៤.៨៩៦** |
| ខាតសុទ្ធពីឧបករណ៍ហិរញ្ញវត្ថុវាស់វែងតាម FVYPL | - | - | (១៩០.១៦៦) | (៧៦៩.២២១) | (១.៩៦៥.៣១០) | (៧.៩៦៣.៤៣៦) |
| ចំណូលផ្សេងៗ | ១.៩៥២.២១៤ | ៧.៨៤៣.៩៩៦ | ១៧៣.៨១៧ | ៧០៣.០៩០ | ២២៨.២៧៥ | ៩២៤.៩៧០ |
| ចំណាយបុគ្គលិក | - | - | (២៥.៧៨៣.១៣៤) | (១០៤.២៩២.៧៧៧) | (៣៤.៣៨៣.៤៣៤) | (១៣៩.៣២១.៦៧៥) |
| ចំណាយរំលស់ | - | - | (៤.៩៩០.៦៩៣) | (២០.១៨៧.៣៥៣) | (៥.៣២៨.៤០៣) | (២១.៥៩០.៦៨៩) |
| ចំណាយផ្សេងៗ | - | - | (៤.៩៩០.៦៩៣) | (៣៣.១០៩.៤៧៨) | (៩.៨២៩.៣៥៦) | (៣៩.៨២៨.៥៥១) |
| ចំណាយប្រតិបត្តិការ | -៣៨.៦០០.៧០៩ | -១៥៥.០៩៧.៦៤៩ | - | - | - | - |
| **ចំណេញប្រតិបត្តិការ** | **៣១.៥០០.៧០០** | **១២៦.៥៦៩.៨១៣** | **២៧.២៧៧.៧៤៩** | **១១០.៣៣៨.៤៩៧** | **៣៥.៣៩៦.៤០៨** | **១៤៣.៤២៦.២៤៤** |
| ចំណេញ/(ខាត)សុទ្ធពីឧបករណ៍ហិរញ្ញវត្ថុ | (៥.៤៤៤.០១៤) | (២១.៨៧៤.០៤៨) | (៣.៦១៨.៤៨៨) | (១៤.៦៣៦.៧៨៤) | ១០៥.២២៤ | ៤២៦.៣៦៨ |
| **ប្រាក់ចំណេញមុនដកពន្ធ** | **២៦.០៥៦.៦៨៦** | **១០៤.៦៩៥.៧៦៥** | **២៣.៦៥៩.២៦១** | **៩៥.៧០១.៧១៣** | **៣៥.៥០១.៦៣២** | **១៤៣.៨៥២.៦១២** |
| ពន្ធលើប្រាក់ចំណេញ | (៥.២៨៧.២៥៨) | (២១.២៤៤.២០៣) | (៤.៨០៧.៧៧៣) | (១៩.៤៤៧.៤៤២) | (៣.៣៧៦.៤៨៨) | (១៣.៦៨១.៥២៩) |
| **ប្រាក់ចំណេញសុទ្ធក្នុងគ្រា** | **២០.៧៦៩.៤២៨** | **៨៣.៤៥១.៥៦២** | **១៨.៨៥១.៤៨៨** | **៧៦.២៥៤.២៧១** | **៣២.១២៥.១៤៤** | **១៣០.១៧១.០៨៣** |
| ចំណូលលំអិតផ្សេងៗ | - | - | - | (១.៤២៥.១៥០) | - | ៤.៥០០.០៤៩ |
| **សរុបប្រាក់ចំណេញក្នុងឆ្នាំ** | - | - | **១៨.៨៥១.៤៨៨** | **៧៤.៨២៩.១២១** | **៣២.១២៥.១៤៤** | **១៣៤.៦៧១.១៣២** |

## របាយការណ៍ បម្រែបម្រួលមូលធន

| | ដើមទុន | បុព្វលាភភាគហ៊ុន | ទុនបម្រុងស្របច្បាប់ | ទុនបម្រុងផ្សេងៗ | ប្រាក់ចំណេញរក្សាទុក | សរុប |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| នាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨ | ៣០.០០០.០០០ | ១៩.០៨២.៥០២ | ៦៨២.៤៥៩ | ១.១៤៥.៧១៤ | ៥៤.៤៨០.០១២ | ១០៥.៣៩០.៦៨៧ |
| ដើមទុនបន្ថែម (កំណត់សម្គាល់ ២០ និងកំណត់សម្គាល់ ២៨ (ច)) | ៤៥.០០០.០០០ | - | - | - | - | ៤៥.០០០.០០០ |
| ប្រាក់ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | - | - | - | - | ២០.៧៦៩.៤២៨ | ២០.៧៦៩.៤២៨ |
| ការផ្ទេរចូលទុនបម្រុងផ្សេងៗ | - | - | - | ១៤៧.០៤១ | (១៤៧.០៤១) | - |
| នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ | ៧៥.០០០.០០០ | ១៩.០៨២.៥០២ | ៦៨២.៤៥៩ | ១.២៩២.៧៥៥ | ៧៥.១០២.៣៩៩ | ១៧១.១៦០.១១៥ |
| សមមូលជាពាន់រៀល នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ | ៣០១.៣៥០.០០០ | ៧៦.៦៧៣.៤៩៣ | ២.៧៤២.១២០ | ៥.១៩៤.២៩០ | ៣០១.៧៦១.៤៣៩ | ៦៨៧.៧២១.៣៤២ |
| នាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨ - CIFRS | ៣០.០០០.០០០ | ១៩.០៨២.៥០២ | ៦៨២.៤៥៩ | ២.០៣៨.៦៤២ | ៥០.៥៨៩.២៦២ | ១០២.៣៩២.៨៦៥ |
| ដើមទុនបន្ថែម (កំណត់សម្គាល់ ២០ និងកំណត់សម្គាល់ ២៨ (ច)) | ៤៥.០០០.០០០ | - | - | - | - | ៤៥.០០០.០០០ |
| ប្រាក់ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | - | - | - | - | ១៨.៨៥១.៤៨៨ | ១៨.៨៥១.៤៨៨ |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុក ទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | ១.៥២១.០៤៤ | (១.៥២១.០៤៤) | - |
| ការផ្ទេរចូលទុនបម្រុងផ្សេងៗ | - | - | - | ១៤៧.០៤១ | (១៤៧.០៤១) | - |
| នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ | ៧៥.០០០.០០០ | ១៩.០៨២.៥០២ | ៦៨២.៤៥៩ | ៣.៧០៦.៧២៧ | ៦៧.៧៧២.៦៦៥ | ១៦៦.២៤៤.៣៥៣ |
| សមមូលជាពាន់រៀល នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ | ៣០១.៣៥០.០០០ | ៧៦.៦៧៣.៤៩៣ | ២.៧៤២.១២០ | ១៣.៤៦៨.៤៧៩ | ២៧៣.៧៣៥.៧១៨ | ៦៦៧.៩៦៩.៨១០ |

| | | | | | | |
|---|---|---|---|---|---|---|
| នាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៩ - CIFRS | ៧៥.០០០.០០០ | ១៩.០៨២.៥០២ | ៦៨២.៤៥៩ | ៣.៧០៦.៧២៧ | ៦៧.៧៧២.៦៦៥ | ១៦៦.២៤៤.៣៥៣ |
| ដើមទុនបន្ថែម (កំណត់សម្គាល់ ២០ និងកំណត់សម្គាល់ ២៨ (ច)) | - | - | - | - | - | - |
| ប្រាក់ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | - | - | - | - | ៣២.១២៥.១៤៤ | ៣២.១២៥.១៤៤ |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | ៤.៣១០.៥១៦ | (៤.៣១០.៥១៦) | - |
| ការផ្ទេរចូលទុនបម្រុងផ្សេងៗ | - | - | - | ១១៨.៦៩០ | (១១៨.៦៩០) | - |
| នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ | ៧៥.០០០.០០០ | ១៩.០៨២.៥០២ | ៦៨២.៤៥៩ | ៨.១៣៥.៩៣៣ | ៩៥.៤៦៨.៦០៣ | ១៩៨.៣៦៩.៤៩៧ |
| សមមូលជាពាន់រៀល នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ | ៣០៥.៦២៥.០០០ | ៧៧.៧៦១.១៩៦ | ២.៧៨១.០២០ | ៣៧.៦៥៣.៩៧៦ | ៣៨៤.៥៣៤.៥០៨ | ៨០៨.៣៥៥.៧០០ |

## របាយការណ៍លំហូរសាច់ប្រាក់

| | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ | | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ CIFRS | | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ CIFRS | |
|---|---|---|---|---|---|---|
| **របាយការណ៍លំហូរសាច់ប្រាក់ ( ១/២ )** | ដុល្លារអាមេរិក | រៀល'០០០ | ដុល្លារអាមេរិក | រៀល'០០០ | ដុល្លារអាមេរិក | រៀល'០០០ |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | | |
| ចំណេញមុនដកពន្ធលើប្រាក់ចំណេញ | ២៦.០៥៦.៦៨៦ | ១០៤.៦៩៥.៧៦៥ | ២៣.៦៥៩.២៦១ | ៩៥.៧០១.៧១៣ | ៣៥.៥០១.៦៣២ | ១៤៣.៨៥២.៦១២ |
| **និយ័តភាពលើចំណូល និងចំណាយមិនមែនសាច់ប្រាក់** | | | | | | |
| ចំណូលពីការប្រាក់សុទ្ធ | (៦៨.១៤៩.១៩៥) | (២៧៣.៨២៣.៤៦៦) | (៦៣.៦៩៧.៨៧០) | (២៥៧.៦៥៧.៨៨៥) | (៨២.៤៦៣.១៦១) | (៣៣៤.១៤០.៧២៩) |
| ខាតសុទ្ធពីឧបករណ៍ហិរញ្ញវត្ថុវាស់វែងតាម FVYPL | - | - | ១៩០.១៦៦ | ៧៦៩.២២១ | ១.៩៦៥.៣១០ | ៧.៩៦៣.៤៣៦ |
| ចំណេញ/(ខាត)សុទ្ធពីឧបករណ៍ហិរញ្ញវត្ថុ | ៥.៤៤៤.០១៤ | ២១.៨៧៤.០៤៨ | ៣.៦១៨.៤៨៨ | ១៤.៦៣៦.៧៨៤ | (១០៥.២២៤) | (៤២៦.៣៦៨) |
| រំលស់ | ២.៣៣៦.២៩២ | ៩.៣៨៧.២២១ | ៤.៩៩០.៦៩៣ | ២០.១៨៧.៣៥៣ | ៥.៣២៨.៤០៣ | ២១.៥៩០.៦៨៩ |
| ចំណាយបុគ្គលិកផ្សេងៗ | - | - | ១.១៩១.០២៣ | ៤.៨១៧.៦៨៨ | ១.២៨៦.៧២០ | ៥.២១៣.៧៨៩ |
| អត្ថប្រយោជន៍ក្រោយឈប់ពីការងារ | ៩១៩.២៤៥ | ៣.៦៩៣.៥២៦ | - | - | - | - |
| ចំណេញពីការលក់ទ្រព្យសម្បត្តិ | (៦៧៥) | (២.៧១២) | (៦៧៥) | (២.៧៣០) | ២.៣៣៣ | ៩.៤៥៣ |
| **ចំណូលពីការប្រាក់សុទ្ធលំអៀងពីការប្តូររូបិយប័ណ្ណ:** | | | | | | |
| ប្រាក់កម្ចី | ៤៩.៤៩៨ | ១៩៨.៨៨៣ | ៥៨.៦៦៤ | ២៣៧.២៩៦ | ១១០.០២៣ | ៤៤៥.៨១៣ |
| ចំណេញពីការលក់ទ្រព្យសម្បត្តិ | (៣៣.៣៨៤.១៣៥) | (១៣៣.៩៧៦.៧៣៥) | (២៩.៩៩០.២៥០) | (១២១.៣១០.៥៦០) | (៣៨.៣៧៣.៩៦៤) | (១៥៥.៤៩១.៣០៥) |
| **ការប្រែប្រួលនូវ** | | | | | | |
| សមតុល្យនៅធនាគារជាតិ នៃ កម្ពុជា | (១៤.២៧៩.៨៤១) | (៥៧.៣៧៦.៤០១) | (១៤.២៧៩.៨៤១) | (៥៧.៧៦១.៩៥៧) | (១៣.៦៤១.៦៣១) | (៥៥.២៧៥.៨៨៩) |
| ឥណទានផ្តល់ដល់អតិថិជន | (១៨៤.៥០៥.៥១១) | (៧៤១.៣៤៣.១៤៣) | (១៨៣.៩៨០.១៨៤) | (៧៤៤.១៩៩.៨៤៤) | (២៩៦.៥០០.៦៧៩) | (១.២០១.៤២០.៧៥១) |
| ទឹកប្រាក់ត្រូវទទួលពីសម្ព័ន្ធញាតិ | (១៤.៦៩២) | (៥៩.០៣២) | - | - | - | - |
| ទ្រព្យសកម្មផ្សេងៗ | (១.៦៨៣.១៧៨) | (៦.៧៦៣.០០៩) | (១៩១.៤២៧) | (៧៧៤.៣២២) | (១៨.៨៤៨.៨៨៩) | (៧៦.៣៧៥.៦៩៨) |
| ប្រាក់បញ្ញើរបស់អតិថិជន | ១១២.៦៧២.៤៦២ | ៤៥២.៧១៧.៩៥២ | ១១២.៦៧២.៤៦០ | ៤៥៥.៧៦០.១០១ | ១១៧.៩៤១.៧៤៩ | ៤៧៧.៨៩៩.៩៦៧ |
| ទឹកប្រាក់ជំពាក់សម្ព័ន្ធញាតិ | (៦៩.៣៣៩) | (២៧៨.៦០៤) | - | - | - | - |
| បំណុលផ្សេងៗ | ១.៤១១.៥១៣ | ៥.៦៧១.៤៥៩ | ១.២៨៦.៤៦០ | ៥.២០៣.៧៣១ | ៤៣.០៥១.៥០៧ | ១៧៤.៤៤៤.៧០៦ |
| | (១១៩.៨១២.៧២១) | (៤៨១.៤០៧.៥១៣) | (១១៤.៤៨២.៧៨២) | (៤៦៣.០៨២.៨៥១) | (២០៦.៣៧១.៩០៧) | (៨៣៦.២១៨.៩៧០) |
| ការប្រាក់បានទទួល | ១១៤.០៨៩.៣២១ | ៤៥៨.៤១០.៨៩២ | ១១១.២២២.៥៣៨ | ៤៤៩.៨៩៥.១៦៦ | ១៤១.៤១៣.៩៣០ | ៥៧៣.០០៩.២៤៤ |
| ការប្រាក់បានបង់ | (៤៣.៩៥១.៤១៤) | (១៧៦.៥៩៦.៧៨២) | (៤៤.៣៤៦.២៦០) | (១៧៩.៣៨០.៦២២) | (៥៧.៤៥៧.៣២៨) | (២៣២.៨១៧.០៩៣) |
| ពន្ធលើប្រាក់ចំណេញបានបង់ | (៤.៥៣៦.៥៧៨) | (១៨.២២៧.៩៧០) | (៤.៥៣៦.៥៧៨) | (១៨.៣៥០.៤៥៨) | (៦.៤០៨.៦០២) | (២៥.៩៦៧.៦៥៥) |
| អត្ថប្រយោជន៍ក្រោយឈប់ពីការងារបានបង់ | (១.០៥៧.៤៩១) | (៤.២៤៨.៩៩៩) | - | - | - | - |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ | (៥៥.២៦៨.៨៨៣) | (២២២.០៧០.៣៧២) | (៥២.១៤៣.០៨២) | (២១០.៩១៨.៧៦៥) | (១២៨.៨២៣.៩០៧) | (៥២១.៩៩៤.៤៧៤) |

**លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ**

| | | | | | | |
|---|---|---|---|---|---|---|
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | (២.៣៦៤.៣០៦) | (៩.៤៩៩.៧៨២) | (២.៣៦៤.៣០៦) | (៩.៥៦៣.៦១៨) | (២.២៥៧.០៦១) | (៩.១៤៥.៦១១) |
| ការទិញទ្រព្យសម្បត្តិអរូបិយ | (៣៨៥.៨៨៩) | (១.៥៥០.៥០២) | (៣៨៥.៨៨៩) | (១.៥៦០.៩២១) | (១.៦៩៥.១៨៨) | (៦.៨៦៨.៩០២) |
| សាច់ប្រាក់បានពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | ៧៤៣ | ២.៩៨៥ | ៧៤៣ | ៣.០០៥ | ៧៥៣ | ៣.០៥១ |
| វិនិយោគលើក្រុមហ៊ុនបុត្រសម្ព័ន្ធ | - | - | - | - | (៤៩០) | (១.៩៨៥) |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ | (២.៧៤៩.៤៥២) | (១១.០៤៧.២៩៩) | (២.៧៤៩.៤៥២) | (១១.១២១.៥៣៤) | (៣.៩៥១.៩៨៦) | (១៦.០១៣.៤៤៧) |

| របាយការណ៍លំហូរសាច់ប្រាក់ (២/២) | ដុល្លារអាមេរិក | រៀល'000 | ដុល្លារអាមេរិក | រៀល'000 | ដុល្លារអាមេរិក | រៀល'000 |
|---|---|---|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាព** | | | | | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | ១០៧.៣៤០.០២៣ | ៤៣១.២៩២.២១២ | ១០៧.៣៤០.០២៣ | ៤៣៤.១៩០.៣៩៣ | ១៨៤.៨១៦.៨៥១ | ៧៤៨.៨៧៧.៨៨០ |
| ការទូទាត់សងប្រាក់កម្ចី | (៧១.៣៨៨.៧៧៣) | (២៨៦.៨៤០.០៩០) | (៩០.៣៨៨.៧៧៣) | (៣៦៥.៦២២.៥៨៧) | (៦៥.៧៨៧.០៩៧) | (២៦៦.៥៦៩.៣១៧) |
| សាច់ប្រាក់ទទួលបានពីសម្ព័ន្ធញាតិ | ៨.០០០.០០០ | ៣២.១៤៤.០០០ | - | - | - | - |
| ការទូទាត់សងសម្ព័ន្ធញាតិ | (២៧.០០០.០០០) | (១០៨.៤៨៦.០០០) | - | - | - | - |
| ការទូរទាត់សងប្រាក់ដើមភតិសន្យា | - | - | (៣.១២៥.៨០១) | (១២.៦៤៣.៨៦៥) | (៣.៥២៩.៥៥១) | (១៤.៣០១.៧៤១) |
| ការទូទាត់សងអនុបំណុល | (២.០០០.០០០) | (៨.០៣៦.០០០) | (២.០០០.០០០) | (៨.០៩០.០០០) | (១១.០០០.០០០) | (៤៤.៥៧២.០០០) |
| សាច់ប្រាក់ទទួលបានពីការលក់ | ២៩.៨៦៥.៦០៥ | ១២០.០០០.០០០ | ២៩.៨៦៥.៦០៥ | ១២០.៨០៦.៣៧២ | - | - |
| ការបោះផ្សាយដើមទុនបន្ថែម | ៤៥.០០០.០០០ | ១៨០.៨១០.០០០ | ៤៥.០០០.០០០ | ១៨២.០២៥.០០០ | - | - |
| សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពហិរញ្ញប្បទាន | ៨៩.៨១៦.៨៥៥ | ៣៦០.៨៨៤.១២២ | ៨៦.៦៩១.០៥៤ | ៣៥០.៦៦៥.៣១៣ | ១០៤.៥០០.២០៣ | ៤២៣.៤៣៤.៨២២ |
| ការកើនឡើង/(ថយចុះ) សុទ្ធ នូវសាច់ប្រាក់ និងសាច់ប្រាក់សមមូល | ៣១.៧៩៨.៥២០ | ១២៧.៧៦៦.៤៥១ | ៣១.៧៩៨.៥២០ | ១២៨.៦២៥.០១៤ | (២៨.២៧៥.៦៩០) | (១១៤.៥៧៣.០៩៩) |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅដើមគ្រា | ៧៥.១៧៧.៨០០ | ៣០៣.៤៩២.៧៧៨ | ៧៥.១៧៧.៨០០ | ៣០៣.៤៩២.៧៧៨ | ១០៦.៩៧៦.៣២០ | ៤២៩.៨៣០.៨៥៤ |
| លំអៀងពីការប្តូររូបិយប័ណ្ណ | - | (១.៤២៨.៣៧៥) | - | (២.២៨៦.៩៣៨) | - | ៥.៤៤៧.៣១២ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងគ្រា | ១០៦.៩៧៦.៣២០ | ៤២៩.៨៣០.៨៥៤ | ១០៦.៩៧៦.៣២០ | ៤២៩.៨៣០.៨៥៤ | ៧៨.៧០០.៦៣០ | ៣២០.៧០៥.០៦៧ |

កាន់តែទុកចិត្ត កាន់តែចំរើន

# ហត្ថាកសិករ លីមីតធីត

# HATTHA KAKSEKAR LIMITED


**ការិយាល័យកណ្តាល**

អគារលេខ៦០៦ ផ្លូវលេខ២៧១ សង្កាត់បឹងទំពុនទី១

ខណ្ឌមានជ័យ រាជធានីភ្នំពេញ ប្រទេសកម្ពុជា ប្រអប់សំបុត្រ៖ ២០៤៤

ទូរស័ព្ទ៖ (៨៥៥) ២៣ ៩៩៩ ២៦៦ | លេខថ្ងៃហ្វ្រី៖ ១៨០០ ២១២ ២២២

អ៊ីមែល៖ info@hkl.com.kh | គេហទំព័រ៖ www.hkl.com.kh


ស្កេនសម្រាប់របាយការណ៍ឯកសារទន់